ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍បូកសរុបលទ្ធផល
ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ ២០១៧
និងទិសដៅអនុវត្ត ឆ្នាំ ២០១៨

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ

សារលិខិតថ្លែងអំណរគុណ

សម្តេច ឯកឧត្តម លោកជំទាវ
លោក លោកស្រី ថ្នាក់ដឹកនាំ មន្ត្រីគ្រប់ក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
លោក លោកស្រី ប្រធាន និងបុគ្គលិកអង្គការដៃគូអភិវឌ្ឍន៍អន្តរជាតិ និងអង្គការសង្គមស៊ីវិល
ដែលកំពុងធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរួមគ្នាជាមួយរាជរដ្ឋាភិបាលកម្ពុជា
បងប្អូនជនរួមជាតិ ជាទីគោរពរាប់អាន

របាយការណ៍ជាតិ ស្តីពី “**លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨**” នេះ គឺជាការបង្ហាញអំពីការខិតខំប្រឹងប្រែងរួមគ្នាប្រកបដោយការទទួលខុសត្រូវ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដែលមានក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជាសមាជិក ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គការដៃគូអភិវឌ្ឍន៍អន្តរជាតិ អង្គការសង្គមស៊ីវិលក្នុងស្រុក និងស្ថានតំណាងព្រះរាជាណាចក្រកម្ពុជាប្រចាំនៅក្រៅប្រទេស។ លទ្ធផលការងារឆ្នាំ២០១៧ បានបញ្ជាក់អំពីភាពរីកចម្រើន ក៏ដូចជាភាពប្រឈម និងចំណុចសេសសល់ទាំងឡាយ ដែលយើងទាំងអស់គ្នា ចាំបាច់ ត្រូវបន្តខិតខំ បន្តទៀត មិនអាចធ្វេសប្រហែសបាន ដើម្បីការពារប្រជាជនយើង ក៏ដូចជាមនុស្សជាតិ ពីភាពរងគ្រោះដោយអំពើ ជួញដូរមនុស្សគ្រប់រូបភាព និងដើម្បីបង្កើតភាពសុខសាន្ត និងសុខដុមនីយ៍កម្មក្នុងគ្រួសារ និងក្នុងសង្គមជាតិ ទាំងមូល ។ ជាការពិតណាស់ ប្រសិនបើមិនមានការប្រឹងប្រែងទាំងអស់នេះទេ នោះអំពើកេងប្រវ័ញ្ចរំលោភបំពាន និងជួញដូរមនុស្សនឹងកាន់តែសកម្ម កាន់តែឃោរឃៅ ហើយរីករាលដាលកាន់តែខ្លាំងជាងនេះទៅទៀត។

ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ដើម្បីថ្លែងនូវការកោតសរសើរ និងអំណរគុណចំពោះគ្រប់ការចូលរួម សហការ និងការលះបង់អស់ពីកម្លាំងកាយចិត្ត បញ្ញា ស្មារតី ទ្រព្យធន ពេលវេលា ប្រកបដោយការទទួលខុសត្រូវ របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ វិស័យឯកជនទាំងឡាយ និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ដែលតែងបានប្រឹងប្រែងរួមគ្នាដោះស្រាយបញ្ហាចំពោះមុខតាមទិសដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលដោយមិនខ្លាចនឿយហត់ ពុះពារប្រឆាំងដាច់ខាតទៅនឹងសកម្មភាពរបស់ឧក្រិដ្ឋជនគ្រប់រូបភាព រហូតរក្សាបាននូវសន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម ស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចយ៉ាងល្អប្រសើរ ។

ជាទីបញ្ចាប់ ខ្ញុំសូមឧទ្ទិសបួងសួងដល់គុណព្រះរតនៈត្រ័យ បារមី វត្ថុស័ក្តសិទ្ធិ សូមឲ្យទេវតាឆ្នាំថ្មីប្រទានពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ សូមមានដល់ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងបងប្អូនជនរួមជាតិ សូមប្រកបដោយពរបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃទី...សុក្រ...៨...រោច...ខែផល្គុន...ឆ្នាំរកា...នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី...០៩...ខែ...មីនា...ឆ្នាំ២០១៨

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

សម្តេចក្រឡាហោម ស ខេង

មាតិកា

I.ស្ថានភាពទូទៅ ១
ក .ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ ៣
ក.១-ការងារបទដ្ឋានច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការដែលសម្រេចបាន ៣
ក.១.១-សន្ធិសញ្ញា ៣
ក.១.២-អនុស្សរណៈនៃការយោគយល់គ្នាដែលបានចុះហត្ថលេខាហើយ ៤
ក.១.៣-បទដ្ឋានជាតិ ៤
ក.១.៤-លិខិតបទដ្ឋានរដ្ឋបាលសម្របសម្រួលការងារ ៥
ក.២-ច្បាប់ គោលនយោបាយ និងឯកសារកិច្ចសហប្រតិបត្តិការកំពុងរៀបចំ ៥
ក.២.១-សេចក្តីព្រាងច្បាប់ដែលកំពុងរៀបចំ ៥
ក.២.២-សន្ធិសញ្ញាកំពុងរៀបចំ ៦
ក.២.៣-អនុស្សរណៈកំពុងរៀបចំ ៦
ក.២.៤-បទដ្ឋានគតិយុត្តិ កំពុងរៀបចំ ៦
ខ.ការបង្ការទប់ស្កាត់ ៧
ខ.១-ការគ្រប់គ្រងភ្នាក់ងារជ្រើសរើសពលករឯកជន ៧
ខ.២-កាត់បន្ថយភាពរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ ៨
ខ.៣-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ៨
ខ.៤-យុទ្ធនាការ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ៩
ខ.៥-សកម្មភាពអប់រំតាមសាលារៀន ៩
ខ.៦-ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសម្ភារៈ ១០
ខ.៧-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស ១១
ខ.៧.១-វិធានការទប់ស្កាត់តាមជំនាញរបស់អគ្គស្នងការនគរបាលជាតិ ១១
ខ.៧.២-វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ ១២
ខ.៨-គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់ ១៣
ខ.៨.១-វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក ១៣
ខ.៨.២-ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន ១៤
ខ.៨.៣- ការត្រួតពិនិត្យពលករបរទេសខុសច្បាប់ចូលមកកម្ពុជា ១៤

ខ.៩-ដំណោះស្រាយផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជានៅក្រៅប្រទេស ១៥
ខ.១០-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស......១៦
ខ.១១-ការចុះអធិការកិច្ចដើម្បីការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ..................................... ១៦
គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស... ១៧
គ.១-ការងារអនុវត្តច្បាប់..១៧
គ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ...១៧
គ.១.២-ការកសាងសំណុំរឿង បណ្តឹងជនសង្ស័យរងគ្រោះ បញ្ជូនទៅតុលាការ................................ ១៩
គ.១.៣-ការបង្ក្រាបករណីអន្តរការីនៃការពពោះជំនួស ២០
គ.២-កិច្ចការយុត្តិធម៌ ២០
គ.២.១-លទ្ធផលចំណាត់ការផ្តន្ទាទោសក្នុងឆ្នាំ២០១៧ ....២០
គ.២.២-ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ៖..២០
គ.២.៣-ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ៖.....................................២១
គ.២.៤-ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ រាជធានី-ខេត្ត ៖...២១
ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ...២២
ឃ.១-ការសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញា ជនរងគ្រោះ និងជនសង្ស័យ.. ២២
ឃ.២-ការទទួលជនសង្ស័យរងគ្រោះ ២៣
ឃ.៣-ការជួយជនរងគ្រោះ និងជនងាយរងគ្រោះ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ២៤
II.ការលើកកម្ពស់សមត្ថភាព ២៥
១.ក្នុងប្រទេស ២៥
១.១-ការបណ្តុះបណ្តាលក្នុងប្រទេស ២៥
១.២-សិក្ខាសាលា.. ២៨
១.៣-សន្និសីទ... ៣១
១.៤-ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ ៣១
២.ក្រៅប្រទេស...៣២
២.១-វគ្គបណ្តុះបណ្តាល ៣២

២.២-សិក្ខាសាលា ៣២
២.៣-កិច្ចប្រជុំ ៣៣
២.៤-សន្និសីទ ៣៥
III.ការសន្និដ្ឋានវាយតម្លៃ ៣៦
ក.ចំណុចខ្លាំង ៣៦
ខ .ចំណុចប្រឈម និងចំណុចខ្វះខាត..... ៣៦
គ.សន្និដ្ឋាន ៣៧
IV.ទិសដៅឆ្នាំ២០១៨ ..... ៣៨
ក.ការងារសហប្រតិបត្តិការ៖ ៣៨
ខ.ការងារបង្ការ ទប់ស្កាត់៖ ៣៨
គ.ការងារការពារជនរងគ្រោះ៖ ៣៩
ឃ.ការងារអនុវត្តច្បាប់ និងកិច្ចការយុត្តិធម៌៖ ៣៩
ង.ការងារគាំទ្រ និងតាមដានត្រួតពិនិត្យ៖ ៣៩
- ឧបសម្ព័ន្ធ
- កម្រងរូបភាព

របាយការណ៍បូកសរុប
សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៧ និងទិសដៅ ឆ្នាំ២០១៨

(គិតចាប់ពីថ្ងៃទី ០១ ខែមករា ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧)

I.ស្ថានភាពទូទៅ

សន្តិភាព និង ស្ថេរភាពនយោបាយ គឺជាកត្តាគន្លឹះ និងជាមូលដ្ឋានគ្រឹះដែលនាំឲ្យព្រះរាជាណាចក្រកម្ពុជា មានឱកាសនៅក្នុងការជម្រុញការរីកចម្រើនលើគ្រប់វិស័យ។ ប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** តែងយកចិត្តទុកដាក់ជាសំខាន់លើការគោរពសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ដែលជាមូលដ្ឋានគ្រឹះនៃសន្តិភាព និងការអភិវឌ្ឍ។ ក្នុងនោះ រាជរដ្ឋាភិបាលបានខិតខំជម្រុញការធ្វើកំណែទម្រង់សំខាន់ៗ និងពង្រឹងកិច្ចការពារបូរណភាពទឹកដី និងសន្តិសុខជូនប្រជាពលរដ្ឋ ព្រមទាំងលើកកម្ពស់ជីវភាព និងកាត់បន្ថយភាពក្រីក្របានដោយជោគជ័យ តាមរយៈការស្វែងរកឱកាសការងារ ឬ មុខរបរ ខ្នាតតូច មធ្យម ឬ ធំ សម្រាប់ប្រជាពលរដ្ឋ ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស។ រាជរដ្ឋាភិបាល បានខិតខំដោះស្រាយបញ្ហា និងភាពប្រឈមទាំងឡាយ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ រាប់ទាំង ការកសាងច្បាប់ គោលនយោបាយ លិខិតបទដ្ឋាន យន្តការ និងសេវាចាំបាច់ផ្សេងៗ ក្នុងនោះ ការផ្តល់ភាពស្របច្បាប់ជូនពលករដែលបាន និងកំពុងស្នាក់នៅធ្វើការខុសច្បាប់ ក្នុងប្រទេសថៃ និងការបើកកន្លែងផ្តល់លិខិតឆ្លងដែន និងប័ណ្ណអនុញ្ញាតការងារ នៅទីតាំងសំខាន់ៗមួយចំនួន ក៏ជាដំណោះស្រាយមួយ ដើម្បីការការពារពលករពីការរំលោភបំពាន និងកេងប្រវ័ញ្ច ក្នុងរូបភាពជាពលករខុសច្បាប់។ ទន្ទឹមនឹងនោះ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើកិច្ចការជាច្រើនទៀត ដើម្បីការពារឧត្តមប្រយោជន៍របស់ពលករកម្ពុជានៅក្រៅប្រទេស រួមមាន៖

១.រាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តប្រវេសន៍តាមរយៈការខិតខំជួយពលករដែលធ្វើការនៅបរទេសដើម្បីធានាបាននូវផលប្រយោជន៍ស្របច្បាប់ និងជួយផ្តល់ភាពស្របច្បាប់ដល់ពលករ។

២.រាជរដ្ឋាភិបាលកំពុងសហការជាមួយប្រទេសជាដៃគូ ទទួលស្គាល់ពលករដែលមានជំនាញទៅវិញទៅមកជាមួយកម្ពុជា។

៣.រាជរដ្ឋាភិបាលកំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងកិច្ចសហប្រតិបត្តិការ លើវិស័យរបបសន្តិសុខសង្គម ដោយធានាចំពោះពលករស្របច្បាប់នៅគ្រប់ប្រទេសនៅពេលមានគ្រោះថ្នាក់ដល់ជីវិតឲ្យទទួលបានសំណងតាមច្បាប់។ ពលករទាំងអស់អាចផ្ទេរប្រាក់ធានារ៉ាប់រងសង្គម គ្រោះថ្នាក់ការងារ និងប្រាក់ធានារ៉ាប់រងសុខភាពមកក្រុមគ្រួសារពលករនៅស្រុកកំណើត។

៤.រាជរដ្ឋាភិបាលកំពុងសហការជាមួយបណ្តាប្រទេសអាស៊ាន ក្នុងការអនុវត្តរបបសោធននិវត្តន៍ ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់វិភាគទាន បេឡាសន្តិសុខសង្គមពីប្រទេសមួយបន្ទាប់ពីបានបញ្ចប់កិច្ចសន្យាការងារ ដើម្បីធ្វើជាមូលដ្ឋានគិតប្រាក់សោធននិវត្តន៍ ហើយផលប្រយោជន៍ទាំងនោះពលករនឹងទទួលបាននៅឆ្នាំ២០១៩។

៥.រាជរដ្ឋាភិបាលកំពុងសម្រួលបែបបទជូនពលករនៅបរទេស អាចផ្ទេរសិទ្ធិជូនគ្រួសារ នៅក្នុងប្រទេសឲ្យធ្វើជាតំណាង ដើម្បីស្នើសុំលិខិតថ្កោលទោស លិខិតរដ្ឋបាល ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្ទាល់ខ្លួន ដោយពុំចាំបាច់ឲ្យសាមីខ្លួនវិលត្រឡប់មកស្រុកកំណើតវិញ។ ដោយឡែកសម្រាប់ពលករធ្វើការនៅប្រទេសថៃត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ដើម្បីបំពេញបែបបទស្របច្បាប់ ទាំងនេះ គឺជាអត្ថប្រយោជន៍សម្រាប់ពលករទេសន្តរប្រវេសន៍ ។

លើសពីនេះទៅទៀត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសជាឧឡារិក ចំពោះមុខកម្មករ កម្មការិនីរាប់សិបម៉ឺននាក់ និងចំពោះជនរួមជាតិ អំពីកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាល និងបានដាក់ចេញនូវគោលនយោបាយជាបន្តបន្ទាប់ ដើម្បីលើកទឹកចិត្ត និងលើកកម្ពស់ជីវភាពកម្មករ កម្មការិនីក្នុងស្រុក ដោយបានបញ្ជាក់អំពីការផ្តល់អត្ថប្រយោជន៍ជាច្រើនទៀត សម្រាប់កម្មករ កម្មការិនី ក្នុងប្រទេសដូចជា៖ ប្រាក់ខែកម្មករយ៉ាងតិច **១៧០ដុល្លារ**ក្នុងមួយខែ ចាប់ពីឆ្នាំ២០១៨នេះទៅកម្មការិនីមានផ្ទៃពោះត្រូវបានចេញមុនម៉ោង១៥នាទីយ៉ាតិច និងបានទទួលប្រាក់**១២០%** រួមទាំងច្បាប់ឈប់សម្រាកចំនួន៣ខែក្រោយប្រសូត្របុត្រ និងមានប្រាក់សោធននិវត្តន៍ ពេលឈឺទៅព្យាបាលនៅមន្ទីរពេទ្យរដ្ឋមិនបង់ប្រាក់ ជិះរថយន្តក្រុងរាជធានីភ្នំពេញមិនបង់ប្រាក់ និងបានអំពាវនាវឲ្យគ្រប់គ្រឹះស្ថានទាំងអស់ ទាំងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើម្បីធានានូវសុខុមាលភាពរបស់ប្រជាពលរដ្ឋ កម្មករ-កម្មការិនី ដែលធ្វើការងារជាមួយខ្លួន។ ជូនដំណឹងដល់កម្មករនិយោជិត និងអ្នកពាក់ព័ន្ធ ចំនួន៤ចំណុច ដូចជា៖ ១)ការផ្តល់សេវាមូលនិធិសមធម៌ សុខាភិបាល ២)ការបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ដល់កម្មករនិយោជិត ជាស្ត្រី ទាំងក្នុង និងក្រៅប្រព័ន្ធ ពេលសម្រាលកូន ៣)ក្នុងករណីនិយោជក ម្ចាស់ សហគ្រាស គ្រឹះស្ថាន ម្ចាស់អាជីវកម្ម ឧកខានមិនបានទៅចុះបញ្ជី នៅបេឡាជាតិសន្តិសុខសង្គម និង៤)ចំពោះការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព ដល់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

ដោយឡែក **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** (គ.ជ.ប.ជ) ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន** គឺជាយន្តការថ្នាក់ជាតិ ដែលមានវិសាលភាពដល់ថ្នាក់ក្រោមជាតិ បានរួមសហការជាមួយដៃគូ ជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធទាំងឡាយ រៀបចំ និងអនុវត្តយុទ្ធសាស្ត្រ ផែនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទយ៉ាងសកម្ម ព្រមទាំងបានរកឃើញ និងបង្ក្រាបបទល្មើសជួញដូរមនុស្សជាច្រើនរូបភាព។

បទល្មើសជួញដូរមនុស្ស គឺជាបទឧក្រិដ្ឋដែលមានអង្គការចាត់តាំងប្រកបដោយល្បិចកលខ្ពស់ នាំមនុស្សឆ្លងដែនពីប្រទេសមួយទៅទេសមួយទៀតក្នុងគោលដៅកេងប្រវ័ញ្ច និងបានក្លាយជាទាសភាពសម័យទំនើប ដែលរំលោភបំពានលើសិទ្ធិ សេរីភាព និងអាយុជីវិតមនុស្ស យ៉ាងធ្ងន់ធ្ងរ ។ ប្រជាពលរដ្ឋយើងជាច្រើនបាន និងកំពុងលង់ក្នុងល្បិចកលនៃឧក្រិដ្ឋជន ដែលឆក់ឱកាសបោកបញ្ឆោតមនុស្សទាំងប្រុសស្រីក្មេងចាស់ ដើម្បីកេងប្រវ័ញ្ច រំលោភបំពាន និងជួញដូរ តាមគ្រប់មធ្យោបាយ ដោយអមនុស្សធម៌ និងគ្មានខ្លាចក្រែងអែងច្បាប់ឡើយ។ ថ្មីៗនេះ ក៏មានលេចចេញនូវបទល្មើសជួញដូរសរីរាង្គ និងបទអន្តរការីនៃអំពើពពោះជំនួស ដើម្បីនាំយកទារកចេញទៅក្រៅប្រទេស ដែលជាសញ្ញាណថ្មីពាក់ព័ន្ធនឹងបទល្មើសរត់ពន្ធ ឬជួញដូរទារកឆ្លងដែន។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ ដោះស្រាយ និងបង្ការទប់ស្កាត់ជាបន្ទាន់ ហើយចាប់ផ្តើមកសាងច្បាប់ ដើម្បីគ្រប់គ្រងសកម្មភាពពពោះជំនួសឲ្យបានឆាប់ក្នុងគោលបំណងការពារស្ត្រី និងទារក ដែលជាកម្មវត្ថុនៃអំពើជួញដូរ ។

ការចេញទៅធ្វើការនៅប្រទេសក្រៅដោយប្រថុយប្រថាន គ្មានឯកសារតាមផ្លូវច្បាប់ គឺជាមូលហេតុមួយដែលនាំឲ្យមានភាពរងគ្រោះដោយអំពើកេងប្រវ័ញ្ច រត់ពន្ធ និងជួញដូរមនុស្ស ។ ហេតុនេះហើយ បានជារាជរដ្ឋាភិបាលចាំបាច់ត្រូវដោះស្រាយ ដែលចាប់ផ្តើមពីការដោះស្រាយផ្តល់ភាពស្របច្បាប់ដល់ពលករ ដែលមានចំនួនច្រើនលើសលុប រហូតដល់ជាងមួយលាននាក់ និង មានតែប្រមាណជិត ៣០ភាគរយប៉ុណ្ណោះ ដែលត្រូវបានបញ្ជូនដោយមានឯកសារច្បាប់ តាមអនុស្សរណៈយោគយល់គ្នារវាងថៃ-កម្ពុជា ដែលបានកំណត់ ។ ពលករមួយចំនួនត្រូវបានផ្តល់ភាពស្របច្បាប់បណ្តោះអាសន្ន តាមរយៈការផ្តល់ការអនុញ្ញាតឲ្យធ្វើការងារ ដោយរដ្ឋាភិបាលថៃជាឯកត្តោភាគី (ប័ណ្ណស៊ីជម្ពូ) និង ឯមួយចំនួនធំទៀត មិនមានឯកសារសោះ ។ ដោយមានការឯកភាពគ្នារវាងរដ្ឋាភិបាលថៃ និងកម្ពុជា ពលករទាំងនោះ ត្រូវបានដោះស្រាយផ្តល់ភាពស្របច្បាប់ តាមរយៈការចុះឈ្មោះស្នើសុំលិខិតឆ្លងដែន ប័ណ្ណអនុញ្ញាតការងារ និងប័ណ្ណស្នាក់នៅបណ្តោះអាសន្ន ដើម្បីបានគ្រប់គ្រប់លក្ខ័ណ្ឌ តែពលករត្រូវចំណាយខ្ពស់ ហើយចំណូលដែលរកបាន ត្រូវចំណាយស្ទើរទាំងស្រុងនៅក្នុងប្រទេសថៃ ។ ដំណោះស្រាយនេះ នឹងមិនអាចបញ្ចប់បានដោយងាយៗឡើយ ព្រោះនៅមានពលករដែលនៅសេសសល់មិនទាន់ចុះបញ្ជី និងមានអ្នកដែលចូលទៅថ្មីទៀតជំនួសកម្លាំងដែលទ្រុឌទ្រោមបាត់បង់សមត្ថភាពពលកម្ម។ ចំណែកឯរាជរដ្ឋាភិបាលកម្ពុជាត្រូវរែកពុន បន្ទុកជាច្រើនទៀត ដែលកើតចេញពីការវិលត្រឡប់ ឬបញ្ជូនត្រឡប់ ពេលដែលពលករទាំងនោះ បាត់បង់សមត្ថភាពពលកម្ម ចាស់ជរា និងក្មេងក្នុងគ្រួសារទេសន្តរប្រវេសន៍ ដែលគ្មានទីពឹងជាដើម ។

លទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិទី១នៃការអនុវត្តផែនការសកម្មភាពជាតិ ២០១៤-២០១៨ ដែលបានធ្វើឡើងក្នុងឆ្នាំ២០១៦ បានរកឲ្យឃើញចំណុចខ្លាំង ចំណុចប្រឈម និងខ្វះខាតជាច្រើន ដែលចាំបាច់ត្រូវកែលម្អ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញផែនការសកម្មភាពក្នុងដំណាក់កាលទី២ (២០១៧-២០១៨) ដោយបានឆ្លើយតបទៅនឹងចំណុចខ្វះខាតទាំងឡាយដែលបានរកឃើញ ក្នុងរបាយការណ៍វាយតម្លៃ ពាក់កណ្តាលអណត្តិនៃផែនការ។

ជាលទ្ធផល ដែលសម្រេចបានក្នុងឆ្នាំ២០១៧នេះ មានដូចខាងក្រោម៖

ការអនុវត្តផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

ក .ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ក.១-ការងារបទដ្ឋានច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការដែលសម្រេចបាន៖

ក.១.១-សន្ធិសញ្ញា៖

ក្រសួងយុត្តិធម៌៖ បានចុះហត្ថលេខាលើសន្ធិសញ្ញា

- ស្តីពី "**បត្យាប័ន**" ចំនួន ០២ គឺ
  - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសរុស្ស៊ី នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧។
  - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសបារាំង។
- ស្តីពី "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" ចំនួន ០២ គឺ
  - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសវៀតណាម នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦។
  - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសរុស្ស៊ី។
- ស្តីពី "ការផ្ទេរទណ្ឌិត" ចំនួន ០២ គឺ
  - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសវៀតណាម។
  - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសរុស្ស៊ី។

ក.១.២-អនុស្សរណៈនៃការយោគយល់គ្នាដែលបានចុះហត្ថលេខាហើយ៖

- **ប្រមុខរដ្ឋ/ប្រមុខរដ្ឋាភិបាលអាស៊ាន** បានចុះហត្ថលេខា លើឯកច្ឆ័នភាពអាស៊ាន ស្តីពី "**ការការពារ និងការលើកកម្ពស់សិទ្ធិទេសន្តរប្រវេសន៍ការងារ**" ក្នុងកិច្ចប្រជុំកំពូលអាស៊ាន នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅប្រទេសហ្វីលីពីន។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះអនុស្សរណៈនៃការយោគយល់គ្នាចំនួន២គឺ៖
  - ✓ ស្តីពី "**កិច្ចសហប្រតិបត្តិការលើវិស័យការងារ (ជ្រើសរើស និងគ្រប់គ្រងពលករ)**" រវាងអគ្គនាយកដ្ឋាន នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា និងសមាគមអភិវឌ្ឍន៍ធនធានមនុស្ស នៅតំបន់រដ្ឋបាលពិសេសហុងកុង (ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧)។
  - ✓ ស្តីពី "**កិច្ចសហប្រតិបត្តិការលើវិស័យការងារ**" រវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារជនពិការ និងសង្គមកិច្ច នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម (ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧)។
- **ក្រសួងយុត្តិធម៌** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងចំនួន០២គឺ៖
  - ✓ ផែនការការងារសហប្រតិបត្តិការ ឆ្នាំ២០១៧-២០១៨ រវាងក្រសួងយុត្តិធម៌កម្ពុជា និងក្រសួងយុត្តិធម៌វៀតណាម (ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧)។
  - ✓ អនុស្សរណៈនៃការយោគយល់គ្នា រវៀងរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការកម្ពុជា និងបណ្ឌិត្យសភាតុលាការវៀតណាម (ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧)។

ក.១.៣-បទដ្ឋានជាតិ៖

- **រាជរដ្ឋាភិបាលកម្ពុជា** បានចេញអនុក្រឹត្យចំនួនពីរគឺ៖
  - ✓ អនុក្រឹត្យលេខ២៧៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពី "ប័ណ្ណព្រំដែនកម្ពុជា-ឡាវ"។
  - ✓ អនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ ស្តីពី "ការលុបចោល និងដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី" ដែលជនបរទេសកំពុងកាន់កាប់ប្រើប្រាស់។
- **ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចេញប្រកាសអន្តរក្រសួងលេខ៥១៨៨ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ស្តីពីនីតិវិធី និងបែបបទ នៃការចេញការដកហូត ការបដិសេធ លិខិត ធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស។
- **ក្រសួងមហាផ្ទៃ** បានចេញសេចក្តីជូនដំណឹងលេខ១០២៥ សជណ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីករណីពលករខ្មែរដែលអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីឲ្យអាជ្ញាធរខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ ទប់ស្កាត់ និងដោះស្រាយបញ្ហាខាងលើ ពិសេសការបង្កើតកិច្ចសហការផ្លាស់ប្តូរព័ត៌មាន អំពីការបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ ដោយស្នើឲ្យភាគីថៃយកចិត្តទុកដាក់លើការដឹកជញ្ជូន ការគោរពសិទ្ធិពលរដ្ឋ សុវត្ថិភាពសុខភាព និងស្បៀង អាហារ ឲ្យបានសមស្រប។ ទន្ទឹមនឹងនេះ ត្រូវបង្កើត

កិច្ចសហការស្រាវជ្រាវរកមេក្លោងដែលនាំ ពលករឆ្លងដែនខុសច្បាប់ ដើម្បីចាត់វិធានការឲ្យបានម៉ឺងម៉ាត់ស្របតាមច្បាប់ជាធរមាន។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានធ្វើលិខិតជូន**ក្រសួងព័ត៌មាន** លេខ១១១៣ កប/មហ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ស្តីពី សំណើសុំជួយទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានបំផ្លើសដើម្បីទប់ស្កាត់ការយល់ខុសរបស់ប្រជាពលរដ្ឋ នាំឲ្យចាញ់បោកមេខ្យល់ ឬក្រុមហ៊ុនមិនស្របច្បាប់។

ក.១.៤-លិខិតបទដ្ឋានរដ្ឋបាលសម្របសម្រួលការងារ ៖

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ ៖**
  - ចេញសេចក្តីសម្រេច លេខ០៧៧/១៧ សសរ ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការប្រគល់ភារកិច្ច ជូនលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និង ជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីដឹកនាំការងារគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍មិនប្រក្រតី តាមព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។
  - សេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមការងារកិច្ចការយុត្តិធម៌ លេខ០៣៧/១៧ ស.ស.រ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការតែងតាំងលោក **ពេញ វិបុល** អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ ជាសមាជិកបន្ថែមក្រុមការងារកិច្ចការយុត្តិធម៌របស់ គ.ជ.ប.ជ។
  - សេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមការងារការពារជនរងគ្រោះលេខ០៣៦/១៧ ស.ស.រ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការតែតាំង លោកស្រី **ព្រុំ សុខន** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសមាជិកបន្ថែមក្រុមការងារការពារជនរងគ្រោះ។
  - សេចក្តីសម្រេច លេខ១៦៨/១៧ សសរ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមការងារ ទទួលពលករ ពលការិនីខុសច្បាប់មកពីប្រទេសថៃ។
- **គណៈកម្មាធិការ គ.រ.ប.ជ និង គ.ខ.ប.ជ** បានកែសម្រួលសមាសភាពមន្ត្រីស្រុក និងមន្ត្រីឃុំ សង្កាត់ ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមមាន៖ រាជធានីភ្នំពេញ កណ្តាល ស្វាយរៀង ព្រៃវែង សៀមរាប កំពង់ធំ ព្រះសីហនុ កែប តាកែវ កំពង់ស្ពឺ មណ្ឌលគិរី បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តព្រះវិហារ។

ក.២-ច្បាប់ គោលនយោបាយ និងឯកសារកិច្ចសហប្រតិបត្តិការកំពុងរៀបចំ៖

ក.២.១-សេចក្តីព្រាងច្បាប់ដែលកំពុងរៀបចំ៖

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានដឹកនាំការធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**" ។
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA)
  - ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

ក.២.២-សន្ធិសញ្ញាកំពុងរៀបចំ៖

- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា ទ្វេភាគី៖
  - **ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"**
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង។
  - **ស្តីពី"បត្យាប័ន"**
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
  - **ស្តីពី "ការបញ្ជូនទណ្ឌិត"**
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលអង់គ្លេស
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ
    - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

ក.២.៣-អនុស្សរណៈកំពុងរៀបចំ៖

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសឥណ្ឌា ស្តីពី "**កិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស**" នៅដើមឆ្នាំ២០១៨។
- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយអង្គការអន្តរជាតិ GVC ស្តីពី "ការគាំទ្រ និងការតស៊ូមតិលើសិទ្ធិពលករទេសន្តប្រវេសន៍កម្ពុជាក្នុងប្រទេសថៃ" ដើម្បីទប់ស្កាត់ការរំលោភបំពានអំពើជួញដូរមនុស្ស។
- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការ Friends International ស្តីពី "ការអនុវត្តគម្រោងកុមារភាព" ។

ក.២.៤-បទដ្ឋានគតិយុត្តិ កំពុងរៀបចំ៖

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តលក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ**"។
- **ក្រសួងអប់រំ យុវជន និងកីឡា៖** ធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**"។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងអនុក្រឹត្យ ស្តីពី "របបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត" ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

ខ.ការបង្ការទប់ស្កាត់

អាស្រ័យដោយមានការប្រែប្រួលគោលនយោបាយក្នុងប្រទេសថៃ ក្នុងការរឹតបន្តឹងច្បាប់អន្តោប្រវេសន៍ និងច្បាប់ការងារថៃ ពលករកម្ពុជា ដែលមួយចំនួនធំ បានឆ្លងដែនចូលទៅធ្វើការដោយខុសច្បាប់ គ្មានឯកសារត្រឹមត្រូវ បានប្រឈមនឹងការបញ្ជូនត្រឡប់ ជាបន្តបន្ទាប់។

- **ក្រុមការងារនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** ដឹកនាំដោយលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចុះសិក្សា ពិនិត្យស្ថានភាពតាមច្រកព្រំដែន ក្នុងខេត្តបាត់ដំបង ប៉ៃលិន និងបន្ទាយមានជ័យ អំពីលំហូរមិនប្រក្រតីឆ្លងកាត់ព្រំដែន ដែលនាំឲ្យមានកំណើនពលករខុសច្បាប់នៅក្នុងប្រទេសថៃ និងពិនិត្យលទ្ធភាពក្នុងការរៀបចំសាងសង់មណ្ឌលសំចតបណ្តោះអាសន្ន សម្រាប់ទទួលពលករ ដែលត្រូវបានបញ្ជូនត្រឡប់ ឬវិលត្រឡប់ពីប្រទេសថៃ។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានធ្វើកិច្ចការជាច្រើន ដែលជាការងារទប់ស្កាត់ដោយប្រយោលនៃលំហូរពលកម្មចេញទៅក្រៅប្រទេស តាមរយៈការលើកកម្ពស់លក្ខខណ្ឌនៅកន្លែងធ្វើការងារឲ្យបានកាន់តែល្អប្រសើរដោយបានដំឡើងប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០១៧ ពីចំនួន**១៥៣**ដុល្លារអាមេរិក ទៅ**១៧០**ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨ ពិសេសសម្រាប់កម្មករផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើង ដោយមិនគិតបញ្ចូលពីប្រាក់កម្រៃផ្សេងៗទៀត។ ការអនុវត្តរបបសន្តិសុខសង្គម ដែលបច្ចុប្បន្នកំពុងអនុវត្តរបបគ្រោះថ្នាក់ការងារ របបថែទាំសុខភាព និងកំពុងរៀបចំដំណើរការរបបសោធននិវត្តន៍សម្រាប់កម្មករវិស័យឯកជន។ បានចូលរួមយ៉ាងសកម្មក្នុងការអប់រំណែនាំដល់កម្មករនិយោជិតអំពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ដើម្បីអប់រំពលរដ្ឋ និងកម្មករនិយោជិតឲ្យងាកមកមើលឃើញអំពីគុណប្រយោជន៍ជាចម្បងនាពេលបច្ចុប្បន្ន និងទៅអនាគត នៃការងារនៅក្នុងប្រទេស។
- **ក្រសួងអភិវឌ្ឍន៍ជនបទ** មានចក្ខុវិស័យរយៈពេលវែង "ជំរុញកំណើនសេដ្ឋកិច្ចជនបទឲ្យបានប្រហាក់ប្រហែលទីប្រជុំជននៅឆ្នាំ២០២៥" ដើម្បីជំរុញការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅជនបទ និងបានចូលរួមបង្ការ ទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងកិច្ចការពារជនងាយរងគ្រោះជាពិសេសស្ត្រី និងកុមារ តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សម្រាប់សម្រួលដល់ជីវភាព និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ នៅជនបទ និងបានបណ្តុះបណ្តាល បង្កើតការងារជាច្រើនសម្រាប់ប្រជាពលរដ្ឋនៅជនបទ។

ខ.១-ការគ្រប់គ្រងភ្នាក់ងារជ្រើសរើសពលករឯកជន ៖

❖ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានអនុញ្ញាតឲ្យក្រុមហ៊ុនឯកជនចំនួន**៨៥** ធ្វើការជ្រើសរើសបញ្ជូនពលករទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស និងតាមប្រព័ន្ធអនុគ្រោះមុខរបរ(EPS)របស់រដ្ឋាភិបាល បានចំនួន**៤៥.៧៩៧**នាក់ (ស្រី១៨.២៨០នាក់) ក្នុងនោះមាន៖

- ក្រុមហ៊ុនឯកជនចំនួន**៨៥**ក្រុមហ៊ុន បានធ្វើការជ្រើសរើស និងបញ្ជូនពលករទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស សរុបចំនួន**៣៨.១៣៦**នាក់ (ស្រីចំនួន**១៦.៤៨៣**នាក់) និងបានបញ្ជូនទៅប្រទេស៖
    - ទៅប្រទេសថៃឡង់ដ៍ ចំនួន**៣៥.៦៧៤**នាក់ (ស្រី**១៥.០៨០**នាក់)
    - ទៅប្រទេសជប៉ុន ចំនួន**២.២៨០**នាក់ (ស្រី**១.២៤១**នាក់)
    - ប្រទេសសិង្ហបូរី ចំនួន**១៣៨**នាក់(ស្រី)
    - ប្រទេសម៉ាឡេស៊ី ចំនួន**២៧**នាក់ (ស្រី**០៧**នាក់)

  - ប្រទេសអារ៉ាប់ប៊ីសាអូឌីត ចំនួន**១២**នាក់(ស្រី)
  - តំបន់រដ្ឋបាលពិសេសហុងកុង ចំនួន**០៥**នាក់(ស្រី)។
- រាជរដ្ឋាភិបាលបានបញ្ជូនពលករទៅធ្វើការនៅប្រទេសកូរ៉េតាមប្រព័ន្ធអនុគ្រោះមុខរបរ(EPS) ចំនួន **៧.៦៦១**នាក់ (ស្រី**១.៧៩៧**នាក់)។

ខ.២-កាត់បន្ថយនាពងគ្រោះដល់ជនមុខសញ្ញាគ្រោះ៖

ប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចំនួន**០៥** គឺប៉ុស្តិ៍ ច្រកប៉ោយប៉ែត ច្រកដូង ច្រកព្រំ ច្រកអូរស្មាច់ និងច្រកជាំ បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចំនួន **២០៤.០៩៣**ក្បាល ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន។ ក្រៅពីនោះយើងមានសកម្មភាព៖

- ខេត្តកំពង់ចាម ស្នងការដ្ឋាននគរបាល បានចលនាដល់បណ្តាញភ្នាក់ងាររឺម៉កកង់បីនិងម៉ូតូឌុប បិទស្លាក ដើម្បីសុវត្ថិភាពកុមារ បានចំនួន**៨៤**កន្លែង ព្រមទាំងបានបំពេញទម្រង់ពិនិត្យភ្នាក់ងារសុវត្ថិភាពកុមារ បានចំនួន**០៩**នាក់។
- ខេត្តព្រៃវែង មន្ទីរសង្គមកិច្ច សហការជាមួយអធិការដ្ឋាននគរបាលស្រុក និងប៉ុស្តិ៍នគរបាល បានចែកប័ណ្ណដែលមានលេខទូរស័ព្ទដល់ប្រជាពលរដ្ឋ ដើម្បីទំនាក់ទំនងមកសមត្ថកិច្ច ក្នុងការជួយសង្គ្រោះទាន់ពេល នៅពេលជួបបញ្ហាអសកម្ម ឬអំពើរំលោភបំពានផ្លូវភេទ និងអំពើជួញដូរមនុស្សជាដើម។

ខ.៣-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

- ✓ ឆ្នាំ២០១៧នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកម្មវិធីវេទិកាអន្តរសាសនាថ្នាក់ជាតិនៅកម្ពុជា ពិធីសូត្រធម៌ អធិដ្ឋាន និងបញ្ជូនសារ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ ដែលមានអ្នកចូលរួមប្រមាណ**១.២០០អង្គ/នាក់**។
- ✓ ដោយឡែកស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចសហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈដើម្បីអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" ដល់អាជ្ញាធរមូលដ្ឋាន សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន**៥២.៨៧៩**លើក មានអ្នកចូលរួមសរុបចំនួន**៤.៩៥៩.៩៣៨**នាក់ (ធៀបនឹងឆ្នាំ២០១៦ ដែលមានចំនួនត្រឹមតែ**៣.៧៤០.២១១**នាក់ ប៉ុណ្ណោះ គឺកើនឡើងចំនួន **១.២១៩.៧២៧**នាក់ ស្មើនឹង**៣២,៦១%** ក្នុងនោះស្ត្រីមានចំនួន**២.៣៦៣.៧៩១**នាក់)។ (ឧបសម្ព័ន្ធទី១)

ខ.៤-យុទ្ធនាការ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)** បានសហការជាមួយអង្គការដៃគូដូចជា៖ USAID, WINROCK, The Asia Foundation, UN-ACT, Terre des Hommes, IJM, IOM, APLE, Cambodia Acts...) ផលិតសម្ភារផ្សព្វផ្សាយអប់រំ ក្នុងកម្មវិធីយុទ្ធនាការនៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ ធ្នូ លើកទី១១ ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមប្រមាណ**៣.២៣២**នាក់ ជាថ្នាក់ដឹកនាំកំពូលសំខាន់ៗ ក្នុងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ តុលាការ អង្គទូតនានាដែលមាននិវេសនដ្ឋាននៅកម្ពុជា អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តំណាងផ្នែកសាសនា និយោជិត កម្មករ និយោជក សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ និងជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។
- លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចំនួន**១៧** គឺ៖ ខេត្តបាត់ដំបង ព្រៃវែង ព្រះវិហារ កំពត កំពង់ឆ្នាំង ពោធិ៍សាត់ ព្រះសីហនុ កណ្តាល បន្ទាយមានជ័យ មណ្ឌលគិរី ឧត្តរមានជ័យ កោះកុង សៀមរាប កំពង់ចាម កំពង់ធំ តាកែវ និងខេត្តស្វាយរៀង បានសហការជាមួយអង្គការដៃគូ រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ និងផលិតសម្ភារផ្សព្វផ្សាយអប់រំក្នុងយុទ្ធនាការ ដែលមានអ្នកចូលរួមជាថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋចំនួន**៥៣៥.៨៧៧**នាក់ (ស្រី**១០២.៩១៤**នាក់)។

ខ.៥-សកម្មភាពអប់រំតាមសាលារៀន

លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ចុះផ្សព្វផ្សាយការយល់ដឹង ស្តីពីការលើកកម្ពស់បរិស្ថានសិក្សា សមភាពយេនឌ័រ និងការប្រឆាំងអំពើជួញដូរមនុស្ស តាមសាលារៀន វិទ្យាល័យ អនុវិទ្យាល័យ សាលាគរុកោសល្យ មានលោកគ្រូ អ្នកគ្រូ និងសិស្សចូលរួមចំនួន**៨៩៤**នាក់ នៅក្នុងខេត្តចំនួន**០៦**គឺ ខេត្តកំពង់ឆ្នាំង កំពង់ចាម តាកែវ កណ្តាល បាត់ដំបង និងខេត្តព្រៃវែង។

- **ក្រសួងអប់រំ យុវជន និងកីឡា** បានពិនិត្យបញ្ចូលប្រធានបទពាក់ព័ន្ធនឹងការបង្ការ ទប់ស្កាត់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន ទូទាំងប្រទេស ដូចជា៖
  - មុខវិជ្ជាៈសិក្សាសង្គម សីលធម៌ និងពលរដ្ឋវិទ្យា នៅតាមកម្រិតបឋមសិក្សា បឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ និងមានការគ្រប់គ្រងវត្តមាន របស់សិស្សនៅកម្រិតសិក្សាចំណេះទូទៅច្បាស់លាស់
  - នៅតាមវិទ្យាល័យសាធារណៈ អនុវិទ្យាល័យ និងសាលារៀនឯកជនចំនួន**១.០៣៧**គ្រឹះស្ថានសិក្សា និងសកលវិទ្យាល័យចំនួន**១២** នៅទូទាំងប្រទេស បានសហការគ្នា រៀបចំធ្វើមីទ្ទិញផ្សព្វផ្សាយពីគោលនយោបាយប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការប្តេជ្ញាចូលរួមបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស

- **ក្រសួងធម្មការ និងសាសនា** បានបញ្រ្ជាបការយល់ដឹង សុជីវធម៌ គុណធម៌ សីលធម៌ តាមរយៈព្រះសង្ឃជាធម្មកថិកាចារ្យល្បីៗ ដែលមានទេពកោសល្យខ្ពស់ក្នុងការសំដែងធម្មទេសនាដោយផ្សារភ្ជាប់ព្រះពុទ្ធសាសនាទៅក្នុងសង្គម ដើម្បីលើកកម្ពស់ការយល់ដឹង និងពាក់ព័ន្ធ ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ចំនួន**៨៣អង្គ** និងមានការចូលរួមស្តាប់មកពីគ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំរដ្ឋ ឯកជន មហាជនជាពុទ្ធបរិស័ទចំនួន **៤.៤៨៣**នាក់ និងព្រះសង្ឃចំនួន**៥៣៤អង្គ** នៅតាមបណ្តារាជធានី-ខេត្ត។

ខ.៦-ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសម្ភារៈ

- **អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ៖**
  - បានសហការជាមួយទូរទស្សន៍ PNN និងទូរទស្សន៍បាយ័ន ផលិត បទយកការណ៍ ដើម្បីចាក់ផ្សាយ ក្នុងកម្មវិធីយុទ្ធនាការទិវាជាតិ ១២ធ្នូ ២០១៧។
  - បានចូលរួមក្នុងកម្មវិធីការងារ និងជីវិត ជាវាគ្មិនវិទ្យុ VOD ផ្សាយផ្ទាល់ពិភាក្សា ប្រធានបទ "**ស្រ្តីបម្រើសេវាកម្សាន្តស្នើឲ្យមានច្បាប់ការពារ**" នៅស្ថានីយវិទ្យុសារិកា FM106.5MHz។
  - ចូលរួមធ្វើជាវាគ្មិនបណ្តុះបណ្តាល ច្បាប់ស្តីពី៖
    - ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។
    - ការផ្តល់ព័ត៌មានសម្ភាសលើការសិក្សាស្រាវជ្រាវអំពីដំណើរការរីកចម្រើន និងស្ថានភាពសិទ្ធិកុមារនៅកម្ពុជា។
  - ចូលរួមសិក្ខាសាលាពិភាក្សា និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីជំនួយទៅវិញទៅមក ផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។
- **ក្រសួងកិច្ចការនារី** បានចូលរួមជាវាគ្មិន ក្នុងកិច្ចសន្ទនា តាមទូរទស្សន៍ជាតិកម្ពុជាចំនួន**០១**លើក ស្តីពីការលើកកម្ពស់ការទទួលបានសិទ្ធិ និងកិច្ចគាំពារកុមារបន្ទាល់ទី (រៀបចំដោយ Cambodia ACTs)។
- **ក្រសួងធម្មការ និងសាសនា** បានផលិត DVCamsចំនួន**១.០១២ដុំ** និងCD សម្លេងចំនួន**៧៧០បន្ទះ** ស្តីពីផលប៉ះពាល់នៃការជួញដូរមនុស្ស ហើយត្រូវចាក់ផ្សាយតាមវិទ្យុ ចំនួន**២៣**ស្ថានីយ៍ និងតាមទូរទស្សន៍ ចំនួន២៣ស្ថានីយ៍។
- <u>**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ៖**</u>
  - សហការជាមួយផលិតកម្មភាពយន្ត និងក្រុមហ៊ុននាំចូលខ្សែភាពយន្ត ឲ្យបញ្ចូលសារអប់រំស្តីពីផលប៉ះពាល់នៃការជួញដូរមនុស្ស ការកេងប្រវ័ញ្ចលើកម្លាំងពលកម្មកុមារ និងការជួញដូរផ្លូវភេទក្នុងផលិតផលខ្សែភាពយន្ត ចម្រៀងកាយវិកា និងខារ៉ាអូខេ។
  - ផលិតស្នាដៃល្ខោននិយាយខ្លីជាវីឌីអូ ជូនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្តីពីគ្រោះថ្នាក់នៃការជួញដូរមនុស្ស ការកេងប្រវ័ញ្ចលើ កម្លាំងពលកម្មកុមារ បានចំនួនពីរចំណងជើងគឺ(១)វិលវិញ និង(២)ខ្ញុំខុសរហូត។
  - សម្តែងសិល្បៈជាឈុតល្ខោននិយាយខ្លី ស្តីពីគ្រោះថ្នាក់នៃការជួញដូរមនុស្ស៖

- ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ និងបុណ្យអុំទូក អកអំបុកសំពះព្រះខែ ដល់ប្រជាពលរដ្ឋ មន្ត្រីរាជការ និងសិស្សានុសិស្ស ដែលបានចូលរួមប្រមាណជាង៦០០នាក់។
- ក្នុងឱកាសទិវាជាតិ១២ធ្នូ លើកទី១១ ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ

  ○ នាយកដ្ឋានភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ បានផលិតស្នាដៃភាពយន្តវីដេអូចំនួន០៣ស្នាដៃ ស្តីពីគ្រោះថ្នាក់នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្មកុមារ។

- **លេខាធិការដ្ឋានគ.ខ.ប.ជ** បានផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមប៉ុស្តិ៍វិទ្យុ ចំនួន**២២៦**លើក មានខេត្តកោះកុង**១៥៨**លើក, សៀមរាប**២៨**លើក, កំពង់ចាម**០៣**លើក បាត់ដំបង**២៦**លើក ក្រចេះ**០២**លើក និងកំពត**០៩**លើក។
- **ខេត្តប៉ៃលិន** បានបិទផ្សព្វផ្សាយខ្លឹមសារច្បាប់ និងសេចក្តីណែនាំលេខ០៤៥ ស.ណ.ន ទាក់ទងនឹងអំពើជួញដូរមនុស្ស តាមគោលដៅចំនួន៨៩កន្លែង។
- **ខេត្តកំពត** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានចែកឌីស និងបញ្ចាំងវីដេអូអប់រំ ផ្សព្វផ្សាយផលប៉ះពាល់នៃការធ្វើចំណាកស្រុក ស្តីពី"**ជើងមេឃនៅឯណា**" បានចំនួន៤០០ឌីសតាមបណ្តាស្រុកទូទាំងខេត្ត សរុបបានចំនួន**១.២០០**ដង មានអ្នកចូលរួមសរុបចំនួន**៦០.០០០**នាក់ ស្រី**២២.៤០០**នាក់។
- **ខេត្តកំពង់ស្ពឺ** បានផលិតបដា ពាក្យស្លោក ដែលមានខ្លឹមសារ "វិធានការច្បាប់ប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស" ចងនៅខាងមុខមន្ទីរ អង្គភាព ស្ថាប័នពាក់ព័ន្ធ និងនៅតាមវិទ្យាល័យនានាទូទាំងខេត្ត ចំនួន០៤លើក លើទីតាំង**១៧**កន្លែង ស្មើនឹង**៥៤**បដា។
- **ខេត្តបាត់ដំបង៖**

  ○ លេខាធិការដ្ឋាន គ.ខ.ប.ជ បានចុះចែកខិត្តប័ណ្ណផ្សព្វផ្សាយ ដល់ពលករចំណាកស្រុកនៅតាមច្រកព្រំដែនកម្ពុជា-ថៃ ចំនួន**១.០០០**សន្លឹក។

  ○ មជ្ឈមណ្ឌលព័ត៌មានទីផ្សារការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ចំនួន**១.៤៤៣**សន្លឹក។

  ○ អង្គការ Samaritan Purse បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយដល់ពលករចំណាកស្រុកចំនួន**២.៧៩០**នាក់ ស្រី**១.០៤១**នាក់ ដែលបញ្ជូនត្រឡប់មកខេត្តបាត់ដំបងវិញ នៅតាមព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

- **ខេត្តកំពង់ចាម អង្គការចាប់ដៃ** បានធ្វើការជ្រើសរើសអ្នកតាមដានស្តាប់កម្មវិធីវិទ្យុ និងចែកខិត្តប័ណ្ណជំនួយ**៥០០**សន្លឹក ដល់ប្រជាពលរដ្ឋ។

ខ.៧-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស

ខ.៧.១-វិធានការទប់ស្កាត់តាមជំនាញរបស់អគ្គស្នងការនគរបាលជាតិ៖

កងកម្លាំងនគរបាល វរៈការពារព្រំដែនគោក និងនគរបាលប៉ុស្តិ៍ តាមបណ្តាច្រករបៀងនៅខេត្តជាប់ព្រំដែនកម្ពុជា-ថៃ បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរបម្រុងធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃ ដោយមិនស្របច្បាប់ ឬតាមរយៈមេខ្យល់។ ក្រោយពីពេលធ្វើការសាកសួរ អប់រំ ណែនាំ និងបានធ្វើកិច្ចសន្យារួចហើយ កម្លាំងជំនាញបានណែនាំឲ្យពួកគាត់វិលទៅរកលំនៅដ្ឋានវិញ មានដូចតារាងខាងក្រោម ៖

តារាងសកម្មភាពបង្ការ និងទប់ស្កាត់

ល.រ	ឈ្មោះអង្គភាព និង លេខាធិការដ្ឋាន គ.ខ.ប.ជ	សកម្មភាពទប់ស្កាត់	ចំនួនលើក	ចំនួនរួម	ស្រី	អនីតិជន
១	អគ្គបញ្ជាការដ្ឋាន ទីចាត់ការព្រំដែន	- បានធ្វើការបង្ការ ទប់ស្កាត់សកម្មភាពឆ្លងដែនខុសច្បាប់របស់ពលករខ្មែរដែលធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ។	០២	២១		
២	ខេត្តបន្ទាយមានជ័យ	- កម្លាំងនគរបាលប៉ុស្តិ៍គោករមៀត ប៉ុស្តិ៍អូរពាជាន់ និង វរៈនគរបាលការពារព្រំដែនគោកលេខ៩១១ និង៨០៧ បានទប់ស្កាត់ពលករខ្មែរធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ។	២១	៦៨៧	២៥៣	៤៩
៣	ខេត្តបាត់ដំបង	- វរៈនគរបាលការពារព្រំដែនគោកលេខ៨៧៣ ៨១៩ ៨២៣ និង៣១០ បានទប់ស្កាត់ពលករខ្មែរ ដែលធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ។	០៥	១៤៩	៥៧	៣៤
៤	ខេត្តប៉ៃលិន	- បានទប់ស្កាត់ប្រជាពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ នៅចំណុចផ្សារព្រំជាប់ព្រំដែន។	០១	៥៨	២៦	០៥
៥	ខេត្តព្រះវិហារ	- ស្នងការដ្ឋាននគរបាលខេត្ត បានធ្វើការបង្ការ ទប់ស្កាត់ពលករខ្មែរដែលធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ។	០១	២៨		
សរុប			៣០	៩៤៣	៣៣៦	៨៨

ខ.៧.២-វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖

ក្រុមការងារអនុវត្តន៍ច្បាប់៖ ឆ្នាំ២០១៧នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផល ៖

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត៖ ពោធិ៍សាត់ ស្ទឹងត្រែង កែប ឧត្តរមានជ័យ មណ្ឌលគិរី រតនគិរី និងខេត្តព្រះវិហារ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញាកម្ម និងបានផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន**១៩៦**គោលដៅ មានមនុស្សចំនួន**១.៥៨៨**នាក់ (ស្រី**១.៣៤០**នាក់)។
- បានកំណត់គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្សចំនួន**០៩**គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន**៦៦**គោលដៅ សរុបចំនួន**៧៥**គោលដៅ ទូទាំងរាជធានី-ខេត្ត។
- ខេត្តសៀមរាប ព្រៃវែង ឧត្តរមានជ័យ ស្វាយរៀង ពោធិ៍សាត់ កំពង់ធំ និងខេត្តកំពង់ស្ពឺ បានធ្វើការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន**៣២៥**លើក។
- ខេត្តព្រះសីហនុ ស្នងការដ្ឋាននគរបាល និងអង្គការម្លប់តាប៉ាង បានចុះចលនាដាក់បណ្តាញភ្នាក់ងារចំនួន**៦៣៣**នាក់ ដើម្បីធ្វើការពាក់ព័ន្ធសុវត្ថិភាពកុមារ លើក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បី បណ្តាញសហគមន៍ បណ្តាញអ្នកលក់តាមឆ្នេរសមុទ្រ បុគ្គលិកតាមផ្ទះសំណាក់ និងសណ្ឋាគារ។

ខ.៨-គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់

ខ.៨.១-វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក៖

បច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស ប្រចាំខែនីមួយៗ បានពិនិត្យឃើញថា នៅតែបន្តកើតមាន ជាក់ស្តែងឆ្នាំ២០១៧នេះ តួលេខមានដូចក្នុងតារាងខាងក្រោម៖

តារាងតាមដានបច្ចុប្បន្នភាពទិន្នន័យពលករខ្មែរចំណាកស្រុក ប្រចាំខែនីមួយៗ ក្នុងឆ្នាំ២០១៧

ប្រចាំខែ	សរុបរួម				ស្របច្បាប់				មិនស្របច្បាប់				សម្គាល់
	សរុប	ស្រី	អនីតិជន		សរុប	ស្រី	អនីតិជន		សរុប	ស្រី	អនីតិជន		
			សរុប	ស្រី			សរុប	ស្រី			សរុប	ស្រី	
មករា	៣២០.៤៣៧	១៤៤.៩៣៩	៨.៤៦៩	៣.៣០៤	១៧៩.៥៧២	៨៧.៥១៩	៦៨៨	២៧៧	១៤០.៨៦៥	៥៧.៤២០	៧.៧៨១	៣.០២៧	កើន ១.៩០៤
កុម្ភៈ	៣១៩.២៤៧	១៤០.២០១	៧.៩៦៥	៣.០៥៤	១៧៩.៨៣១	៨៣.៦៥៥	៥៨៩	២៤៤	១៣៩.៤១៦	៥៦.៥៤៦	៧.៣៧៦	២.៨១០	ថយចុះ ១.១៩០
មីនា	៣២១.១៥៩	១៤០.៥០៧	៧.៨៩៤	៣.០១៤	១៨០.៧១២	៨៣.៨១៦	៥៨៩	២៤៤	១៤០.៤៤៧	៥៦.៦៩១	៧.៣០៥	២.៧៧០	កើន ១.៩១២
មេសា	៣២៣.៨១៨	១៤០.០០២	៨.៦៤៤	៣.៤៤៤	១៨៣.៩០៤	៨៣.៨៣៩	១.៣០៨	៥៧៧	១៣៩.៩១៤	៥៦.១៦៣	៧.៣៣៦	២.៨៦៧	កើន ២.៦៥៩
ឧសភា	៣២៣.៦២៨	១៣៩.៩៤៧	៨.៧២៤	៣.៤៨១	១៨៤.៣៣៧	៨៤.២៥០	១.៣០១	៥៧៧	១៣៩.២៩១	៥៥.៦៩៧	៧.៤២៣	២.៩០៤	ថយចុះ ១៩០
មិថុនា	៣៣០.២៦៧	១៧០.៥៨៦	៨.៧៣៤	៣.២២៩	១៨៦.០៩០	៨៥.០៤៩	៥៩៧	២៤៧	១៤៤.១៧៧	៨៥.៥៣៧	៨.១៣៧	២.៩៨២	កើន ៦.៦៣៩
កក្កដា	៣២៦.៧៩៩	១៤១.០៦៧	៩.១០២	៣.៤៣២	១៨៦.២៧៨	៨៤.៣៦០	១.២០៧	៥៥៣	១៤០.៥២១	៥៦.៧០៧	៧.៨៩៥	២.៨៧៩	ថយចុះ ៣.៤៦៨
សីហា	៣២៧.៦៣៨	១៤១.៧៩៤	៩.១០២	៣.៣៩៨	១៨៦.៨២៨	៨៤.៩៨១	១.២២៣	៥៦០	១៤០.៨១០	៥៦.៨១៣	៧.៨៧៩	២.៨៣៨	កើនឡើង ៨៣៩
កញ្ញា	៣១៧.១៨២	១៤២.២៥៤	៩.០៧៤	៣.៤២១	១៧៥.៤៩៧	៨៥.៣៣២	១.១៨១	៥៥០	១៤១.៦៨៥	៥៦.៩២២	៧.៨៩៣	២.៨៦៧	ថយចុះ ១០.៤៥៦
តុលា	៣១៥.៥៦១	១៤១.៣១៨	៩.០៧១	៣.៤២៨	១៧៤.៧៦៨	៨៤.៨៤២	១.១៩១	៥៥៩	១៤០.៧៩៣	៥៦៤៧៦	៧.៨៨០	២.៨៦៩	ថយចុះ ១.៦២១
វិច្ឆកា	៣២០.៩៥១	១៤០.៦២០	៨.៩៥៩	៣.៣៧៣	១៧៨.៨៩៣	៨៣.៨៣៦	១.១៤០	៥២៤	១៤២.០៥៨	៥៦.៧៨៤	៧.៨១៩	២.៨៤៩	កើនឡើង ៥.៣៩០
ធ្នូ	៣២១.៥៩៧	១៤១.៧១២	៩.០១៩	៣.៣៧៤	១៧៩.២២៤	៨៤.៧៦០	១.១៨០	៥២៤	១៤២.៣៧៣	៥៦.៩៥២	៧.៨៣៩	២.៨៥០	កើនឡើង ៦៤៦

ប្រៀបធៀបពលករចំណាកស្រុក ឆ្នាំ២០១៦ និងឆ្នាំ២០១៧

ប្រចាំខែ	ឆ្នាំ២០១៦				ឆ្នាំ២០១៧			
	ចំនួនរួម	ស្រី	អនីតិជន		ចំនួនរួម	ស្រី	អនីតិជន	
			សរុប	សរុប			សរុប	ស្រី
មករា	៤៩០.៤០៧	២១៧.០៣១	១២.០០៣	៤.៥៨០	៣២០.៤៣៧	១៤៤.៩៣៩	៨.៤៦៩	៣.៣០៤
កុម្ភៈ	មិនមានរបាយការណ៍				៣១៩.២៤៧	១៤០.២០១	៧.៩៦៥	៣.០៥៤
មីនា	២៩៧.៤៩៦	១៣០.១៩០	៣.៣៦៦	២.០៣២	៣២១.១៥៩	១៤០.៥០៧	៧.៨៩៤	៣.០១៤
មេសា	២៩១.០៨៤	៦១.៩០៩	៦.០៧០	២.៣៩១	៣២៣.៨១៨	១៤០.០០២	៨.៦៤៤	៣.៤៤៤
ឧសភា	២៩០.៧២៤	១២៨,៩៦៧	៥,៦៦៤	២.២៤០	៣២៣.៦២៨	១៣៩.៩៤៧	៨.៧២៤	៣.៤៨១
មិថុនា	២៩៩.២៥៤	១៣០.២០២	៥.៨១៧	២.២៦២	៣៣០.២៦៧	១៧០.៥៨៦	៨.៧៣៤	៣.២២៩
កក្កដា	៣០១.៨០៦	១៣៧.៥០០	៥.៧៥១	២.២២៥	៣២៦.៧៩៩	១៤១.០៦៧	៩.១០២	៣.៤៣២
សីហា	៣០២.២៩៥	១៣៦.៧៦២	៥.៨១៣	២.២៤៧	៣២៧.៦៣៨	១៤១.៧៩៤	៩.១០២	៣.៣៩៨
កញ្ញា	៣០៩.០៥៦	១៤១.៦២១	៥.៧៣៥	២.២៣០	៣១៧.១៨២	១៤២.២៥៤	៩.០៧៤	៣.៤២១
តុលា	៣១៣.២៨៥	១៤១.៦៩៥	៦.២០៨	២.៣៦៩	៣១៥.៥៦១	១៤១.៣១៨	៩.០៧១	៣.៤២៨
វិច្ឆិកា	៣១៥.៦៦៩	១៤២.៨៩៨	៦.២៧០	២.៣៩៨	៣២០.៩៥១	១៤០.៦២០	៨.៩៥៩	៣.៣៧៣
ធ្នូ	៣១៨.៩៣៣	១៤៣.៦០០	៦.២៩១	២.៤០៣	៣២១.៥៩៧	១៤១.៧១២	៩.០១៩	៣.៣៧៤

ខ.៨.២-ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន៖

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍អន្តោប្រវេសន៍៖ អាជ្ញាធរបរទេសចំនួន១៨ប្រទេស បានបញ្ជូនពលរដ្ឋខ្មែរត្រឡប់មកវិញចំនួន**១២៣.៥៦១**នាក់ ស្រី **៤៥.៩៨៥**នាក់ និងកុមារ **៧.៨៨១**នាក់ (ក្នុងនោះពីប្រទេសថៃ**១២២.៦៣០**នាក់ កូរ៉េខាងត្បូង **៣២៣**នាក់ ម៉ាឡេស៊ី**២៨៩**នាក់ វៀតណាម **៨៦**នាក់ សឹង្ហបុរី**៣៨**នាក់ ជប៉ុន**២៦**នាក់ ឥណ្ឌូនេស៊ី**២០**នាក់ ចិន**៦៨**នាក់)។

ស្ថានភាព ៖

- ❖ ក្រុមអនុវត្តច្បាប់៖ មានពលរដ្ឋខ្មែរចំនួន**៥.១០៨**នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ និងឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។
- ❖អគ្គបញ្ជាការដ្ឋានកិច្ចការព្រំដែន នៃក្រសួងការពារជាតិ ៖
  - ○ បានទទួល និងសម្ភាសន៍ពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនមកវិញតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃចំនួន **២៧.៦៤០**នាក់ ស្រី **៩.៦៧០**នាក់ អនីតិជន **២.៨១២**នាក់។
  - ○ **បានទទួល សព ពលរដ្ឋខ្មែរពីអាជ្ញាធរថៃចំនួន២០៦លើក សរុបចំនួន២១១សព(ស្រី៤៣សព)**
- ❖ ខេត្តបន្ទាយមានជ័យ៖ អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព «**និរទេស**» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន**១.៦៥៧**ជើងរថយន្ត សរុបមានមនុស្សចំនួន **៧៣.២៧៥**នាក់ ស្រី**២៥.៥៨០**នាក់ ក្នុងនោះកុមារ**៧.៣២៩**នាក់ កុមារី**៣.៨៧៧**នាក់ (បើប្រៀបធៀបនឹងឆ្នាំ២០១៦ មានចំនួនតែ**៣៩.៩៨៧**នាក់ កើនឡើងចំនួន**៣៣.២៨៨**នាក់ ស្មើ**៨៣,២៤%**)។
  - ○ ចេញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានចំនួន**២៨.៤០៥**នាក់ ។
  - ○ តាមច្រករបៀងមានចំនួន**៤៤.៨៧០**នាក់ (ចេញដោយខ្លួនឯងចំនួន**៣២.៦៧៦**នាក់ និងតាមគេនាំ ចំនួន**៤០.៥៩៩**នាក់ ក្នុងនោះកុមារចំនួន**១.០៣៥**នាក់ កុមារីចំនួន**៣៧៣**នាក់។ តាមការសម្ភាសន៍ កុមារបានទៅតាមឪពុកម្តាយមានចំនួន **៦៩១**នាក់ និងទៅតាមបងប្អូន ឬអ្នកជិតខាង **៣៤១**នាក់ ។
- ❖ ខេត្តបាត់ដំបង បានទទួលពលករខ្មែរដែលអាជ្ញាថៃបញ្ជូនត្រឡប់មកវិញ ចំនួន**៩៨៧**លើក មនុស្សចំនួន **៥៦.៧២០**នាក់ ស្រី **២២.២៥០**នាក់(កុមារសរុប **៨៩៥**នាក់មានកុមារី **១៩៩**នាក់)
- ❖ ខេត្តប៉ៃលិន បានទទួលពលករខ្មែរដែលអាជ្ញាថៃបញ្ជូនត្រឡប់មកវិញ បានចំនួន**១.២៤៦**នាក់ មានស្រី**៥១៧**នាក់។

ខ.៨.៣- ការត្រួតពិនិត្យពលករបរទេសខុសច្បាប់ចូលមកកម្ពុជា៖

ការវិនិយោគរបស់វិស័យឯកជន លើវិស័យសហគ្រាស និងគ្រឹះស្ថាននានានៅតាមបណ្តា រាជធានី-ខេត្ត មានចំនួន សរុប២.១៥២ក្រុមហ៊ុន លើវិស័យធំៗ ចំនួន០៤ គឺវិស័យ៖ រោងចក្រសហគ្រាសចំនួន១.៦៧០ក្រុមហ៊ុន, វិស័យកសិកម្មចំនួន១៩៣ក្រុមហ៊ុន វិស័យទេសចរណ៍ចំនួន១៥៨ក្រុមហ៊ុន និងវិស័យហេដ្ឋារចនាសម្ព័ន្ធចំនួន១៣១ក្រុមហ៊ុន ។

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានរកឃើញ ជនបរទេសដែលមកធ្វើការដោយខុសច្បាប់នៅតាមបណ្តារោងចក្រសហគ្រាសទាំងនោះ និងមានវិធានការដូចខាងក្រោម៖

១-ពិនិត្យបទល្មើសស្នាក់នៅខុសច្បាប់ចំនួន២៨៧លើក មានមនុស្សចំនួន១.១០៣នាក់:

- ពិនិត្យ១២៥លើកៈ មានមនុស្សចំនួន៩៤១នាក់ ស្នាក់នៅគ្មានលិខិតស្នាម និងធ្វើការខុសច្បាប់ មានសញ្ជាតិៈ វៀតណាម៨៧៨នាក់ នីហ្សេរីយ៉ា២០នាក់ កូរ៉េខាងត្បូង៧នាក់ អង់គ្លេស៧នាក់ ឥណ្ឌា៦នាក់ អាមេរិក៤នាក់ រុស្ស៊ី៣នាក់ សឹង្ហបុរី២នាក់ ចិន២នាក់ ហ្វីលីពីន១នាក់ កូឡុំប៊ី ១នាក់ ជប៉ុន១នាក់ ហ្គាណា១នាក់ រ៉ូម៉ានី១នាក់ ថៃ១នាក់ កាណាដា១នាក់ អ៊ុយក្រែន១នាក់ បារាំង១នាក់ ទួរគី១នាក់ និងនេបាល់១នាក់។
- ពិនិត្យ១៦២លើកៈ មានមនុស្សចំនួន១៦២នាក់ ស្នាក់នៅលើសទិដ្ឋាការ មានសញ្ជាតិៈ នីហ្សេរីយ៉ា១០៣នាក់ ឥណ្ឌា១០នាក់ ចិន៧នាក់ ហ្វីលីពីន៥នាក់ បារាំង៥នាក់ កូរ៉េខាងត្បូង៤នាក់ រុស្ស៊ី៣នាក់ អង់គ្លេស៣នាក់ អាមេរិក៣នាក់ អាហ្វ្រិកខាងត្បូង២នាក់ បេឡារ៉ុស ១នាក់ អ៊ីតាលី១នាក់ បាឡេស្ទីន១នាក់ អូស្ត្រាលី១នាក់ ប៊ូតាន់១នាក់ បែលហ្ស៊ិក១នាក់ នេប៉ាល់ ១នាក់ កាណាដា១នាក់ ហូឡង់១នាក់ ចរដៀ១នាក់ កូឡុំប៊ី១នាក់ កុងហ្គោ១នាក់ ហ្គាណា១នាក់ បង់ក្លាដែស១នាក់ និងស្លូវ៉ាគី១នាក់។

២-ការងារត្រួតពិនិត្យហត្ថពលករបរទេសៈ ក្រុមការងារចម្រុះអធិការកិច្ចហត្ថពលកម្មបរទេស បានចុះត្រួតពិនិត្យសហគ្រាស គ្រឹះស្ថានតាមបណ្តារាជធានី-ខេត្ត ចំនួន៣.៩៦៩គោលដៅ រកឃើញមានពលករបរទេសសរុបចំនួន៣២.៥១២នាក់ សរុបមាន៩៣សញ្ជាតិ។ ជនបរទេសប្រកបមុខរបរ និងបម្រើការងារគ្មានប័ណ្ណការងារចំនួន១.៣៨៩នាក់ បានធ្វើការផាកពិន័យតាមច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជា គិតជាប្រាក់ស្មើនឹង ៦៩៤.៥០០.០០០រៀល។

៣-ការងារអនុវត្តនីតិវិធី ចំពោះជនបរទេសខុសច្បាប់ៈ បានឃាត់ខ្លួន និងបណ្តេញចេញជនបរទេសខុសច្បាប់ សរុបចំនួន១.៨៨៥នាក់ មាន៤៧សញ្ជាតិៈ

ក្នុងនោះ មានជនជាតិវៀតណាម៩១៧នាក់ ចិន៥៩៨នាក់ នីហ្សេរីយ៉ា១៥៥នាក់ ឥណ្ឌា៣១នាក់ តៃវ៉ាន់៣១នាក់ កូរ៉េខាងត្បូង១៥នាក់ អង់គ្លេស១៤នាក់ អាមេរិក១៣នាក់ ហ្វីលីពីន១២នាក់ និងចាត់វិធានការ

- បណ្តេញចេញតាមប្រកាសរបស់ក្រសួងមហាផ្ទៃ ចំនួន១.៧១៩នាក់ មាន៤៤សញ្ជាតិ។
- បានទប់ស្កាត់ការចូលដោយខុសច្បាប់ ដោយការិយាល័យអន្តោប្រវេសន៍នៃស្នងការដ្ឋាននគរបាលខេត្តជាប់ព្រំដែន ដោយបណ្តេញ ចេញ ចំនួន១៦៦នាក់ មានសញ្ជាតិវៀតណាម ១៥៥នាក់ និងថៃ០១នាក់។

ខ.៩-ដំណោះស្រាយផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជានៅក្រៅប្រទេស

ប្រាយការណ៍ របស់ប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា លេខ ០១៤/១៧ គ.ផ.ថ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១៧ បានឲ្យដឹងថាៈ

- ជំរឿនលើកទី១ ក្នុងខែតុលាឆ្នាំ២០១៤ និងជំរឿនលើកទី២ក្នុងខែកញ្ញាឆ្នាំ២០១៦ភាគីថៃបានផ្តល់ប័ណ្ណស៊ីជម្ពូដល់ពលករកម្ពុជា ចំនួន១.០៤៤.១១៥នាក់ (ក្នុងនោះពលករដែលមាននៅក្នុងប្រទេសថៃមានចំនួន៤១,៣៥៨នាក់) និងពលករកម្ពុជាផ្នែកនេសាទចំនួនប្រមាណជា៤៧.០០០នាក់ (ដែលនឹងផុតសុពលភាពប័ណ្ណ ពណ៌ស៊ីជម្ពូ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧) ។ សម្រាប់អ្នកចុះបញ្ជីថ្មី

និងអ្នកដែលសុំផ្លាស់ប្តូរកន្លែងការងារ ឬប្តូរថៅកែ ថៃទុកពេលមួយខែ តែត្រូវបង់បន្ថែមប្រមាណពី **១.០០០**បាត ទៅ**២.០០០**បាតទៀត។

- គិតត្រឹមខែមេសាឆ្នាំ២០១៧ ពលករកម្ពុជាដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ទាំងអ្នកស្របច្បាប់ អ្នកស្របច្បាប់បណ្តោះអាសន្ន និងអ្នកខុសច្បាប់ ដែលទើបឆ្លងទៅប្រទេសថៃក្រោយការធ្វើជំរឿនរបស់ភាគីថៃ ឃើញមានពលករសរុបចំនួន**១.០៥៦.៣៥៨**នាក់ (ស្រីចំនួន**៤២០.០០០**នាក់) និងអ្នកដែលបានចូលនិងស្នាក់នៅធ្វើកាងារខុសច្បាប់គ្មានឯកសារមានចំនួន **៣១០.០០០**នាក់(ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)។
- គិតចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧នេះ គណៈកម្មការផ្តល់ភាពស្របច្បាប់ បានបើកផ្តល់សំណុំលិខិតផ្តល់ភាពស្របច្បាប់ ដល់ពលករបានចំនួន **៣២៥.១៩៩**នាក់ ក្នុងនោះមានលិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាធ្វើការនៅបរទេស (OCWC)។ <u>សូមបញ្ជាក់ថា</u> កន្លងមកមូលហេតុយឺតយ៉ាវដោយសារដំណាក់កាលទី១ ភាគីថៃ បើកដំណើរការផ្តល់សំណុំលិខិតតាមច្រកចេញចូលតែមួយនៅទូទាំងប្រទេសថៃ <u>តែមួយកន្លែងគត់</u>(ក្នុងខេត្តសាមុតប្រាកាន)។ <u>តែបច្ចុប្បន្នភាគីថៃ</u> បើកដំណើរការផ្តល់សំណុំលិខិតតាមខេត្តចំនួន**០៣**ទៀត ហើយអាចបំពេញសំណុំលិខិតផ្តល់ភាពស្របច្បាប់នេះតាមប្រព័ន្ធអនឡាញក៏បាន និងអាចមកស្ថានទូតខ្មែរប្រចាំទីក្រុងបាងកកក៏បាន។
- ពីឆ្នាំ២០១៤-ឆ្នាំ២០១៧ ក្រសួងមហាផ្ទៃ បានផ្តល់លិខិតឆ្លងដែនដល់ពលរដ្ឋខ្មែរប្រមាណ **១.០៨២.៩១៦**នាក់ និងលិខិតធ្វើដំណើរជូនពលករកម្ពុជាទៅធ្វើការនៅបរទេសចំនួន**៣៩៧. ៨៣៨**នាក់។ ក្នុងឆ្នាំ ២០១៧ បានកែសម្រួលលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ដើម្បីកាត់បន្ថយបែបបទនីតិវិធីសាំញ៉ាំដោយបើកច្រកចេញចូលតែមួយចំនួន៣កន្លែងគឺ នៅផ្សារទំនើបស្ទឹងមានជ័យថ្មី ខេត្តបាត់ដំបង និងក្រុងប៉ោយប៉ែត និងកំពុងរៀបចំបើកបន្ថែមកន្លែងផ្តល់លិខិតឆ្លងដែន៤កន្លែងទៀត នៅខេត្តបាត់ដំបង បន្ទាយមានជ័យ កោះកុង និងផ្សារអ៊ីអនទី២។

ខ.១០-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសចំនួន**១.៤១៣**គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់ទៅនារីខ្មែរចំនួន**៤០**នាក់ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេស ដើម្បីធ្វើការតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

ខ.១១-ការចុះអធិការកិច្ចដើម្បីការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះធ្វើអធិការកិច្ចការងារលើសហគ្រាស គ្រឹះស្ថាន ដើម្បីពិនិត្យលក្ខខណ្ឌការងារ របស់កម្មករវ័យក្មេង ទប់ស្កាត់ពលកម្មកុមារ ចាត់វិធានការចំពោះសហគ្រាស គ្រឹះស្ថានដែលប្រព្រឹត្តល្មើសច្បាប់ និងបានដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរ ចំនួន**២៤០**នាក់ កុមារី**៩៩**នាក់។

- **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប** បានចុះអធិការកិច្ចពលកម្មកុមារនៅតាមឡឥដ្ឋចំនួន២០ឡឥដ្ឋ នៅស្រុកចំនួន០៣ គឺស្រុកក្រឡាញ់ ស្រុកអង្គរធំ និងស្រុកបន្ទាយស្រី (០២កន្លែងត្រូវបានបិទ) រកឃើញមនុស្សសរុបចំនួន៥១៧នាក់ មានស្រី២៥៧នាក់ (ក្នុងនោះមានកុមារចំនួន២៣៥នាក់ មានកុមារី១១០នាក់)។ ការស្រង់ស្ថិតិឡឥដ្ឋចំនួន៤៦កន្លែងផ្សេងទៀត រកឃើញកំពុងដំណើរការតែ៣៧កន្លែង បិទដំណើរការ០៣កន្លែង និងផ្អាក០៥កន្លែង រកឃើញកម្មករសរុប៧៨៧នាក់ មានស្រី៣៨០នាក់។

គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទទួលបានពីអង្គភាពចំនួន **២២** គឺ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋានរាជធានី-ខេត្តចំនួន**២០**គឺ រាជធានីភ្នំពេញ កណ្តាល កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ តាកែវ កំពត ព្រះសីហនុ កោះកុង កំពង់ចាម កំពង់ធំ សៀមរាប ព្រះវិហារ ស្វាយរៀង ខេត្តត្បូងឃ្មុំ ក្រចេះ មណ្ឌលគិរី និងរតនគិរី ។ ចំណែកខេត្តចំនួនប្រាំទៀត គឺខេត្តស្ទឹងត្រែង កំពង់ស្ពឺ ឧត្តរមានជ័យ កែប និងព្រៃវែង មិនបានដាក់បញ្ចូលរបាយការណ៍ ក្នុងឆ្នាំ២០១៧ ទាន់ពេលវេលាទេ ។

គ.១-ការងារអនុវត្តច្បាប់

គ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

ដោយមានការដឹកនាំ និងកិច្ចសហការសម្របសម្រួលយ៉ាងជិតស្និទ្ធ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាមួយស្ថាប័នអនុវត្តច្បាប់ មានអគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថ ក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញា និងស្ថាប័នតុលាការ បានធ្វើឲ្យការបង្ក្រាបអំពើជួញដូរមនុស្ស និងការផ្តន្ទាទោសជនល្មើសទទួលបានលទ្ធផលល្អគួរជាទីពេញចិត្ត ទាំងបរិមាណ និងគុណភាព។

ក្នុងឆ្នាំ២០១៧នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ដូចជាសមាជិកក្នុងក្រុមការងារអនុវត្តន៍ច្បាប់ បានសហការជាមួយព្រះរាជអាជ្ញាតាមបណ្តារាជធានី-ខេត្ត បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន**១៥៩**ករណី (លើ**៩២**ករណីបើធៀបនឹងឆ្នាំ២០១៦ កើនឡើងចំនួន**៦៧**ករណី ស្មើនឹង**៧២.៨២%**)។ ឃាត់ខ្លួនជនសង្ស័យ និងបញ្ជូនទៅសាលាដំបូង បានចំនួន**២០៣/១១៣**នាក់ (កើនឡើងចំនួន**៩០**នាក់) ស្រី**៦១**នាក់ អនីតិជន**១៧**នាក់ ត្រូវបានចាប់ខ្លួន។ ក្នុងចំនួនជនសង្ស័យដែលជាជនបរទេសចំនួន**២០**នាក់ មាន**០៨**សញ្ជាតិគឺ៖ វៀតណាម**០៣**នាក់ អង់គ្លេស**០២**នាក់ ហូឡង់**០២**នាក់ ជប៉ុន**០១**នាក់ អាមេរិក**០១**នាក់ ស្វ៊ីស**០១**នាក់ ចិន**០៩**នាក់ និងឆែក**០១**នាក់។

ដោយឡែកជនរងគ្រោះ ដែលសង្គ្រោះបានក្នុងករណីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទសរុបបានចំនួន**៣៩៥/២៩៨**នាក់ (កើនចំនួន**៤៧**នាក់) ក្នុងនោះអាយុក្រោម១៥ឆ្នាំមាន**១៣៨**នាក់ អាយុពី១៥-១៧ឆ្នាំមាន**៩០**នាក់ និងអាយុ១៨ឆ្នាំឡើង មាន**១៦៧**នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ចចំនួន**១២០**នាក់ ទៅ អង្គការចំនួន**០៥**នាក់ និងទៅបញ្ជូនទៅគ្រួសារវិញបានចំនួន**២២០**នាក់)។

១.ករណីអំពើជួញដូរមនុស្ស៖

បង្ក្រាបបាន**៤៨/២៧ករណី** (កើន២១ករណី ស្មើនឹង **៧៧.៧៧%**) ឃាត់ខ្លួនជនសង្ស័យចំនួន**៧២**នាក់ (ស្រី**៣៧**នាក់) មានជនបរទេសចំនួន០៨នាក់ មានសញ្ជាតិ ចិន០៣នាក់ វៀតណាម០១នាក់ អាមេរិក០១នាក់ រុស្ស៊ី០១នាក់ ជប៉ុន០១នាក់ និងអង់គ្លេស០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន**១២៩**នាក់ មានអាយុក្រោម១៥ឆ្នាំចំនួន**៣២**នាក់(**២៤.៨០%**) អាយុពី១៥-១៧ឆ្នាំចំនួន**១៩**នាក់(**១៤.៧២%**)និងអាយុ១៨ឆ្នាំឡើងចំនួន**៧៨**នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ច**២៤**នាក់ ទៅអង្គការ០១នាក់ និងបញ្ជូនទៅគ្រួសារវិញចំនួន**១០៤**នាក់។ មានតារាងរាយលម្អិតដូចខាងក្រោម៖

តារាងស្ថិតិបទល្មើសជួញដូរមនុស្ស

បទល្មើស	ករណី	ជនសង្ស័យ	ជនបរទេស
-ការនាំយកអនីតិជនជាអាទ៏ចេញដោយមិនស្របច្បាប់	៧	៧	
-ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ	១៥	២១	វៀតណាម១
-ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន	១០	១៤	ចិន៣
-ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច	៥	៩	ជប៉ុន១ រុស្ស៊ី១
-អំពើលក់ដូរមនុស្សដោយមានគោលដៅ	៣	៦	
-អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន	៣	៨	
-អំពើនាំឆ្លងដែន	១	១	
-ការទិញពេស្យាចារកុមារ	៤	៦	អាមេរិក១ អង់គ្លេស១
សរុប	៤៨ ករណី	៧២ នាក់	៨ នាក់

២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖

បង្ក្រាបបាន១១១/៦៥ករណី (កើន៤៦ករណី ស្មើនឹង **៧០.៧៦%**) ឃាត់ខ្លួនជនសង្ស័យចំនួន១៣១នាក់ (ស្រី២៤នាក់) មានជនបរទេស១២នាក់ មានសញ្ជាតិ ចិន០៦នាក់ ហូឡង់០២នាក់ វៀតណាម០២នាក់ អង់គ្លេស០១នាក់ និង ឆេក០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន**២១៦**នាក់ មានអាយុក្រោម១៥ឆ្នាំចំនួន**១០៦**នាក់(**៤៩.០៧%**) អាយុ១៥-១៧ឆ្នាំចំនួន២១នាក់ (**៩.៧២%**) និងអាយុ១៨ឆ្នាំឡើងចំនួន៨៩នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ច**៩៦**នាក់ ទៅអង្គការ០៤នាក់ និងបញ្ជូនទៅគ្រួសារវិញចំនួន**១១៦**នាក់។ មានតារាងរាយលម្អិតដូចខាងក្រោម៖

តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ

បទល្មើស	ករណី	ជនសង្ស័យ	ជនបរទេស
-ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង	២	២	
-ស្ថានទម្ងន់ទោស (ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង)	១	៧	
-សញ្ចារកម្ម	៩	១៥	ចិន៦ វៀតណាម១
-សញ្ចារកម្មមានអនីតិជន	៣	៤	
-ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម	៣	៦	
-សញ្ចារកម្ម (ទាក់ទងនឹងពេស្យាចារកុមារ)	៦	៨	វៀតណាម១
-រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ	២	២	ហូឡង់១
-អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ	៦២	៦៤	ឆេក១
-អំពើអាសអាភាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ	២៣	២៣	ហូឡង់១ អង់គ្លេស១
សរុប	១១១ ករណី	១៣១ នាក់	១២ នាក់

គ.១.២-ការកសាងសំណុំរឿង បណ្តឹងជនសង្ស័យរងគ្រោះ បញ្ជូនទៅតុលាការ

ល.រ	អំពើ	មាត្រា	ចំនួនករណី		ចំនួនជនល្មើស		ចំនួនជនរងគ្រោះ	
			ជួញដូរមនុស្ស	អាជីវកម្មផ្លូវភេទ	ជួញដូរមនុស្ស	អាជីវកម្មផ្លូវភេទ	ជួញដូរមនុស្ស	អាជីវកម្មផ្លូវភេទ
១	ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់	៩*	៧		៧		៨	
២	ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ	១០*	១៥		២១		៣១	
៣	ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន	១១*	១០		១៤		៣៤	
៤	ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច	១២*	៥		៩		៣០	
៥	អំពើលក់ដូរមនុស្សដោយមានគោលដៅ	១៥*	៣		៦		២	
៦	អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន	១៦*	៣		៨		៤	
៧	ការដឹកជញ្ជូនដោយមានគោលដៅ	១៧*						
៨	អំពើនាំឆ្លងដែន	១៨*	១		១			
៩	ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង	២១*		២		២		២
១០	ស្ថានទម្ងន់ទោស (ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង)	២២*		១		៧		១៣
១១	សញ្ចារកម្ម	២៦*		៩		១៥		៣២
១២	សញ្ចារកម្ម (មានអនីតិជន)	២៦*		៣		៤		២០
១៣	ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម	២៧*		៣		៦		១៥
១៤	សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ	២៨*		៦		៨		២៧
១៥	ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ	៣២*						
១៦	បទល្មើសទាក់ទននឹងពេស្យាចារកុមារ	៣៣*						
១៧	ការទិញពេស្យាចារកុមារ	៣៤*	៤		៦		២០	
១៨	អំពើអូសទាញពេស្យាចារកុមារ	៣៥*						
១៩	ការនាំឲ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌ ទាក់ទងទៅនឹងអំពើពេស្យាចារកុមារ	៣៦*						
២០	រូបភាព និងសម្ភារៈអាសអាភាស	៣៩*						
២១	រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ	៤១*		២		២		២០
២២	អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ	៤១*		៦២		៦៤		៦៤
២៣	អំពើអាសប្រចាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ	៤១*		២៣		២៣		២៣
២៤	កិច្ចសន្យាសម្រាប់អំពើលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ	៤៥*						
	សរុប	២៤	៤៨	១១១	៧២	១៣១	១២៩	២១៦
	សរុបរួម	២៤	១៥៩ ករណី		២០៣ នាក់		៣៤៥ នាក់	

តារាងបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទឆ្នាំ២០១៧ ប្រៀបធៀបនឹងឆ្នាំ២០១៦

ល.រ	អនុវត្ត	ករណី	ជនសង្ស័យ	ជនរងគ្រោះ
១	ឆ្នាំ២០១៧	១៥៩	២០៣	៣៤៥
២	ឆ្នាំ២០១៦	៩២	១១៣	២៩៨
	សម្គាល់	កើនឡើង៦៧ករណី	កើនឡើង៩០នាក់	កើនឡើង៤៧



គ.១.៣-ការបង្ក្រាបករណីអន្តរការីនៃការពពោះជំនួស

ការបង្ក្រាបអំពើអន្តរការីនៃការពពោះជំនួស០១ករណី កាលពីខែវិច្ឆិកា ឆ្នាំ២០១៦ ដោយស្នងការដ្ឋានរាជធានីភ្នំពេញ ដែលមានជនសង្ស័យចំនួន០៣នាក់ (មានជនបរទេសម្នាក់) ត្រូវបានបន្តនីតិវិធីផ្តន្ទាទោសនៅក្នុងឆ្នាំ២០១៧នេះ។

ចំណែកករណីសង្ស័យថា ជួញដូរសរីរាង្គ ក៏បានបង្ក្រាប០១ករណី តែតុលាការមិនបានរកឃើញ ភស្តុតាងដល់ការដកហូត ឬជួញដូរសរីរាង្គនៅឡើយ ដូច្នេះករណីនេះត្រូវបានចោទប្រកាន់ក្នុងបទល្មើសជួញដូរមនុស្ស។

គ.២-កិច្ចការយុត្តិធម៌

គ.២.១-លទ្ធផលចំណាត់ការផ្តន្ទាទោសក្នុងឆ្នាំ២០១៧

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

គ.២.២-ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ៖

ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន**១៦៦**ករណី រកឃើញជនរងគ្រោះចំនួន**១៧៧**នាក់ (អនីតិជន៨៥នាក់) រកឃើញជនត្រូវចោទមានចំនួន**២០៧**នាក់ ក្នុងនោះអនីតិជន**១៩**នាក់ ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន**១០៧**ករណី តម្កល់ទុកឥតចាត់ការ**០៣**ករណី និងកំពុងចាត់ការចំនួន**៥៦**ករណី មានតារាងរាយលម្អិតដូចខាងក្រោម៖

តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖

ចំនួនករណី	ចំនួនជនរងគ្រោះ				ចំនួនជនល្មើស				ប្រភេទចំណាត់ការ		
	នីតិជន		អនីតិជន		នីតិជន		អនីតិជន		បញ្ជូនទៅស៊ើបសួរ	តម្កល់ទុកឥតចាត់ការ	កំពុងចាត់ការ
	ប្រុស	ស្រី	ប្រុស	ស្រី	ប្រុស	ស្រី	ប្រុស	ស្រី			
សរុប	២៣	៦៩	៤	៨១	១១១	៧៧	១៥	៤	១០៧	៣	៥៦
១៦៦	៩២នាក់		៨៥នាក់		១៨៨នាក់		១៩នាក់		១៦៦ករណី		

គ.២.៣-ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ៖

ចំណាត់ការរបស់ចៅក្រមស៊ើបសួរ រាជធានី-ខេត្ត សរុបមានចំនួន**៤៤២**ករណី រកឃើញជនរងគ្រោះ**៥៦២**នាក់ (អនីតិជន**៣៤៩**នាក់) រកឃើញជនត្រូវចោទមានចំនួន**៤៩៦**នាក់ (អនីតិជន**៦២**នាក់) នៅក្នុងឃុំចំនួន**៣៦៩**នាក់ (អនីតិជន**១១៩**នាក់) នៅក្រៅឃុំចំនួន**១៩៥**នាក់ (អនីតិជន**៥៣**នាក់) និងបានចំណាត់ការបញ្ជូនទៅជម្រះក្តីចំនួន**៣៧**ករណី លើកលែងការចោទចំនួន**០៣**ករណី និងកំពុងចាត់ការចំនួន**៤០២**ករណី មានតារាងរាយលម្អិតដូចខាងក្រោម៖

តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួរ៖

ចំនួនករណី	ចំនួនជនរងគ្រោះ				ចំនួនជនត្រូវចោទ				នៅក្នុងឃុំ				នៅក្រៅឃុំ				ប្រភេទចំណាត់ការ		
	នីតិជន		អនីតិជន		នីតិជន		អនីតិជន		នីតិជន		អនីតិជន		នីតិជន		អនីតិជន		ជូនទៅជម្រះ	លើកលែងចោទ	កំពុងចាត់ការ
	ប	ស	ប	ស	ប	ស	ប	ស	ប	ស	ប	ស	ប	ស	ប	ស			
សរុប	៦០	១៥៣	១០៧	២៤២	៣៦៧	៦៧	៥៧	៥	២១២	៣៨	១០៨	១១	៨៦	៥៦	២៨	២៥	៣៧	៣	៤០២
៤៤២	២១៣នាក់		៣៤៩នាក់		៤៣៤នាក់		៦២នាក់		៣៦៩នាក់				១៩៥នាក់				៤៤២ករណី		

គ.២.៤-ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ រាជធានី-ខេត្ត ៖

ចំណាត់ការរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត សរុបមានចំនួន**២៧០**ករណី រកឃើញជនរងគ្រោះចំនួន**២៧៥**នាក់ (អនីតិជន**៩៨**នាក់) រកឃើញជនជាប់ចោទសរុប**៣២៣**នាក់ (ស្រី**៧០**នាក់) និងបានចំណាត់ការទោសព្យួរគ្មាន ពិន័យជាប្រាក់**០៣**នាក់ រួចផុតពីបទចោទចំនួន**០៤**ករណី រំលត់បណ្តឹងអាជ្ញាគ្មានចាត់ការរួច**៥៨**ករណី ផ្តន្ទាទោសពន្ធនាគារ ក្នុងឃុំ**១២៩**នាក់ ក្រៅឃុំ**៤៥**នាក់ និងកំពុងចាត់ការ**២០៨**ករណី។

តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមជំនុំជម្រះ៖

ចំនួនករណី	ចំនួនជនរងគ្រោះ				ចំនួនជនជាប់ចោទ		ប្រភេទចំណាត់ការ							
	នីតិជន		អនីតិជន				ទោសព្យួរ	ពិន័យជាប្រាក់	រួចផុតពីបទចោទ	រំលត់បណ្តឹងអាជ្ញា	ចាត់ការរួច	ផ្តន្ទាទោសពន្ធនាគារ		កំពុងចាត់ការ
	ប្រុស	ស្រី	ប្រុស	ស្រី	ប្រុស	ស្រី						ក្នុងឃុំ	ក្រៅឃុំ	
២៧០	៥២	១២៥	១៣	៨៥	២៥៣	៧០	គ្មាន	៣	៤	គ្មាន	៥៨	១២៩	៤៥	២០៨

ក្រាហ្វិកចំណាត់ការរបស់ចៅក្រមជំនុំជម្រះឆ្នាំ២០១៧ ប្រៀបធៀបនឹងឆ្នាំ២០១៦



ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

ឃ.១-ការសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញា ជនរងគ្រោះ និងជនសង្ស័យ

- **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៖** ស្ថានទូត ស្ថានតំណាងនៅបរទេស បានទទួល ពលរដ្ឋខ្មែរដែលបរទេសបញ្ជូនត្រឡប់មកកម្ពុជា ហើយដែលរងគ្រោះដោយអំពើជួញដូរមនុស្ស មានចំនួន**៧៥៧**នាក់ (ស្រី**៣៩៣**នាក់) មានមកពី ៖
  - ប្រទេសម៉ាឡេស៊ី ចំនួន**៣៥១**នាក់ (ស្រី**២២៦**នាក់)
  - ប្រទេសថៃ ចំនួន**២៦០**នាក់ (ស្រី**៨៧**នាក់)
  - ប្រទេសចិន ចំនួន**៥០**នាក់ (ស្រី**៥០**នាក់)
  - ប្រទេសឡាវ ចំនួន**៣៣**នាក់ (ស្រី**០៣**នាក់)
  - ប្រទេសសូម៉ាលី ចំនួន**១៨**នាក់
  - ប្រទេសឥណ្ឌូនេស៊ី ចំនួន**១៨**នាក់ (ស្រី**០១**នាក់)
  - ប្រទេសវៀតណាម ចំនួន**១៧**នាក់ (ស្រី**១៧**នាក់)
  - ប្រទេសជប៉ុន ចំនួន**០៥**នាក់ (ស្រី**០៥**នាក់)
  - ប្រទេសសឹង្ហបូរី ចំនួន**០៤**នាក់ (ស្រី**០៣**នាក់)
  - អារ៉ាប៊ីសាអូឌីត ចំនួន**០១**នាក់ (ស្រី**០១**នាក់)។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** (របាយការណ៍តាមក្រុមការងារអនុវត្តន៍ច្បាប់) បានទទួលពលករខ្មែរសង្ស័យរងគ្រោះចំនួន**៣០៤**នាក់(ស្រី១៨៩នាក់) ក្នុងនោះមកពីប្រទេសម៉ាឡេស៊ី **១៤៦**នាក់ (ស្រី**៩៧**នាក់) ចិន**៥៦**នាក់ ឡាវ**២៥**នាក់ (ស្រី**០២**នាក់) វៀតណាម**២៥**នាក់ (ស្រី**១៨**នាក់) សូម៉ាលី**១៨**នាក់ ជប៉ុន**១២**នាក់ ឥណ្ឌូនេស៊ី**១១**នាក់ ថៃ**០៧**នាក់ សាំងហ្គាពួរ **០៣**នាក់ អារ៉ាប៊ីសាអូឌី**០១**នាក់ តាមការសម្ភាសបានឲ្យដឹងថាមានទៅតាមមេខ្យល់ចំនួន **១៧១**នាក់ ទៅដោយខ្លួនឯងចំនួន**២៧**នាក់ ទៅតាមរយៈស្គាល់គ្នាមានចំនួន**១២**នាក់ ទៅតាមក្រុមហ៊ុនមានចំនួន**៤០**នាក់ ក្នុងនោះមិនបានសម្ភាសន៍ចំនួន**១៥៦**នាក់។
- របាយការណ៍**អង្គការ IOM** ឆ្នាំ២០១៧នេះ បានជួយសម្រួលការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋ ពលករ-ពលការិនី និងស្ត្រីខ្មែរសង្ស័យរងគ្រោះចំនួន**២៩៤**នាក់ ស្រី**១១២**នាក់ មកពីប្រទេសចំនួន៨ រួមមាន៖ ថៃ**១២៦**នាក់(ស្រី**២២**នាក់) ម៉ាឡេស៊ី**១០៧**នាក់ (ស្រី**៦៨**នាក់) ឥណ្ឌូនេស៊ី**២២**នាក់ (ស្រី**០២**នាក់) សូម៉ាលី**១៨**នាក់ ជប៉ុន**០៦**នាក់ អារ៉ាប៊ីសាអូឌី**០២**នាក់ ចិន**១២**នាក់ និងសិង្ហបុរី**០១**នាក់។ថែមទាំងបានផ្តល់សេវាស្នាក់នៅ ហូបចុក ថ្នាំសង្កូវ អប់រំចិត្តសាស្ត្រ លុយកាក់ សម្ភារ (កង់ ម៉ូតូ) ដល់ជនរងគ្រោះមួយចំនួនតាមស្ថានភាពខ្វះខាត ជាក់ស្តែងក្នុងពេលកំពុងស្នាក់នៅបណ្តោះអាសន្នផងដែរ។ ការងារពលករខ្មែរទាំងនោះមានដូចជា ធ្វើកសិកម្ម សំណង់ បម្រើការតាមផ្ទះ រោងចក្រ នេសាទ ពេស្យាចារ លក់ដូរ ចាញ់បោកមិត្តភក្តិ រៀបការជាមួយជនបរទេសផ្ទុយពីឆន្ទៈ គ្មានការងារធ្វើ បុគ្គលិកបូមសាំង..។ល។និង។ល។

ឃ.២-ការទទួលជនសង្ស័យរងគ្រោះ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា (របាយការណ៍ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាសរុបមានចំនួន**២៥១**នាក់ (ស្រី**១២៧**នាក់) ។ សកម្មភាពមានដូចជា៖

- ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការ IOM អង្គការចាប់ដៃ និងអង្គការរតនៈ អង្គការ IJM និងអង្គការ Caritas បានទទួលជនសង្ស័យរងគ្រោះចំនួន**២៤៣**នាក់ (ស្រី**១១៩**នាក់) ដែលបានធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ មានមកពីប្រទេស៖ ម៉ាឡេស៊ី**១១៤**នាក់ ថៃ**៤៥**នាក់ ចិន**២១**នាក់ ឥណ្ឌូនេស៊ី**២១**នាក់ សូម៉ាលី**១៨**នាក់ វៀតណាម**១៦**នាក់ ជប៉ុន**០៦**នាក់ សិង្ហបុរី**០១**នាក់ និងអារ៉ាប់បីសាអូឌីត**០១**នាក់។ ជំនាញបានរកឃើញមានករណីជួញដូរកម្លាំងពលកម្ម (ឆ្លងដែន) រៀបការក្លែងក្លាយ និងជួញដូរមនុស្ស**០១**នាក់។
- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានទទួលជនសង្ស័យរងគ្រោះធ្វើមាតុភូមិនិវត្តន៍ចំនួន**៤៦**នាក់ (ស្រី**០១**នាក់ កុមារ**១៨**នាក់ កុមារី**០៨**នាក់ ទារិកា**០១**នាក់) ពីដៃគូខាងភាគីថៃមានដូចជា៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃប្រទេសថៃ(DSDW) ចំនួន**២៦**នាក់ ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សនៃព្រះរាជាណាចក្រថៃ(ខេត្តសុងខ្លា)ចំនួន**១៨**នាក់ និងមជ្ឈមណ្ឌលភូកេតចំនួន**០១**នាក់ និងអង្គការA21ចំនួន**០១**នាក់(ទារិកា)។ មានករណីជួញដូរកម្លាំងពលកម្ម ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការបោះបង់ចោលទារិកា។
- **ការសងថ្លៃឈ្នួលពលកម្ម និងប្រាក់ឧបត្ថម្ភបន្ថែមដល់ជនរងគ្រោះមាន៖**
    - ជនរងគ្រោះខ្មែរចំនួន២៧នាក់ ក្រោយពីការតវ៉ាក្តីនៅប្រទេសចប់ ថៃបានសងថ្លៃឈ្នួលពលកម្មមកឲ្យ ជនរងគ្រោះគឺ
        - ជនរងគ្រោះចំនួន**០៦**នាក់ ទទួលបានថវិកាពី(SDSW) ម្នាក់ៗចំនួន **៣.០០០**បាត។
        - ជនរងគ្រោះចំនួន**២១**នាក់ ទទួលបានថវិកាខុសៗគ្នាទៅតាមការខូចខាតរបស់សាមីខ្លួនពីថៅកែថៃ។
    - កាលពីឆ្នាំ២០១៦ អង្គការIOM បានជួយជនរងគ្រោះជាបុរសចំនួន**១២**នាក់ បានធ្វើមាតុភូមិនិវត្តន៍ និងទទួលថវិកាសំណងពីថៅថៃក្នុងម្នាក់ៗទទួលបាន**៦២.០០០**បាត។
    - សំណងពីប្រទេសជប៉ុន ជូនដល់ស្ត្រីខ្មែររងគ្រោះដោយអំពើជួញដូរមនុស្សចំនួន**០៥**នាក់ កាលពីខែកុម្ភៈ ឆ្នាំ២០១៨ ក្រោមការជួយអន្តរាគមន៍ពីស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន និងនគរបាលជប៉ុន ក្រុមហ៊ុននៅខេត្ត Tochigi ជប៉ុន បានសងប្រាក់មកជាលក្ខណៈគ្រួសារមានចំនួនសរុប **១០.២៤៧១**ដុល្លារអាមេរិច។
    - អ្នកនេសាទសមុទ្រជាជនជាតិខ្មែរចំនួន០៤នាក់ ដែលរងគ្រោះដោយអំពើប្លន់ចាប់ជាចំណាប់ខ្មាំងតាមផ្លូវសមុទ្រ នៅប្រទេសសុម៉ាលី ក្រោយពីការតវ៉ាសម្របសម្រួលតាមរយៈអង្គការ ISWAN និងអង្គការ CARITAS ធ្វើឲ្យម្ចាស់កប៉ាល់ Nahamm 3 ផ្តល់សំណងថ្លៃឈ្នួលពលកម្មទៅឲ្យជនរងគ្រោះក្នុងម្នាក់ៗ ២.៧០០ដុល្លារ និងប្រាក់ឧបត្ថម្ភបន្ថែមម្នាក់ **១.០០០**ដុល្លារ ។
    - បានធ្វើសម្ភាស ដើម្បីកំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស(នីរទេស) ពលរដ្ឋចំនួន**១៧៧**នាក់ (ស្រី**៤៥**នាក់ កុមារ**១១៧**នាក់

កុមារី៦៩នាក់) រកឃើញកុមារដែលមិនមានមនុស្សធំអមដំណើរមកជាមួយមានចំនួន៣០នាក់ កុមារី១៥នាក់ ក្នុងនោះមានៈ ជនងាយរងគ្រោះចំនួន១៤៤នាក់ បានកំណត់ជាប្រភេទជួញដូរកម្លាំងពលកម្មចំនួន០៦នាក់ និងប្រភេទកេងប្រវ័ញ្ចកម្លាំងពលកម្មចំនួន២៧នាក់។

- **មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ** បានទទួលស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទសរុបចំនួន១៣៣នាក់ (ជួញដូរផ្លូវភេទ១១៩នាក់ ជួញដូរឆ្លងដែន០៦នាក់ និងជួញដូរឆ្លងដែនទៅចិន០៨នាក់) ក្នុងនោះទទួលពីៈ ១.ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក្រសួងមហាផ្ទៃចំនួន២៨នាក់ (ជួញដូរឆ្លងដែនទៅចិន០១នាក់) ២.ពីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញ ចំនួន៦១នាក់ (ទៅចិន០៣នាក់ ជួញដូរឆ្លងដែន០២នាក់ ជួញដូរផ្លូវភេទ០៤នាក់) និងពីខណ្ឌដូនពេញ២៣នាក់ ខណ្ឌចំការមន០១នាក់ ខណ្ឌឫស្សីកែវ០១នាក់ ខណ្ឌសែនសុខ០២នាក់ និងអង្គការដៃគូ១២នាក់(ជួញដូរឆ្លងដែន០៤នាក់ ជួញដូរឆ្លងដែនទៅចិន០៤នាក់ ជួញដូរផ្លូវភេទ០៤នាក់) និងបានទទួលកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទចំនួន៤៦នាក់ (ជួញដូរកម្លាំងពលកម្ម២៥នាក់ ជួញដូរផ្លូវភេទ១៣នាក់ រំលោភ០៤នាក់ កេងកម្លាំងពលកម្ម០១នាក់ សញ្ចារកម្ម០៣នាក់)។
- **មន្ទីរសង្គមកិច្ចខេត្តស្វាយរៀង** បានទទួលប្រជាពលរដ្ឋកម្ពុជាចំណាកស្រុកមកពីប្រទេសវៀតណាមតាមរយៈអគ្គកុងស៊ុលព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន០៧លើក មាន៤៥គ្រួសារ សរុបចំនួន១០៥នាក់ ស្រី៦៤នាក់។
- **អង្គការដៃគូ**បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សសរុបចំនួន៣៤២នាក់ ស្រី១៣៦នាក់ កុមារី១៩៣នាក់ តាមរយៈ៖ អង្គការរេណាសេរ១០នាក់ អង្គការក្ដីសង្ឃឹមនិងយុត្តិធម៌(Hope for Justice) ៤០នាក់ អង្គការសង្គ្រោះជោគវាសនាកម្ពុជា(Destiny Rescue) ១៧១នាក់ អង្គការបេសកកម្ម ទូទាំងពិភពលោក០៩នាក់ អង្គការសង្គ្រោះនិងថែទាំអន្តរជាតិស៊ីធីក័យ២២នាក់ អង្គការHAGA២៨នាក់ អង្គការសួននៃក្ដីសង្ឃឹមនៅកម្ពុជា៤៨នាក់ និងអង្គការពន្លកថ្មី (The Hard Place Comnunity)១៤នាក់។ ករណីរកឃើញមានជួញដូរមនុស្ស១៧៦នាក់ ជួញដូរផ្លូវភេទ៤៥នាក់ ជួញដូរកម្លាំងពលកម្ម១៧នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម១៣នាក់ រំលោភបំពានផ្លូវភេទ៨៤នាក់ អំពើអាស០៦នាក់ និងពេស្យាចារ០១នាក់។

ឃ.៣-ការជួយជនរងគ្រោះ និងជនងាយរងគ្រោះ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- **សមាហរណកម្មជនរងគ្រោះ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ (ក្រុមការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយបានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ ក្នុងការជួយ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ ទៅតាមសហគមន៍ និងវិលត្រឡប់មកប្រទេសខ្លួនវិញ សរុបចំនួន១៨៨នាក់ (ស្រី១៧២នាក់) កុមារ០១នាក់ (កុមារី០៧នាក់)។ របាយការណ៍លម្អិតមានមកពី៖

- **មន្ទីរសង្គមកិច្ចរាជធានី-ខេត្ត** បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន១៣នាក់ ក្នុងនោះមាន៖ មន្ទីរសង្គមកិច្ចខេត្តក្រចេះចំនួន១២នាក់ និងមន្ទីរសង្គមកិច្ចខេត្តពោធិ៍សាត់ចំនួន០១នាក់ ដោយមន្ទីរបានធ្វើការសហការជាមួយអាជ្ញាធរ មជ្ឈមណ្ឌលកម្ពុជា និងអង្គការដៃគូក្នុងការបញ្ជូនជនរងគ្រោះទៅសហគមន៍វិញ។

• **អង្គការសម្ព័ន្ធចាប់ដៃ អង្គការរតនៈ អង្គការមេត្រីអន្តរជាតិ និងអង្គការ** Caritas បានធ្វើសមាហរណកម្មជនរងគ្រោះវិលត្រឡប់ទៅសហគមន៍វិញដោយផ្ទាល់ មានចំនួន៨៣នាក់ (ស្រី៧៥នាក់)។

• **អង្គការចាប់ដៃ** បានសហការជាមួយស្ថានទូតខ្មែរប្រចាំក្រៅប្រទេស បានជួយស្ត្រីរងគ្រោះធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញចំនួន៣៨នាក់ (ស្រី៣៤នាក់ កុមារី០៤នាក់) រកឃើញមានមកពីៈ ប្រទេសចិន២៤នាក់ ទីក្រុងហុងកុង១០នាក់ ជាករណីរៀបការខុសច្បាប់ និងបានជួយសង្គ្រោះកុមារីដោយអំពើរំលោភផ្លូវភេទ០៤នាក់។

• **ដោយឡែកអង្គការដៃគូចំនួន០៤ទៀត** បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជួញដូរផ្លូវភេទបានចំនួន៥១នាក់ (ស្រី៤៧នាក់ កុមារ០១នាក់ កុមារី០៣នាក់) គឺអង្គការHAGA បាន១៦នាក់ អង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជាបាន០៨នាក់ អង្គការក្តីសង្ឃឹមនិងយុត្តិធម៌(Hope for Justice) បាន០៣នាក់ និងអង្គការរតនៈបាន២៤នាក់។

II.ការលើកកម្ពស់សមត្ថភាព

១.ក្នុងប្រទេស

១.១-ការបណ្តុះបណ្តាលក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី អគ្គស្នងការដ្ឋាននគរបាលជាតិ និងខេត្តចំនួន១២ គឺមានខេត្តបាត់ដំបង សៀមរាប ព្រះសីហនុ កោះកុង ស្វាយរៀង ព្រះវិហារ កំពង់ធំ ស្ទឹងត្រែង តាកែវ ត្បូងឃ្មុំ ព្រៃវែង ឧត្តរមានជ័យ និងខេត្តកំពង់ឆ្នាំង បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាលជាសរុបបានចំនួន១០៦វគ្គ មានសិក្ខាកាមចូលរួមចំនួន៦.៥៣៥នាក់ ក្នុងនោះមានស្ត្រី២.៨១៤នាក់ ក្នុងគោលបំណងពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិក គ.ខ.ប.ជ លោកគ្រូ អ្នកគ្រូ ប្រតិបត្តិករទេសចរណ៍នៅតាមសណ្ឋាគារ និងប្រជាពលរដ្ឋ ដើម្បីតម្រង់ទិសការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តារាងលម្អិតមានដូចខាងក្រោមៈ

តារាងវគ្គបណ្តុះបណ្តាល

ល.រ	ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល	ចំនួនវគ្គ	សិក្ខាកាមសរុប	សិក្ខាកាមជានារី
១	**ក្រសួងអប់រំ យុវជន និងកីឡា** - បានបើកវគ្គបណ្តុះបណ្តាល និងតម្រង់ទិសការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាៈ ○ នៅស្រុកកងមាស ខេត្តកំពង់ចាម ○ គ្រូបង្រៀន និងគរុសិស្សនៅសាលាគរុកោសល្យ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ។ - បានសហការជាមួយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ រៀបចំវគ្គបណ្តុះបណ្តាលស្តីពី "អំពើហិង្សាទាក់ទងយេនឌ័រ" រួមមានអំពើហិង្សាក្នុងគ្រួសារ អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ សមភាពយេនឌ័រ ភាពជាអ្នកដឹកនាំ និងការលើកកម្ពស់ស្មារតីគាំទ្រទៅដល់មន្ត្រី និងអាជ្ញាធរក្នុងតំបន់ និងប្រជា	១៤	២.៤០២	១.៣៩០

	ពលរដ្ឋក្នុងសហគមន៍។ លើកកម្ពស់ចំណេះដឹងស្តីពី "បញ្ហាទាក់ទងអំពើជួញដូរផ្លូវភេទ" ដល់សិស្សានុសិស្សថ្នាក់វិទ្យាល័យ អាណាព្យាបាល និងមន្ត្រីមានកាតព្វកិច្ច ដែលរស់នៅក្នុងសហគមន៍។ គោលដៅគឺ រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប។			
២	**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការកាត់បន្ថយ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារតាមខេត្ត។	០១	៣៥	១៧
៣	**ក្រសួងកិច្ចការនារី** បើកវគ្គបណ្តុះបណ្តាគ្រូបង្គោលថ្នាក់តំបន់ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ចំនួន០៤ខេត្តគឺ ឧត្តរមានជ័យ ព្រះវិហារ កោះកុង និងស្វាយរៀង។	០៤	១៦៨	១៥៧
៤	**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** - បានសហការជាមួយអង្គការវិនរ៉ុកអន្តរជាតិ បើកវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវា សមស្រប ដល់មន្ត្រីសង្គមកិច្ច អភិបាលរងស្រុក លោកគ្រូ អ្នកគ្រូ មេឃុំ ក្រុមប្រឹក្សាឃុំ ប្រធាន អនុប្រធានភូមិ។ - បានបើកវគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានអប្បបរមា សម្រាប់ថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធជនរងគ្រោះដោយអំពើជួញដូរមនុស្ស។	០៣	៥៥	២៦
៥	**ក្រសួងសុខាភិបាល៖** - បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ចំនួន**១៩**នាក់ និងគ្រូបង្គោលថ្នាក់រាជធានី-ខេត្តទាំង២៥ ចំនួន**១៤៥**នាក់ ដើម្បីបណ្តុះបណ្តាលបន្តដល់អ្នកផ្តល់សេវាសុខាភិបាលនៅមូលដ្ឋានអំពីការគ្រប់គ្រង និងថែទាំសុខភាពស្ត្រីរងគ្រោះគ្រប់ទម្រង់ដោយអំពើហិង្សា ឬអំពើហិង្សាផ្លូវភេទ និងជួញដូរផ្លូវភេទ។ - បណ្តុះបណ្តាលគ្រូបង្គោល នៅខេត្តកំពង់ចាម កំពង់ឆ្នាំង ក្រចេះ កំពង់ស្ពឺ ឧត្តរមានជ័យ ព្រះវិហារ មណ្ឌលគិរី រតនៈគិរី ត្បូងឃ្មុំ ស្ទឹងត្រែង និងខេត្តព្រះសីហនុ ដើម្បីបណ្តុះបណ្តាលបន្តដល់អ្នកផ្តល់ សេវាសុខាភិបាលនៅមូលដ្ឋានអំពីការគ្រប់គ្រង និងថែទាំសុខភាពស្ត្រីរងគ្រោះគ្រប់ទម្រង់ ដោយអំពើហិង្សា ឬ អំពើហិង្សាផ្លូវភេទ និងជួញដូរផ្លូវភេទបានចំនួន**៣៥១**នាក់។	០២	៥១៥	
៦	**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** សហការជាមួយក្រសួងសង្គមកិច្ច និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងអង្គការ Child Fund, IOM បានចុះបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប (ខេត្តក្រចេះ ស្វាយរៀង កំពង់ស្ពឺ តាកែវ និងខេត្តកំពង់ឆ្នាំង)។	០៥	៣៥៥	៨៦
៧	**អគ្គស្នងការដ្ឋាននរបាលជាតិ** (ក្រុមការងារអនុវត្តន៍ច្បាប់)៖ - សហការជាមួយគម្រោង (AATIP) បើកវគ្គបណ្តុះបណ្តាល០១វគ្គ ស្តីពីជំនាញស៊ើបអង្កេតអំពើជួញដូរមនុស្ស ដល់នគរបាលជាស្ត្រី អ្នកចូលរួមចំនួន ២៥នាក់ (នៅសណ្ឋាគារភ្នំពេញ)។ - សហការជាមួយទីភ្នាក់ងារស៊ើបអង្កេតស្ថានទូតអាមេរិក (FBI)បើកវគ្គបណ្តុះបណ្តាល០១វគ្គ ស្តីពីបទល្មើសពាក់ព័ន្ធការសម្ភាសន៍ ការធ្វើកោសល្យវិច្ច័យនីតិវិធីស៊ើបអង្កេតទេសចរណ៍ផ្លូវភេទ និងការធ្វើទំនាក់ទំនងតាមអ៊ិនធើណេត អ្នកចូលរួមចំនួន៤៨នាក់ (នៅសណ្ឋាគាររ៉ាហ្វេល ភ្នំពេញ)។	១០	៣០០	

	- សហការជាមួយអង្គការ AIMSWAT បើកវគ្គបណ្តុះបណ្តាល០៣វគ្គ ស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ អ្នកចូលរួមចំនួន៦០នាក់ (នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន)។ - សហការជាមួយអង្គការ UNODC បើកវគ្គបណ្តុះបណ្តាល០១វគ្គ ស្តីពីការស៊ើបអង្កេត បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា អ្នកចូលរួមចំនួន៤៥នាក់ (នៅសណ្ឋាគារ Green Palace រាជធានីភ្នំពេញ)។ - សហការជាមួយអង្គការ IJM បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល០៤វគ្គ ស្តីពីនីតិវិធីស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស អ្នកចូលរួមចំនួន១២២នាក់ (នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន០២វគ្គ និងខេត្តសៀមរាប០១វគ្គ ខេត្តកំពង់ចាម០១វគ្គ)។			
៨	**មន្ទីរការងារ និងបណ្តុះបណ្តាលខេត្តបាត់ដំបង** បើកវគ្គបណ្តុះបណ្តាលអំពីការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ការងារ។	០១	១៦	២២
៩	**មន្ទីរទេសចរណ៍ខេត្តសៀមរាប** បើកវគ្គបណ្តុះបណ្តាល ៖ - ស្តីពីបដិសណ្ឋារកិច្ច ជូនដល់បុគ្គលិកបម្រើការងារក្នុងមណ្ឌលកម្សាន្តមនុស្សពេញវ័យ នៅមណ្ឌល កម្សាន្តនាងពួន និងមណ្ឌលកម្សាន្ត New Star។ - ពង្រឹងសមត្ថភាពដល់មន្ត្រីនៅថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុកទូទាំងខេត្ត ចំនួន១០ក្រុង ស្រុក។	១១	៥៤១	១៥៧
១០	**លេខាធិការដ្ឋាន គ.ជ.ប.ជ ខេត្តព្រះសីហនុ** សហការជាមួយមន្ទីរទេសចរណ៍ និងមន្ទីរសង្គមកិច្ចខេត្ត បើកវគ្គបណ្តុះបណ្តាល៖ - ស្តីពីជំនាញបដិសណ្ឋារកិច្ច និងសេវាកម្មទេសចរណ៍ដោយបញ្ជ្រាបបញ្ហាយេនឌ័រ និងការធ្វើអាជីវកម្មទេសចរណ៍ផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ចំនួន០២វគ្គ អ្នកចូលរួមចំនួន៧១នាក់ ស្រី២២នាក់។ - បទដ្ឋានអប្បបរមា សម្រាប់ថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប អ្នកចូលរួម៨២នាក់ ស្រី៥៧នាក់។	០៣	១៥៣	៧៩
១១	**ស្នងការដ្ឋាននគរបាលខេត្តកោះកុង** បើកវគ្គបណ្តុះបណ្តាល៖ - ស្តីពីការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សដល់មន្ត្រីនគរបាលថ្មី អ្នកចូលរួមចំនួន៥៦នាក់ ស្រី១១នាក់។ - ស្តីពីការងារបញ្ជ្រាបយេនឌ័រ ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដល់មន្ត្រីនគរបាល ដែលទើបជ្រើសរើសចូលក្របខ័ណ្ឌថ្មី អ្នកចូលរួមចំនួន៥៦នាក់ ស្រី១២នាក់។ - ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ អ្នកចូលរួមចំនួន៤៥នាក់ ស្រី២៥នាក់។ - ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ ដល់ប្រជាពលរដ្ឋក្នុងភូមិ៥សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ អ្នកចូលរួមចំនួន៤៥នាក់ ស្រី៣៨នាក់។ - ស្តីពីការរំលោភបំពាន ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅឃុំដងពែង ស្រុកស្រែអំបិល អ្នកចូលរួមចំនួន៥១នាក់ ស្រី៣៥នាក់។	០៥	២៥៣	១២១
១២	**លេខាធិការដ្ឋាន គ.ជ.ប.ជ ខេត្តស្វាយរៀង** សហការជាមួយអង្គការសម្ព័ន្ធ មន្ទីរសង្គមកិច្ច នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន	០១	៣០	០៧

	បើកវគ្គបណ្ដុះបណ្ដាលស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។			
១៣	**ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ** សហការជាមួយអង្គការទស្សនៈពិភពលោក បើកវគ្គបណ្ដុះបណ្ដាល ស្ដីពីការកំណត់បទល្មើស និងការបញ្ជូនកុមាររងគ្រោះ ដល់គ្រួបង្គោលក្នុងសហគមន៍ នៅស្រុកត្បែងមានជ័យ។	០៣	៩៦	៥២
១៤	**មន្ទីរសង្គមកិច្ចខេត្តក្រចេះ** បើកវគ្គបណ្ដុះបណ្ដាល ស្ដីពីកិច្ចការពារជនរងគ្រោះ ការទប់ស្កាត់ការជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការធ្វើអាជីវកម្មផ្លូវភេទ។	៣០	១.០៣២	៤៧៧
១៥	**ខេត្តកំពង់ធំ** បើកវគ្គបណ្ដុះបណ្ដាល ស្ដីពីការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកខុសច្បាប់។	០២	១០០	៥៦
១៦	**មន្ទីរសង្គមកិច្ចខេត្តស្ទឹងត្រែង** សហការជាមួយអង្គការសុខមាលភាពសង្គម និងសាម៉ារីតាន់ធីស បានបើកវគ្គបណ្ដុះបណ្ដាល ស្ដីពីគន្លឹះទាំង៧ នៃការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់មន្ត្រីសង្គមកិច្ច អង្គការពាក់ព័ន្ធ និងសមាជិក គ.ក.ន.ក ថ្នាក់ឃុំ។	០១	៥៩	៣៩
១៧	**មន្ទីរកិច្ចការនារីខេត្តតាកែវ សហការជាមួយអង្គការទស្សនៈពិភពលោក** បើកវគ្គបណ្ដុះបណ្ដាល ស្ដីពីច្បាប់ទប់ស្កាត់អំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ។	០២	១១៧	៤៩
១៨	**ខេត្តត្បូងឃ្មុំ** ៖ ស្រុកតំបែរ និងស្រុកពញាក្រែក សហការជាមួយអង្គការស៊ីកាស្វា បើកវគ្គបណ្ដុះបណ្ដាល ស្ដីពីតួនាទីនគរបាលយុត្តិធម៌ និងសិទ្ធិកុមារពាក់ព័ន្ធទៅនឹងច្បាប់ជូនដល់ប៉ុស្តិ៍នគរបាល ក្រុមប្រឹក្សាឃុំ និងអ្នកទទួលបន្ទុកកិច្ចការនារី។	០២	៤៧	១២
១៩	**ខេត្តព្រៃវែង** បើកវគ្គបណ្ដុះបណ្ដាល៖ - ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្ដុះបណ្ដាល ស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន២៨នាក់ ស្រី០៥នាក់។ - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការវីនរ៉ុកអន្តរជាតិ បើកវគ្គបណ្ដុះបណ្ដាល ដល់អាជ្ញាធរមូលដ្ឋាន និងអ្នកផ្ដល់សេវាកម្ម ស្ដីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាកម្មសមស្រប និងបទដ្ឋានអប្បបរមាសម្រាប់ការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ៤៣នាក់។	០២	៧១	០៥
២០	**ខេត្តឧត្តរមានជ័យ** បើវគ្គបណ្ដុះបណ្ដាល ដល់ គ.ក.ន.ក និងមន្ត្រីពាក់ព័ន្ធថ្នាក់ក្រុង ស្រុក ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ ដោយអំពើកេងប្រវ័ញ្ចនានា។	០៣	១៤៥	៣៥
២១	**ខេត្តកំពង់ឆ្នាំង បើកវគ្គបណ្ដុះបណ្ដាល៖** ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ថ្នាក់ខេត្ត។	០១	៤៥	២៧
	សរុប	១០៦វគ្គ	៦.៥៣៥នាក់	២.៨១៤នាក់

១.២-សិក្ខាសាលា

ឆ្នាំ២០១៧នេះ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលេខាធិការដ្ឋានគ.ខ.ប.ជខេត្ត បានសហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ ធ្វើសិក្ខាសាលាផ្តោតទៅលើប្រធានបទសំខាន់ៗ ដែលជាកិច្ចការអាទិភាព

ទាក់ទងនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបបានចំនួន**៣៣**វគ្គ មានអ្នកចូលរួមចំនួន**២.៦១១**នាក់ ស្រី**១.២៧៧**នាក់ សកម្មភាពទាំងនោះរួមមាន៖

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំសិក្ខាសាលាចំនួន**០៣**វគ្គ មានអ្នកចូលរួមសរុបចំនួន**៤៣៣**នាក់ (ស្រី**១៦៦**នាក់) គឺ

(១).សិក្ខាសាលាផ្សព្វផ្សាយឯកសារគោល នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **និងជាប្រធាន** គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ ដែលមានសមាសភាពចូលរួមមានឯកឧត្តម លោកជំទាវ ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុប្រធាន សមាជិក គ.ជ.ប.ជ ប្រធាន និងសមាជិកក្រុមការងារទាំង៦ តំណាងស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ ជាតិ អន្តរជាតិ អភិបាល អភិបាលរង រាជធានី-ខេត្ត សរុបចំនួន**១៩០**នាក់ (ស្រី**៨៩**នាក់)។

(២).សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ការយល់ដឹងអំពីអនុសញ្ញាអាស៊ាន និងផែនការសកម្មភាពអាស៊ានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP & APA) ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ នៅសណ្ឋាគារ៉ាហ្វ៊លឡឺរ៉ូយ៉ាល់ ដែលមានសមាសភាពចូលរួមជាតំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តំណាងក្រុមជំនាញអន្តរក្រសួង ស្ថាប័នទាំង០៦ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិដើម្បីកុមារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្ថានទូតសហរដ្ឋអាមេរិក ASEAN.US Progress IOM, USAID, IJM និង WI សរុបចំនួន**៦៩**នាក់ (ស្រី**១៧**នាក់)។

(៣).សិក្ខាសាលាថ្នាក់ជាតិ ស្តីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ គាំទ្រដោយ អង្គការទេសន្តប្រវេសន៍អន្តរជាតិ IOM មានអ្នកចូលរួម**១៧៤**នាក់ ស្រី**៦០**នាក់។

- **ក្រសួងកិច្ចការនារី** បានរៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅបន្តរបស់កម្មវិធីទប់ស្កាត់អំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចនានា ដែលមានសមាសភាពចូលរួមជាថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងកិច្ចការនារី ប្រធាន-អនុប្រធានមន្ទីរកិច្ចការនារីរាជធានី-ខេត្តទាំង២៥ ប្រធាន អនុប្រធានការិយាល័យកិច្ចការនារីក្រុង ខណ្ឌ ស្រុកដែលជាជនបង្គោល សរុបមានចំនួន**៦០**នាក់ ស្រី**៥៦**នាក់។
- **ក្រសួងទេសចរណ៍** បានរៀបចំសិក្ខាសាលាចំនួន**០៦**វគ្គ ស្តីពី"**សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍**" ដល់ផ្នែកឯកជននៃវិស័យទេសចរណ៍ ដែលមានសិក្ខាកាមចូលរួមចំនួន**៣៨១**នាក់ ស្រី**១៩០**នាក់។
  - ធ្វើនៅខេត្តកំពង់ធំ មានសិក្ខាកាមចូលរួមចំនួន**៦២**នាក់ ស្រី**៣២**នាក់
  - ធ្វើនៅខេត្តតាកែវ មានសិក្ខាកាមចូលរួមចំនួន**៦១**នាក់ ស្រី**២៩**នាក់
  - ធ្វើនៅខេត្តព្រៃវែង មានសិក្ខាកាមចូលរួមចំនួន**៦២**នាក់ ស្រី**៣៤**នាក់
  - ធ្វើនៅខេត្តព្រះវិហារ មានសិក្ខាកាមចូលរួមចំនួន**៦៦**នាក់ ស្រី**៣១**នាក់
  - ធ្វើនៅខេត្តកែប មានសិក្ខាកាមចូលរួមចំនួន**៥០**នាក់ ស្រី**២៤**នាក់
  - ធ្វើនៅខេត្តកណ្តាល មានសិក្ខាកាមចូលរួមចំនួន**៨០**នាក់ ស្រី**៤០**នាក់។

- **ក្រសួងអប់រំ យុវជន និងកីឡា** បានរៀបចំសិក្ខាសាលាចំនួន០២វគ្គ ស្តីពីការពង្រឹងក្របខណ្ឌច្បាប់ និងយន្តការនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសិក្ខាកាមចូលរួមចំនួន**១៥៨**នាក់ ស្រី**៣២**នាក់។
  - ធ្វើនៅខេត្តត្បូងឃ្មុំ មានសិក្ខាកាមចូលរួមចំនួន**៨៥**នាក់ ស្រី**២៣**នាក់
  - ធ្វើនៅខេត្តកោះកុង មានសិក្ខាកាមចូលរួមចំនួន**៧៣**នាក់ ស្រី០៩នាក់។
- **ខេត្តព្រៃវែង ៖ គណៈកម្មាធិការ គ.ខ.ប.ជ** បានសហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) រៀបចំសិក្ខាសាលា ស្តីពីកិច្ចសហការ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុសស្ស ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** នៅសាលប្រជុំ សាខាកាកបាទក្រហមខេត្ត មានអ្នកចូលរួមចំនួន**១១០**នាក់។
- **លេខាធិការដ្ឋានកោះកុងខេត្ត** សហការជាមួយអង្គការវីនរ៉ក (WINROCK) បានបើកសិក្ខាសាលាស្តីពីការបណ្តុះបណ្តាលមន្ត្រីជួរមុខនៃគណៈកម្មាធិការខេត្ត និងលេខាធិការដ្ឋាន គ.ខ.ប.ជ ដែលមានអ្នកចូលរួមសរុប**៤៥**នាក់ ស្រី**១៦**នាក់ ក្រោមអធិបតីភាពលោកស្រី **ឈុន វ៉ារុំ** អភិបាលរងខេត្ត។
- **ខេត្តបាត់ដំបង បានរៀបចំសិក្ខាសាលា ចំនួន១៦លើក អ្នកចូលរួមចំនួន១.១១៤នាក់ ស្រី៦៨១នាក់៖**
  - **លេខាធិការដ្ឋាន គ.ខ.ប.ជ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសមាសភាពអញ្ជើញចូលរួមដូចជាក្រុមប្រឹក្សាខេត្ត មន្ទីរ អង្គភាពពាក់ព័ន្ធ គណៈអភិបាលក្រុង-ស្រុក ក្រុមប្រឹក្សាក្រុង-ស្រុក និងក្រុមប្រឹក្សាឃុំ-សង្កាត់ នៅសណ្ឋាគារខេមរា ខេត្ត បាត់ដំបង អ្នកចូលរួមចំនួន**១៣០**នាក់ ស្រី**១១០**នាក់។
  - **មន្ទីរទេសចរណ៍ខេត្ត** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ "**ច្បាប់ស្តីពីទេចរណ៍ និងស្តង់ដារទេសចរណ៍**" ក្នុងនោះបានធ្វើបទបង្ហាញស្តីពី "**សុវត្ថិភាពស្ត្រី និងកុមារក្នុងវិស័យទេសចរណ៍**" នៅសាលប្រជុំសណ្ឋាគារ ប្រេស៊ីដង់ ដែលមានអ្នកចូលរួមចំនួន៩៨នាក់ ស្រី៣៩នាក់
  - **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត៖**
    - សិក្ខាសាលាផ្សព្វផ្សាយស្តីពីការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តិពាក់ព័ន្ធនឹងពលករទេសន្តប្រវេសន៍ការងារ ដែលមានអ្នកចូលរួមមកពីមន្ទីរពាក់ព័ន្ធជុំវិញខេត្ត តំណាងស្នងការនគរបាលខេត្ត អង្គការជាតិ-អន្តរជាតិ ស្ថានីយ៍វិទ្យុ និងតំណាងស្រុកគោលដៅសរុបចំនួន**២១**នាក់ ស្រី០៥នាក់ នៅក្នុងសាលប្រជុំរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង។
    - សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីនីតិវិធីបំពេញបែបបទស្នើសុំប័ណ្ណ និងសៀវភៅការងារជនបរទេស និងការបំពេញបែបបទស្នើសុំកូតា ប្រើប្រាស់ហត្ថពលកម្មបរទេស តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម អ្នកចូលរួម**៣០នាក់** ស្រី**១៣នាក់** នៅវិទ្យាស្ថានបច្ចេកវិទ្យា ខេត្តបាត់ដំបង (BIT)។
  - **មជ្ឈមណ្ឌលការងារខេត្ត៖**
    - ស្តីអំពីការរៀបចំផែនការអាជីព និងជ្រើសរើសជំនាញសិក្សានៅវិទ្យាល័យក្នុងខេត្ត ចំនួន០៤លើក ដែលមានសិស្សានុសិស្សចូលរួមចំនួន៣៨៦នាក់ ស្រី២១៤នាក់។

- ស្ដីអំពីភាពឆ្លាតវៃខាងថវិកា-ការអប់រំហិរញ្ញវត្ថុសម្រាប់កម្មករ/កម្មការិនី ចំណាកស្រុក និងគ្រួសាររបស់ពួកគេ នៅវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង ក្រោមគម្រោង MRC-ILO ដែលមានអ្នកចូលរួមសរុប**៧៣**នាក់ ស្រី**៦៥**នាក់។
- សិក្ខាសាលាផ្សព្វផ្សាយ និងប្រមូលអ្នកស្វែងរកការងារនៅតាមមូលដ្ឋាន នៅស្រុកបាណន់ ស្រុកមោងឫស្សី និងស្រុកថ្មគោល ចំនួន**០៣**លើក អ្នកចូលរួមសរុប**១២០**នាក់ ស្រី**៣៧**នាក់។

• **អង្គការប្រតិបត្តិកុមារកម្ពុជា** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីការធ្វើចំណាកស្រុកដោយស្របច្បាប់ នៅក្នុងតំបន់គោលដៅ ទៅដល់អាជ្ញាធរ និងសហគមន៍ដែលពាក់ព័ន្ធ បានចំនួន**០៤**លើក អ្នកចូលរួមចំនួន**១១១**នាក់។

• **អង្គការទស្សនៈពិភពលោកអន្តរជាតិកម្ពុជាប្រចាំភូមិភាគខាងលិច** បានរៀបចំសិក្ខាសាលា ស្ដីពីបទពិសោធន៍អំពើជួញដូរមនុស្ស ចំណាកស្រុកប្រកដោយសុវត្ថិភាព និងការបង្ការ ទប់ស្កាត់ អ្នក ចូលរួមចំនួន**១៤៥**នាក់។

- **ខេត្តសៀមរាប** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការបេសកកម្មអន្តរជាតិ (IJM) និងអង្គការទស្សនពិភពលោក ក្នុងការរៀបចំសិក្ខាសាលាពង្រឹងសមត្ថភាព ដល់សមាជិកលេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលមានចំនួនចូលរួមសរុប**១០៥**នាក់ ស្រី**៤៥**នាក់។
- **ខេត្តបន្ទាយមានជ័យ** បានរៀបចំសិក្ខាសាលា ស្ដីពីកិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំ (ក) ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អ្នកចូលរួមចំនួន**១១៥**នាក់ ស្រី**៤១**នាក់។
- **ខេត្តកណ្ដាល** មន្ទីរទេសចរណ៍ខេត្ត បានសហការជាមួយក្រសួងទេសចរណ៍ និងអង្គការ Friend International បើកវគ្គសិក្ខាសាលា ស្ដីពី "**សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍**" ដល់មន្ត្រីនគរបាលទេសចរណ៍ អាជីវកម្មផ្ទះសំណាក់ សណ្ឋាគារ ខារ៉ាអូខេ ភោជនីយដ្ឋាន អ្នកចូលរួមចំនួន**៩០**នាក់ ស្រី**៥០**នាក់។

១.៣-សន្និសីទ

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានរៀបចំសន្និសីទអាស៊ី-អ៊ឺរ៉ុបលើកទី១៤ ស្ដីពីការគ្រប់គ្រងលំហូរទេសន្តប្រវេសន៍ ក្រោមអធិបតីភាព សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅខេត្តសៀមរាប មានសមាជិកចូលរួមចំនួន**៦៤**នាក់ មកពី**២៥**ប្រទេស។

១.៤-ការដឹកនាំសម្របសម្រួល កិច្ចប្រជុំ

សរុបការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ**៩៩១**លើក មានអ្នកចូលរួមសរុប**៧.៤២៥**នាក់ មានស្រី**២.២៥៥**នាក់ ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានរៀបចំកិច្ចប្រជុំចំនួន**១៤០**លើក ក្រសួងយុត្តិធម៌ **០១**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន**២៦**លើក ក្រសួងកិច្ចការនារី ចំនួន**២៨**លើក

ក្រសួងអប់រំ យុវជន និងកីឡា ចំនួន២៦លើក ក្រសួងទេសចរណ៍០១លើក ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ០៥លើក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំសន្និបាតចំនួន០១លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត បានរៀបចំប្រជុំចំនួន២៦៣លើក ។ (**ឧបសម្ព័ន្ធទី២**)

២.ក្រៅប្រទេស

២.១-វគ្គបណ្តុះបណ្តាល

- **អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ** បានបញ្ជូនមន្ត្រីជាន់ខ្ពស់ថ្នាក់ប្រធាននាយកដ្ឋាន០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធមនុស្ស និងបទល្មើសដែលមានអង្គការចាត់តាំង នៅទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម។
- **អគ្គស្នងការនគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់)** បានចាត់បញ្ជូនមន្ត្រីជាន់ខ្ពស់ចំនួន០៦រូប ទៅចូលរួម៖
  - មន្ត្រីជាន់ខ្ពស់ចំនួន០២រូប ចូលរួមវគ្គបណ្តុះបណ្តាលការពារសាក្សីទៅលើករណីអំពើជួញដូរមនុស្ស សម្រាប់អាស៊ាន (នៅបណ្ឌិត្យសភានគរបាលប្រទេសថៃ)។
  - មន្ត្រីជាន់ខ្ពស់ចំនួន០៣រូប ចូលរួមវគ្គបំប៉នជំនាញការងារប្រឆាំងការជួញដូរមនុស្សចំនួន០២លើក (នៅប្រទេសវៀតណាម)។
  - មន្ត្រីជាន់ខ្ពស់ចំនួន០១រូប ចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសថៃ ក្នុងកម្មវិធីបណ្តុះបណ្តាលប្រទេសតតិយលោក សម្រាប់អភិវឌ្ឍន៍ការគ្រប់គ្រងរងជនជាប់ទោសនៅតាមសហគមន៍ប្រកបដោយប្រសិទ្ធភាព ក្នុងប្រទេស កម្ពុជា ឡាវ ភូមា និងវៀតណាម (Third Country Training Programme (TCTP) For Development Effective Community Based Treatment of offenders in the CLMV Countries) ។
- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានបញ្ជូនមន្ត្រី និងនាយនគរបាលជាន់ខ្ពស់ចំនួន៤៨រូប ទៅចូលរួមវគ្គបណ្តុះបណ្តាល៖
  - ស្តីពីការគ្រប់គ្រងអន្តោប្រវេសន៍ និងការប្រើប្រាស់ប័ណ្ណ អន្តោប្រវេសន៍ នៅទីក្រុង Lang Fang ខេត្ត Habei នៅសាធារណរដ្ឋប្រជាមានិតចិន។
  - ស្តីពីការគ្រប់គ្រងអន្តោប្រវេសន៍ នៅសាធារណរដ្ឋប្រជាមានិតចិន។
  - ជំនាញច្រកទ្វារ នៅសាលាមធ្យមព្រំដែន២ ក្រុងវង់តាវ ខេត្តបារៀ ប្រទេសវៀតណាម។
  - ស្តីពីការត្រួតពិនិត្យឯកសារសន្តិសុខ នៅទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី។
- **ខេត្តកំពត** បានបញ្ជូននាយកាវិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន៖
  - ចំនួន០២រូប ទៅរៀនវគ្គ ILEA នៅទីក្រុងបាងកក ប្រទេសថៃ។
  - ចំនួន០១រូប ទៅរៀនវគ្គបំប៉នជំនាញ នៅប្រទេសវៀតណាម។

២.២-សិក្ខាសាលា

- **អគ្គលេខាធិការដ្ឋាន** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ៖
  - លោកជំទាវឧត្តមសេនីយ៍ឯក **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការរង គ.ជ.ប.ជ និងតំណាងក្រសួងកិច្ចការនារី ដើម្បីចូលរួមសិក្ខាសាលាវេទិកាតំបន់អាស៊ាន ស្តីពីការជួញដូរមនុស្ស(នៅប្រទេសឥណ្ឌូនេស៊ី)។

- ចាត់បញ្ជូន លោកឧត្តមសេនីយ៍ត្រី **សុខ ស្មើ** ប្រធានក្រុមជំនួយកិច្ចសហប្រតិបត្តិការអន្តរជាតិ ចូលរួមសិក្ខាសាលាអាស៊ានសម្រាប់អ្នកប្រតិបត្តិផ្ទាល់ ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យច្បាប់ នៅក្នុងរឿងក្តីជួញដូរមនុស្ស (នៅទីក្រុងបាងកកប្រទេសថៃ)។

- **ក្រសួងកិច្ចការនារី ៖**
  - លោកជំទាវ **សាន្ត អរុណ រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី** បានដឹកនាំគណៈប្រតិភូកម្ពុជាដែលមានសមាសភាពមកពី (គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គស្នងការដ្ឋាននគរបាលជាតិ) ដើម្បីចូលរួមសិក្ខាសាលាថ្នាក់តំបន់មេគង្គ លើកទី៧ ស្តីពីការកំណត់អត្តសញ្ញាណ និងផ្តល់សេវាជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការចែករំលែកបទពិសោធន៍ ក្នុងការកសាងជីវិតថ្មីក្នុងចំណោមប្រទេស នៃមហាអនុតំបន់មេគង្គ (រៀបចំដោយ JICA និងក្រសួងសន្តិសុខអភិវឌ្ឍប្រទេសថៃ)។
  - ចូលរួមសិក្ខាសាលាមហាអនុតំបន់មេគង្គ ស្តីពីការពិនិត្យលើគោលណ៍ការទូទៅ និងគោលការណ៍ណែនាំ ស្តីពីការជ្រើសរើសពលករធ្វើការងារប្រកបដោយយុត្តិធម៌ នៅប្រទេសថៃ។
  - សិក្ខាសាលាអាស៊ាន ស្តីពីការជួញដូរមនុស្ស នៅប្រទេសឥណ្ឌូនេស៊ី។
  - សិក្ខាសាលាអាស៊ាន ស្តីពីការពិភាក្សាផ្តល់ធាតុចូលលើសេចក្តីព្រាង និងនីតិវិធីសម្រាប់ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅប្រទេសថៃ។

- **ក្រសួងអប់រំ យុវជន និងកីឡា ៖**
  - បានចូលរួមសិក្ខាសាលាមហាអនុតំបន់ទន្លេមគង្គលើកទី៧ ស្តីពីការកំណត់ការផ្តល់ធនធាន និងសេវាជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការចែករំលែកបទពិសោធន៍ក្នុងការកសាងជីវិតថ្មី ចំណោមប្រទេសមហាអនុតំបន់ទន្លេមគង្គ ដើម្បីទទួលបានសេវាសមស្របរៀបចំដោយអង្គការ JICA និងក្រសួងសន្តិសុខអភិវឌ្ឍសង្គម នៃប្រទេសថៃ។
  - បានចូលរួមសិក្ខាសាលាតំបន់អាស៊ាន ស្តីពីការជួញដូរមនុស្ស នៅប្រទេសឥណ្ឌូនេស៊ី។

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** ចាត់បញ្ជូននាយនគរបាល**០២រូប** ចូលរួមសិក្ខាសាលាសហការករណីរត់ពន្ធជនអន្តោប្រវេសន៍ក្នុងតំបន់ និងការជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ។

២.៣-កិច្ចប្រជុំ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ៖**
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ៖
    - បានដឹកនាំគណៈប្រតិភូកម្ពុជាពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន**១០រូប** ដើម្បីចូលរួមកិច្ចប្រជុំលើកទី១ ឆ្នាំ២០១៧ ស្តីពីការអនុវត្តកិច្ចព្រមព្រៀង ស្តីពីការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស រវាងរដ្ឋាភិបាលចិន-កម្ពុជា ដែលប្រព្រឹត្តទៅនៅទីក្រុងហ៊ាំងសាន ខេត្តអានហួយ សាធារណរដ្ឋប្រជាមានិតុចិន។
    - បានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ ថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីការរៀបចំកតិកាសញ្ញាពិភពលោកស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលប្រារព្ធ ធ្វើនៅមជ្ឈមណ្ឌល សន្និសីទអង្គការសហប្រជាជាតិ នៅក្រុងបាងកក ប្រទេសថៃ រៀបចំដោយ UN ESCAP និង IOM។

  - បានអញ្ជើញបំពេញបេសកកម្មជាផ្លូវរដ្ឋ នៅប្រទេសម៉ិចស៊ីកូ ចូលរួមកិច្ចប្រជុំកំពូលអង្គការសហប្រជាជាតិ ស្តីពីការរៀបចំកតិកាសញ្ញាជាសកល ស្តីពីទេសន្តរប្រវេសន៍ ប្រកបដោយសុវត្ថិភាពភាពស្របច្បាប់ និងប្រក្រតីភាព។
- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានចាត់បញ្ជូន លោកឧត្តមសេនីយ៍ត្រី ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ដើម្បី៖
  - ចូលរួមក្នុងវេទិកាអាំងទែរប៉ូល ស្តីពីការរួមគ្នាដើម្បីសន្តិសុខ និងការទទួលខុសត្រូវសម្រាប់សន្តិភាពពិភពលោក នៅទីក្រុង Abu Dhabi ប្រទេសអារ៉ាប់រួម ។
  - ចូលរួមកិច្ចប្រជុំ ឧត្តមមន្ត្រីអាស៊ានលើកទី១៧ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (នៅក្រុងវៀងច័ន្ទ ប្រទេសឡាវ)។
- ចាត់បញ្ជូនមន្ត្រីជាន់ខ្ពស់ ថ្នាក់អនុប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍០១រូប ចូលរួមសន្និសីទថ្នាក់តំបន់ ស្តីពីការបន្លាស់ទីរបស់កុមារ នៅក្នុងតំបន់អាស៊ី-អាគ្នេយ៍ (នៅទីក្រុងបាងកក ប្រទេសថៃ)។

- **ក្រសួងកិច្ចការនារី៖** លោកជំទាវ **សាន្ត អរុណ** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី បានដឹកនាំគណៈប្រតិភូខមមីតកម្ពុជា ចំនួន**១១រូប** ដែលសមាសភាពមកពី (ក្រសួងកិច្ចការនារី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច និងយុវនីតិសម្បទា ក្រសួងទេសចរណ៍ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងសមាគមនារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍) ទៅចូលរួមក្នុងកិច្ចប្រជុំក្រុមការងារខមមីតថ្នាក់តំបន់ និងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតលើកទី១២ (SOM 12) នៅទីក្រុងណៃពិដោ ប្រទេសមីយ៉ាន់ម៉ា។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៖**
  - ចូលរួមប្រជុំពិគ្រោះយោបល់ទ្វេភាគី រវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃលើកទី១៤ ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស (នៅខេត្តឈៀងម៉ៃ ប្រទេសថៃ)។
  - ឯកឧត្តម **តូច ចាន់នី** អគ្គនាយកបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដឹកនាំគណៈប្រតិភូកម្ពុជាមកពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងអង្គការដៃគូចំនួន**១៩រូប** ដើម្បីចូលរួមកិច្ចប្រជុំ ស្តីពីការគ្រប់គ្រងករណីដំណើរការមាតុភូមិនិវត្តន៍ និងសមាហរណកម្ម (នៅប្រទេសថៃ)។
  - បានដឹកនាំប្រតិភូទៅចូលរួមកិច្ចប្រជុំជាមួយក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការចាត់ចែងដោះស្រាយករណី នៅទីក្រុងបាងកក ប្រទេសថៃ។ លទ្ធផលនៃកិច្ចប្រជុំមានដូចខាងក្រោម៖
    - បង្កើតប្រព័ន្ធទំនាក់ទំនងរវាងភាគីទាំងពីរ ឲ្យមានការតែងតាំងជនបង្គោលដើម្បីទំនាក់ទំនងការងារ ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវយន្តការផ្លាស់ប្តូរព័ត៌មាន ដ៏មានប្រសិទ្ធភាពក្នុងការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មក្នុងការបង្ការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយភាគីកម្ពុជាបានចាត់ លោកស្រី **ព្រុំ សុខន** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ជាជនបង្គោលក្នុងការសម្របសម្រួល និងភាគីថៃ បានចាត់លោកស្រី **Suvaree Jaiharm** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ជាជនបង្គោលក្នុងការសម្របសម្រួល។

   - រៀបចំសេចក្តីព្រាងនីតិវិធីប្រតិបត្តិពិសេស (SOP) រវាងភាគីទាំងពីរស្តីពីការទទួលខុសត្រូវក្នុងការទទួល និងការប្រគល់ជនរងគ្រោះ។
   - ពិនិត្យ និងស្រាវជ្រាវអំពីនីតិវិធីដំណើរការប្រព័ន្ធយុត្តិធម៌ រឿងក្តីឧក្រិដ្ឋកម្មនៃបទឧក្រិដ្ឋពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងការទទួលខុសត្រូវលើការទទួលយកសំណងបដិទាន និងសំណងមូលនិធិ។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានប្រជុំថ្នាក់មន្រ្តីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្រ្តីលើកទី២ ស្តីពីការអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ស្តីពីការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។
- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍៖**
  - **ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត សុខ ផល** អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានដឹកនាំប្រតិភូអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងប្រធានកុងស៊ុលអាស៊ានលើកទី២១(21st DGICM) និងកិច្ចប្រជុំពាក់ព័ន្ធនៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិតេយ្យប្រជាមានិតឡាវ។
  - **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានចាត់បញ្ជូននាយនគរបាល**០៥រូប** ដើម្បីចូលរួម៖
    - ប្រជុំពិភាក្សា ស្តីពីការផ្លាស់ប្តូរការងារគ្រប់គ្រងការងារអន្តោប្រវេសន៍ ជាមួយអគ្គអន្តោប្រវេសន៍នៃព្រះរាជាណាចក្រថៃ នៅទីក្រុងបាងកក ប្រទេសថៃ។
    - សន្និសីទសាកល ស្តីពីបទល្មើសឆ្លងដែន នៅទៅក្រុងសេអ៊ូល នៃសាធារណៈរដ្ឋកូរ៉េ។
    - វេទិកាប្រធានច្រកទ្វារអន្តោប្រវេសន៍លើកទី២ នៅទីក្រុង Tangerang ខេត្ត Banten ប្រទេសឥណ្ឌូនេស៊ី។
    - ដើម្បីធ្វើការសម្ភាស និងកំណត់អត្តសញ្ញាណពលរដ្ឋខ្មែរចំនួន**១០០**នាក់ ទៅទីក្រុងអាឌែលឡែនតូ រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក។
- **ខេត្តបន្ទាយមានជ័យ៖ ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត** បានចូលរួមប្រជុំជាមួយភាគីថៃនៅសណ្ឋាគារឥណ្ឌូចិន ខេត្តស្រះកែវ (ប្រទេសថៃ) ស្តីពីនីតិវិធីក្នុងការបញ្ជូនត្រឡប់ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងភាពប្រឈម ក្នុងនោះមានសមាសភាពចូលរួមខាងភាគី កម្ពុជាចំនួន**២០**នាក់ និងភាគីថៃចំនួន**៣៥**នាក់។
- **ខេត្តព្រះវិហារ៖ ថ្នាក់ដឹកនាំវរការពារព្រំដែនទាំងពីរដែលជាប់ព្រំដែនជាមួយប្រទេសឡាវ** បានចូលរួមប្រជុំជាមួយភាគីឡាវ នៅច្រកព្រំដែនទាំង២ស្តីពីកិច្ចសហប្រតិបត្តិការការពារសន្តិសុខ តាមបណ្តោយព្រំដែន និងបញ្ហាពលករធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដើម្បីស្វែងរកការងារធ្វើនៅក្រៅប្រទេស និងពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្លងដែនខុសច្បាប់។
- **ខេត្តរតនគិរី៖ ថ្នាក់វរៈនិងវរៈការពារព្រំដែន**បានចូលរួមប្រជុំចំនួន**០៤**លើក ថ្នាក់ប៉ុស្តិ៍និងប៉ុស្តិ៍ចំនួន**៤៧**លើក ជាមួយភាគីឡាវ និងភាគីវៀតណាម នៅតាមតំបន់ព្រំដែន ស្តីពីកិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់តាមបណ្តោយព្រំដែន និងដោះស្រាយបញ្ហាប្រជាជនឆ្លងដែនខុសច្បាប់បានចំនួន **១៣២** លើក។

២.៤ សន្និសីទ

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមសន្និសីទអាស៊ាន ស្តីពីសារសំខាន់នៃបញ្ហាផ្នែកច្បាប់ ក្នុងតំបន់នៅប្រទេសសិង្ហបុរី។

III. ការសន្និដ្ឋានវាយតម្លៃ

ក. ចំណុចខ្លាំង

យន្តការនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានធ្វើសកម្មភាពព្រមៗគ្នាប្រកបដោយស្មារតីទទួលខុសត្រូវ ធ្វើឲ្យប្រទេសកម្ពុជាទទួលចំណាត់ថ្នាក់លេខ២ ដោយការវាយតម្លៃរបស់សហរដ្ឋអាមេរិក ស្តីពីកិច្ចខិតខំប្រឹងប្រែងក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧ នេះ។ ចំណុចខ្លាំងនៃយន្តការនេះគឺ៖

- ឆន្ទៈ និងការប្តេជ្ញាចិត្តជានយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកំណត់យកបញ្ហាជួញដូរមនុស្សជាអាទិភាពមួយ ដែលត្រូវតែយកចិត្តទុកដាក់ដោះស្រាយជាបន្ទាន់ មិនអាចព្រងើយកន្តើយបាន ព្រោះវាបានធ្វើឲ្យប៉ះពាល់ដល់អាយុជីវិត សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្សដែលជាធនធានប្រកបដោយសក្តានុពលនៃសេដ្ឋកិច្ចសង្គម និងនយោបាយជាតិយ៉ាងធ្ងន់ធ្ងរ។
- ការសម្រេចចិត្តជាយុទ្ធសាស្រ្តរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ**ព្រះរាជាណាចក្រកម្ពុជា** ក្នុងការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ បញ្ចៀសបញ្ហាប្រឈមដែលពលករខុសច្បាប់នៅក្រៅប្រទេស បង្កើនការយកចិត្តទុកដាក់ជាគោលនយោបាយ លើការលើកកម្ពស់ជីវភាព និងស្ថានភាពរស់នៅរបស់កម្មករក្នុងស្រុកធ្វើឲ្យមានតុល្យភាពសម្រាប់ជម្រើស ក្នុងការរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា កាត់បន្ថយការសម្រេចចិត្តដោយប្រថុយប្រថានក្នុងការធ្វើចំណាកស្រុក និងភាពរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់រូបភាព។
- វិធានការ**ជាគន្លឹះ** ជាបន្តបន្ទាប់ របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ **សម្រាប់ជំរុញការអនុវត្ត**យន្តការសម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់។
- មានសន្ធិសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងឧបករណ៍ច្បាប់នានា ដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខា ទទួលអនុវត្ត ជាពហុភាគី ទ្វេភាគី ជាមួយប្រទេសពាក់ព័ន្ធនានាក្នុងតំបន់ និងលើសកលលោក លើការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធនានា។
- ការលើកកម្ពស់ការអនុវត្តច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើន គឺជាមូលដ្ឋានបង្អែករឹងមាំសម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការសង្គមស៊ីវិលវិស័យឯកជន បានរួមគ្នាជាកម្លាំងស្នូល និងបានបង្កើនសមត្ថភាពបំពេញភារកិច្ចយ៉ាងសកម្ម ដើម្បីក្លាយទៅជាប្រព័ន្ធសុវត្ថិភាពដ៏រឹងមាំសម្រាប់ការពារសុវត្ថិភាពជនគ្រប់រូប ទាំងបុរស ស្ត្រី យុវវ័យ និងកុមារ ពីអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

ខ. ចំណុចប្រឈម និងចំណុចខ្វះខាត

ទន្ទឹមនឹងចំណុចខ្លាំងដែលយើងមាន ក៏នៅមានចំណុចប្រឈម និងចំណុចខ្វះខាតមួយចំនួនដូចជា ៖

- ប្រជាពលរដ្ឋ នៅតែបន្តចាញ់ឧបាយកលជនឧក្រិដ្ឋដែលមានល្បិចកលខ្ពស់ និងមានបណ្តាញប្រទាក់ក្រឡាយ៉ាងស្មុគស្មាញ ក្នុងការកេងប្រវ័ញ្ច និងជួញដូរមនុស្ស។

- ការត្រួតពិនិត្យ និងគ្រប់គ្រងពលករចំណាកស្រុកតាមច្រកព្រំដែន មិនទាន់បានល្អ ដែលបន្តឲ្យមានភាពរងគ្រោះ និងការខាតបង់នៅក្នុងប្រទេសគោលដៅមិនមានសេសសល់ផលកម្រៃពលកម្មឲ្យបានសក្តិសម និងមិនទាន់អាចទាញយកសក្តានុពលចំណូលពីពលកម្មក្រៅប្រទេសបានពេញលេញ។
- ការតាមដានស្ថានភាព និងគាំទ្រដល់ជនរងគ្រោះ ឬ អ្នកវិលត្រឡប់ពីការធ្វើទេសន្តរប្រវេសន៍ មិនទាន់ក្លាយជាប្រព័ន្ធនៅឡើយ។
- មន្ត្រីមួយចំនួនទើបផ្លាស់ប្តូរតួនាទី ត្រូវការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែមទៀត ដើម្បីអាចទទួលខុសត្រូវ អនុវត្តការងារជំនាញដែលខ្លួនទទួលខុសត្រូវឲ្យមានប្រសិទ្ធភាព។
- ការផ្តល់ព័ត៌មាន និងការបញ្ជូនរបាយការណ៍ របស់ក្រសួង ស្ថាប័ន អង្គភាព និងលេខាធិការដ្ឋានខេត្តមួយចំនួន នៅតែយឺតយ៉ាវ មិនទាន់ហេតុការណ៍។
- រាជធានី-ខេត្ត អង្គភាព ស្ថាប័នមួយចំនួន មិនទាន់បានត្រៀមផែនការសកម្មភាព និងថវិកាច្បាស់លាស់នៅឡើយ។
- ត្រូវការយុទ្ធសាស្ត្រនៃការបង្កា ទប់ស្កាត់ ដើម្បីបានជ្រួតជ្រាប និងអនុវត្តក្នុងការកែប្រែទស្សនៈ និងការគិតងាយក្នុងការធ្វើចំណាកស្រុក។
- ជនទេសន្តរប្រវេសន៍ខុសច្បាប់ ត្រូវបានឃាត់ខ្លួន ដកហូត ផាកពិន័យ ជួញដូរ កេងប្រវ័ញ្ច។ល។
- ការដោះស្រាយផ្តល់ភាពស្របច្បាប់ក្នុងប្រទេសគោលដៅ គឺជាដំណោះស្រាយបណ្តោះអាសន្ន មិនអាចបន្តជារៀងរហូតទេ។
- ការបង្ក្រាប បណ្តាញជនល្មើស ដែលមានភាពប្រទាក់ក្រឡា ពីប្រទេសមួយទៅប្រទេសមួយ មិនអាចធ្វើបាន ដោយគ្មានកិច្ចសហការល្អរវាងប្រទេសពាក់ព័ន្ធឡើយ។
- ការរីកដុះដាលឡើងវិញនូវសេវាកម្សាន្ត **"ភ្លើងពណ៌"** ដែលជាប្រភពនៃការជួញដូរផ្លូវភេទ។
- ផលប៉ះពាល់លើកុមារដែលនៅក្នុងគ្រួសារជនទេសន្តរប្រវេសន៍ មានទំហំកាន់តែធំ ទោះបីជាកុមារទាំងនោះត្រូវបានឪពុកម្តាយដែលធ្វើទេសន្តរប្រវេសន៍បោះបង់ឲ្យ រស់នៅជាមួយអ្នកជិតខាងសាច់ញាតិ ឬចាស់ទុំក្តី ឬទៅតាមឪពុកម្តាយនៅពេលធ្វើទេសន្តរប្រវេសន៍ក្តី ព្រោះ ក្មេងទាំងនោះ នឹងមិនមាន ឱកាសទទួលបានការរៀនសូត្រ ថែទាំសុខភាព និងសុវត្ថិភាព ដូចក្មេងដទៃឡើយ។
- ការសាងសង់មណ្ឌលសំចត នៅតាមបណ្តាច្រកព្រំដែនសំខាន់ៗ ដើម្បីទទួលពលករ និងត្រៀមដោះស្រាយបញ្ហាពលករ នៅយឺតយ៉ាវ មិនទាន់ដំណើរការ។

គ.សន្និដ្ឋាន

យុទ្ធសាស្ត្រទាំងបួន ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតែមានសារៈសំខាន់ក្នុងការអនុវត្ត។ លើសពីនេះទៅទៀត គណៈកម្មាធិការជាតិ គ្រប់លំដាប់ថ្នាក់ ចាំបាច់ត្រូវបន្តពង្រឹងយន្តការ ទាំងសមត្ថភាពយល់ដឹង ជំនាញ ការតាមដាន ការគ្រប់គ្រងសភាពការណ៍ ការគ្រប់គ្រងទិន្នន័យ និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នអនុវត្ត និងកិច្ចសហការជាមួយប្រទេសពាក់ព័ន្ធ ជាពិសេស រវាងប្រទេសបញ្ជូន និងប្រទេសគោលដៅ គឺជាកត្តាចាំបាច់ និងគន្លឹះមិនអាចខ្វះបាន ដើម្បីអាចឆ្លើយតប និងដោះស្រាយបញ្ហាភាពរងគ្រោះរបស់ប្រជាពលរដ្ឋ ពីអំពើកេងប្រវ័ញ្ច និងជួញដូរមនុស្សបាន។

IV.ទិសដៅឆ្នាំ២០១៨

ដើម្បីធ្វើឲ្យសម្រេចគោលដៅនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ឆ្នាំ២០១៨ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដាក់ចេញនូវទិសដៅដូចខាងក្រោម៖

ក.ការងារសហប្រតិបត្តិការ៖

១. ប្រមូល និងចងក្រងលិខិតុបករណ៍ជាតិ ឯកសារកិច្ចព្រមព្រៀងទ្វេភាគី-ពហុភាគី ជាមួយបណ្តាប្រទេសនានា ដែលពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

២. ត្រៀមចុះហត្ថលេខា និងអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា និងជំរុញការអនុវត្តជាមួយប្រទេសពាក់ព័ន្ធដទៃទៀតដែលមានអនុស្សរណៈ ឬ កិច្ចព្រមព្រៀងជាមួយកម្ពុជា។

៣. ត្រៀមកិច្ចប្រជុំ ប្រចាំឆ្នាំលើកទី២ កម្ពុជា-ចិន នៅរាជធានីភ្នំពេញ។

៤. ក្រុមការងារខេមមីតកម្ពុជា ត្រៀមចូលរួមកិច្ចប្រជុំពិនិត្យសម្រេចលើកិច្ចព្រមព្រៀងទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសម៉ាឡេស៊ី(ខែមេសា ឆ្នាំ២០១៨)។

៥. ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាប្រទេសនានា ក្នុងតំបន់ និងក្នុងពិភពលោក ដើម្បីធ្វើឲ្យការងារបង្ការទប់ស្កាត់ បង្ក្រាប សង្គ្រោះ និងការពារជនរងគ្រោះ និងជនងាយរងគ្រោះពីអំពើជួញដូរមនុស្សគ្រប់រូបភាពអាចទទួលបានជោគជ័យ។

៦. រៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន(កម្ពុជា ឡាវ ភូមា) និងប្រទេសទទួល (ថៃ) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

ខ.ការងារបង្ការ ទប់ស្កាត់៖

១. បន្តជំរុញយុទ្ធនាការប្រឆាំងការជួញដូរមនុស្ស ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព ដោយប្រើគ្រប់លទ្ធភាព និងធនធានដើម្បីលើកកម្ពស់ការយល់ដឹងជាសាកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ដើម្បីបញ្ជ្រាបការយល់ដឹងជាប្រចាំតាមរយៈវេទិកាសហគមន៍នានាឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យក្នុង និងក្រៅសាលារៀនដែលងាយរងគ្រោះ។

២. រៀបចំយន្តការអន្តរស្ថាប័ន និង“**វិធានការគ្រប់គ្រងលំហូរមិនប្រក្រតីឆ្លងកាត់ព្រំដែនរបស់ប្រជាពលរដ្ឋ**” និងលើកកម្ពស់ទេសន្តរប្រវេសន៍ដែលមានសុវត្ថិភាព រៀបរយ និងស្របច្បាប់ (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ)។

៣. បង្កើតយុទ្ធសាស្ត្របង្ការ ទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងដោយជំរុញអនុវត្តតាមគោលដៅអាទិភាព។

គ.ការងារការពារជនរងគ្រោះ៖

១. បន្តសកម្មភាពបណ្តុះបណ្តាល មន្ត្រីមានសមត្ថកិច្ចកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ។

២. តាមដាន និងចងក្រងទិន្នន័យជនរងគ្រោះ ដោយសហការជាមួយអង្គភាព ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូនានា ក្នុងរាជធានី-ខេត្តគោលដៅ បង្កើតក្រុមអភិឌ្ឍន៍ខ្លួនឯង និងលើកវិធានការផ្តល់កិច្ចការពារ ឬគម្រោងនានា ដើម្បីបង្ការ ទប់ស្កាត់ការវិលត្រឡប់ទៅរងគ្រោះជាថ្មី។

៣. ចុះតាមដាន វាយតម្លៃ និងចងក្រងបទពិសោធន៍ល្អៗក្នុងការអនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹងកិច្ចការពារ និងអភិវឌ្ឍន៍ជនរងគ្រោះ។

ឃ.ការងារអនុវត្តច្បាប់ និងកិច្ចការយុត្តិធម៌៖

១. បន្តកិច្ចសហការជាមួយសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីស្រាវជ្រាវ ស៊ើបអង្កេតរកបទល្មើស ឧក្រិដ្ឋជន និងអ្នកពាក់ព័ន្ធ ដើម្បីផ្តន្ទាទោសតាមច្បាប់ និងពង្រឹងការអនុវត្តច្បាប់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព។

២. បន្តបណ្តុះបណ្តាលមន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស នៅសាលាបណ្ឌិត្យសភានគរបាល និងសាលានគរបាលភូមិភាគ នូវមេរៀនស្តីពី នីតិវិធីនៃការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស ដែលបានដាក់បញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលរួចហើយ។

៣. ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់តាមបណ្តារាជធានី-ខេត្ត ដើម្បីជំរុញការស៊ើបអង្កេត និងបង្រ្កាបឲ្យមានប្រសិទ្ធភាព។

៤. ជំរុញការអនុម័តច្បាប់ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA) និងពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

៥. ជំរុញការអនុម័តច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**" និង ជំរុញការចុះហត្ថលេខាលើសន្ធិសញ្ញាទ្វេភាគី **ស្តីពី** "**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" ជាមួយសាធារណរដ្ឋប្រជាមានិតឡាវ សាធារណរដ្ឋបារាំង និងសាធារណរដ្ឋកូរ៉េ។

ង.ការងារគាំទ្រ និងតាមដានត្រួតពិនិត្យ៖

១. គាំទ្រ និងពង្រឹងសមត្ថភាពដល់មន្ត្រីជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដើម្បីពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ លេខាធិការដ្ឋានរាជធានី-ខេត្ត និងក្រុមការងារ ទាំង៦។

២. រៀបចំផែនការយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល៥ឆ្នាំ (២០១៩-២០២៣) និងផែនការសកម្មភាពប្រចាំឆ្នាំ២០១៩។

៣. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគីដែលបានចុះហត្ថលេខារួចហើយ និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែលសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៤. ជំរុញតាមដាន ត្រួតពិនិត្យក្រុមហ៊ុនដែលបានបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៥. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល។

ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្តឲ្យមានប្រសិទ្ធភាព សម្រាប់ដំណាក់កាលដ៏ចាំបាច់៖

១. ជំរុញអនុវត្តវិធានការដោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។

២. ស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ក្នុងស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា ទំនាក់ទំនងអប់រំ និងផ្តល់សេវា។

៣. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនពលករត្រឡប់ពីប្រទេសថៃ ដោយមានមន្ត្រីប្រចាំការសម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្នមុនបានចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពពលករជាដើម។

ថ្ងៃ សុក្រ ៨រោច ខែ ផល្គុន ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០១៨

អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

ជូ_ប៊ុនអេង

ចម្លងជូន

- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជ្រាបជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ គ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

-លេខាធិការដ្ឋាន គ.រ.ប.ជ/ គ.ខ.ប.ជ

"ដើម្បីជូនជ្រាប និងផ្សព្វផ្សាយ"

-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១

សកម្មភាពផ្សព្វផ្សាយ ឆ្នាំ២០១៧

ល.រ	របាយការណ៍ពី	ខ្លឹមសារសកម្មភាព	អង្គភាព-ស្ថាប័នអ្នករៀបចំ	ចំនួនលើក	ចំនួនមនុស្ស	ចំនួនស្រី
1	ក្រសួងកិច្ចការនារី	វេទិកាសាធារណៈ ស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ប្រជាជនក្នុងឃុំចំនួន១២ឃុំ មានខេត្តឧត្តរមានជ័យ (ស្រុកអន្លង់វែង) ខេត្តព្រះវិហារ(ស្រុករវៀង) ខេត្តកោះកុង (ស្រុកស្រែអំបិល) និងស្រុកស្វាយរៀង ។	ក្រសួងកិច្ចការនារី និង មន្ទីរកិច្ចការនារីខេត្ត	4 លើក	644 នាក់	430 នាក់
2	ក្រសួងអប់រំ យុវជននិងកីឡា	បានធ្វើមីទិញផ្សព្វផ្សាយពីទស្សនាទានរបស់ក្រសួង ស្ដីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដើម្បីធានាបានសិទ្ធិរស់រានរបស់កុមារ នៅតាមគ្រឹះស្ថានសិក្សាចំនួន១០៤៩។	ក្រសួងអប់រំ យុវជន និងកីឡា	1,049 លើក	524,500 នាក់	209,800 នាក់
3	កាកបាទក្រហម	បានបញ្ជ្រាបការងារផ្សព្វផ្សាយអំពីប្រធានបទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និង វិធានការទប់ស្កាត់ ការជួញដូរមនុស្សនៅ តាមសហគមន៍គោលដៅរបស់គម្រោងសុវត្ថិភាព F5	កាកបាទក្រហម ខេត្ត ពោធិ៍ សាត់ និងខេត្តវិហារ	25 លើក	17,523 នាក់	17,529 នាក់
4	ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	ផ្សព្វផ្សាយដល់បណ្ដាញការងារជាតិ និងថ្នាក់ក្រោមជាតិ ស្ដីពីហេតុផលដែលនាំឱ្យមានការជួញ ដូរមនុស្ស ដែលមានខេត្តព្រះសីហនុ ត្បូងឃ្មុំ ស្ទឹងត្រែង បាត់ដំបង ប៉ៃលិន ស្វាយរៀង នៅទីស្ដី ការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។	ក្រសួងឧស្សាហកម្ម និង សិប្បកម្ម	1 លើក	291 នាក់	91 នាក់
5	ក្រុមការងារ អនុវត្តន៍ច្បាប់	ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។	ស្នងការដ្ឋាននគរបាលខេត្ត	6,706 លើក	737,405 នាក់	282,986 នាក់
6	ខេត្តកណ្ដាល	វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។	ស្នងការដ្ឋាននគរបាលខេត្ត	1,972 លើក	197,765 នាក់	83,273 នាក់
		ផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និងបញ្ជ្រាបការយល់ដឹងអំពើជួញដូរមនុស្សតាមវិទ្យាល័យ អនុវិទ្យាល័យសាលារៀន ដល់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។	លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារី មន្ទីរអប់រំយុវជន និងកីឡាខេត្ត	167 លើក	19,774 នាក់	13,012 នាក់
7	ខេត្តពោធិ៍សាត់	វេទិកាសាធារណៈ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស នៅតាមឃុំ សង្កាត់ទូទាំងខេត្ត ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ស្រុកក្រគរ និងស្រុកភ្នំក្រវាញ។	ស្នងការដ្ឋាននគរបាលខេត្ត	427 លើក	34,855 នាក់	16,629 នាក់
		ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាព ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាក ស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ និងបញ្ជ្រាបការយល់ដឹងអំពើជួញដូរមនុស្ស នៅតាមវិទ្យាល័យ អនុវិទ្យាល័យសាលារៀន ដល់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។	លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំយុវជន និងកីឡាខេត្ត	3,120 លើក	469,361 នាក់	276,753 នាក់

ល.រ	របាយការណ៍ពី	ខ្លឹមសារសកម្មភាព	អង្គភាព-ស្ថាប័នអ្នករៀបចំ	ចំនួនលើក	ចំនួនមនុស្ស	ចំនួនស្រី
8	ខេត្តបាត់ដំបង	វេទិកាសាធារណៈ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។	លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត	3,078 លើក	121,957 នាក់	63,257 នាក់
		ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត	7,649 លើក	617,890 នាក់	296,032 នាក់
9	ខេត្តសៀមរាប	វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត	45 លើក	14,161 នាក់	6,246 នាក់
		ផ្សព្វផ្សាយ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ នីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងអ្នកស្ម័គ្រចិត្តយុវជនកាកបាទក្រហម។	លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារី មន្ទីរអប់រំ និងកាកបាទក្រហមកម្ពុជា	3,081 លើក	199,801 នាក់	114,398 នាក់
10	ខេត្តកំពង់ឆ្នាំង	វេទិកាសាធារណៈផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋ ស្ដីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត	4,633 លើក	511,328 នាក់	226,164 នាក់
		ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងវគ្គផ្សព្វផ្សាយ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ។	លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត	7,532 លើក	460,991 នាក់	253,063 នាក់
11	ខេត្តកំពត	វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត	3,242 លើក	149,417 នាក់	73,874 នាក់
		ផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងបញ្ជ្រាបការយល់ដឹងអំពើជួញដូរមនុស្ស តាមវិទ្យាល័យ អនុវិទ្យាល័យសាលារៀន ដល់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។	លេខាធិការដ្ឋាន គ.ខ.ប.ជ ក្រុមការងារទាំង៦ខេត្ត មន្ទីរអប់រំយុវជន និងកីឡាខេត្ត	3,455 លើក	190,742 នាក់	102,480 នាក់
12	ខេត្តព្រះសីហនុ	វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ នូវច្បាប់ស្ដីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។	ស្នងការដ្ឋាននគរបាលខេត្ត	21 លើក	2,289 នាក់	1,287 នាក់
		ផ្សព្វផ្សាយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ កិច្ចការពារជនរងគ្រោះ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរទេសចរណ៍ មន្ទីរការងារ និងមន្ទីរកិច្ចការនារីខេត្ត	103 លើក	13,936 នាក់	10,171 នាក់

ល.រ	របាយការណ៍ពី	ខ្លឹមសារសកម្មភាព	អង្គភាព-ស្ថាប័នអ្នករៀបចំ	ចំនួនលើក	ចំនួនមនុស្ស	ចំនួនស្រី
13	ខេត្តតាកែវ	វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស និងការទប់ស្កាត់ ការជួញដូរកម្លាំងពលកម្មកុមារ ដល់ប្រជាពលរដ្ឋនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក ។	ស្នងការដ្ឋាននគរបាលខេត្ត	264 លើក	5,826 នាក់	2,245 នាក់
		ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត	224 លើក	23,098 នាក់	6,301 នាក់
14	ខេត្តរតនគិរី	វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជស្នងការដ្ឋាននគរបាលខេត្ត	101 លើក	11,141 នាក់	4,067 នាក់
		ផ្សព្វផ្សាយ ស្តីពីច្បាប់ការងារ ច្បាប់អាពាហ៍ពិពាហ៍ និងការប្រឆាំងទប់ស្កាត់រាល់ទម្រង់ពលកម្មលើកុមារ ទៅដល់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន សិប្បកម្ម និងតាមសាលារៀននានាក្នុងខេត្ត។	មន្ទីរការងារ មន្ទីរកិច្ចការនារី និងមន្ទីរអប់រំខេត្ត	129 លើក	4,190 នាក់	270 នាក់
15	ខេត្តកំពង់ចាម	វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។	លេខាធិការដ្ឋាន គ.ខ.ប.ជស្នងការដ្ឋាននគរបាលខេត្ត	312 លើក	12,498 នាក់	2,690 នាក់
		ផ្សព្វផ្សាយ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។	លេខាធិការដ្ឋាន គ.ខ.ប.ជ និងស្នងការដ្ឋាននគរបាលខេត្ត	1,225 លើក	116,204 នាក់	59,112 នាក់
16	ខេត្តព្រៃវែង	វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ នូវច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុក ដោយសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជស្នងការដ្ឋាននគរបាលខេត្ត	4 លើក	454 នាក់	285 នាក់
		ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជ	4 លើក	321 នាក់	225 នាក់
17	ខេត្តត្បូងឃ្មុំ	វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជ	108 លើក	5,277 នាក់	2,526 នាក់
		ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និង ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់សិស្សានុសិស្ស លោកគ្រូអ្នកគ្រូ និងក្រុមប្រឹក្សាយុវជន។	លេខាធិការដ្ឋាន គ.ខ.ប.ជមន្ទីរអប់រំ យុវជន និងកីឡាខេត្ត	9 លើក	10,732 នាក់	7,191 នាក់
18	ខេត្តស្វាយរៀង	វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស។	លេខាធិការដ្ឋាន គ.ខ.ប.ជស្នងការដ្ឋាននគរបាលខេត្ត	3,035 លើក	135,047 នាក់	70,243 នាក់
		ផ្សព្វផ្សាយដល់ពលករ ពលការិនី ស្តីពីការធ្វើចំណាកស្រុកស្វែងរកការងារធ្វើប្រកបដោយសុវត្ថិភាព នៅតាមបណ្តារោងចក្រក្នុងក្រុងបាវិត។	មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត	8 លើក	757 នាក់	350 នាក់

ល.រ	របាយការណ៍ពី	ខ្លឹមសារសកម្មភាព	អង្គភាព-ស្ថាប័នអ្នករៀបចំ	ចំនួនលើក	ចំនួនមនុស្ស	ចំនួនស្រី
19	ខេត្តកោះកុង	វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។	លេខាធិការដ្ឋាន គ.ខ.ប.ជស្នងការដ្ឋាននគរបាលខេត្ត	221 លើក	12,731 នាក់	1,882 នាក់
		ផ្សព្វផ្សាយ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងបញ្ជ្រាបពីការជួញដូរមនុស្ស ក្នុងពិធីបើកបវេសនកាលនៅតាមវិទ្យាល័យ ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស មន្ត្រីរាជការ និងប្រជាពលរដ្ឋ។	លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំយុវជន និងកីឡាខេត្ត	6 លើក	3,010 នាក់	គ្មាន
20	ខេត្តកំពង់ស្ពឺ	ផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ សិស្សានុសិស្ស នៅតាមសាលារៀនទូទាំងខេត្ត ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស ការធ្វើអាជីកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំយុវជន និងកីឡាខេត្ត	311 លើក	191,568 នាក់	85,469 នាក់
		វេទិកាសាធារណៈ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុក ដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។	លេខាធិការដ្ឋាន គ.ខ.ប.ជ	1 លើក	75 នាក់	50 នាក់
21	ខេត្តកែប	ផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស កិច្ចការការពារជនរងគ្រោះ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។	លេខាធិការដ្ឋាន គ.ខ.ប.ជ លេខាធិការដ្ឋាន គ.ខ.ប.ជ	5 លើក	681 នាក់	434 នាក់
		ផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវេទិកាផ្សព្វផ្សាយ ស្តីពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។	ស្នងការដ្ឋាននគរបាលខេត្ត	388 លើក	73,544 នាក់	37,629 នាក់
22	ខេត្តព្រះវិហារ	ផ្សព្វផ្សាយ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។	លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត ស្នងការដ្ឋាននគរបាលខេត្ត	21 លើក	4,414 នាក់	2,646 នាក់
23	ខេត្តប៉ៃលិន	ផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីវិធានការទប់ស្កាត់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមសាលារៀន សហគមន៍មូលដ្ឋាន ដល់ប្រជាពលរដ្ឋ។	លេខាធិការដ្ឋាន គ.ខ.ប.ជ	40 លើក	1,167 នាក់	460 នាក់
24	ខេត្តឧត្តរមានជ័យ	ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្ស ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ កិច្ចការការពារជនរងគ្រោះ យន្តការទេសន្តប្រវេសន៍ ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជ	43 លើក	6,677 នាក់	3,175 នាក់
25	ខេត្តបន្ទាយមានជ័យ	វេទិកាសាធារណៈ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុក ដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ នៅឃុំតាប៉ែន ឃុំតាផូ ឃុំទ្រាស ឃុំផ្គាំ ស្រុកស្វាយចេក។	លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត	4 លើក	998 នាក់	759 នាក់

ល.រ	របាយការណ៍ពី	ខ្លឹមសារសកម្មភាព	អង្គភាព-ស្ថាប័នអ្នករៀបចំ	ចំនួនលើក	ចំនួនមនុស្ស	ចំនួនស្រី
26	ខេត្តកំពង់ធំ	ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងកិច្ចការពារជនរងគ្រោះ និងបញ្ជ្រាបការយល់ដឹងអំពើជួញដូរមនុស្ស តាមវិទ្យាល័យ អនុវិទ្យាល័យ សាលារៀន ដល់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។	លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំយុវជន និងកីឡាខេត្ត	59 លើក	34,544 នាក់	17,157 នាក់
27	ខេត្តស្ទឹងត្រែង	ផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីកម្មផ្លូវភេទការធ្វើចំណាកស្រុកដោយសុវត្ថិភាព។	លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត	3 លើក	698 នាក់	539 នាក់
28	ខេត្តក្រចេះ	ផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ កិច្ចការការពារជនរងគ្រោះ ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដល់ប្រជាពលរដ្ឋ។	លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត	28 លើក	4,257 នាក់	2,832 នាក់
29	ខេត្តមណ្ឌលគិរី	ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងកិច្ចការការពារជនរងគ្រោះ តាមវិទ្យាល័យ អនុវិទ្យាល័យសាលារៀន ដល់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។	មន្ទីរអប់រំយុវជន និងកីឡាខេត្ត	16 លើក	15,399 នាក់	7,779 នាក់

សកម្មភាពសរុបចំនួន: 52,879 លើក

មនុស្សសរុបចំនួន: 4,959,938 នាក់

ស្រីសរុបចំនួន : 2,363,791 នាក់

ឧបសម្ព័ន្ធទី១

តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយ និងវេទិកាគោលនយោបាយភូមិឃុំមានសុវត្ថិភាព(ទិន្នន័យពីបណ្តាក្រសួង.ស្ថាប័ន រាជធានី.ខេត្ត)

ល.រ	ក្រសួង.ស្ថាប័ន រាជធានី.ខេត្ត	ការផ្សព្វផ្សាយ			វេទិកាសាធារណៈ		
	ក្រសួង.ស្ថាប័ន	ចំនួនដង/លើក	សរុបអ្នកចូលរួម	ចំនួនស្ត្រី	ចំនួនដង/លើក	សរុបអ្នកចូលរួម	ចំនួនស្ត្រី
១	ក្រសួងកិច្ចការនារី	មិនមានរបាយការណ៍			៤	៦៤៤	៤៣០
២	ក្រសួងអប់រំ យុវជន និងកីឡា	១,០៤៩	៥២៤,៥០០	២០៩,៨០០	មិនមានរបាយការណ៍		
៣	កាកបាទក្រហម	២៥	១៧,៥២៣	១៧,៥២៩	មិនមានរបាយការណ៍		
៤	ក្រសួងឧស្សាហកម្ម និងសិប្បកម្ម	១	២៩១	៩១	មិនមានរបាយការណ៍		
៥	អគ្គស្នងការដ្ឋាននគរបាលជាតិ	៦,៧០៦	៧៣៧,៤០៥	២៨២,៩៨៦	មិនមានរបាយការណ៍		
	រាជធានី-ខេត្ត						
១	ព្រះសីហនុ	១០៣	១៣,៩៣៦	១០,១៧១	២១	២,២៨៩	១,២៨៧
២	កំពត	៣,៤៥៥	១៩០,៧៤២	១០២,៤៨០	៣,២៤២	១៤៩,៤១៧	៧៣,៨៧៤
៣	កែប	៣៨៨	៧៣,៥៤៤	៣៧,៦២៩	៥	៦៨១	៤៣៤
៤	តាកែវ	២២៤	២៣,០៩៨	៦,៣០១	២៦៤	៥,៨២៦	២,២៤៥
៥	កណ្តាល	១៦៧	១៩,៧៧៤	១៣,០១២	១,៩៧២	១៩៧,៧៦៥	៨៣,២៧៣
៦	ស្វាយរៀង	៨	៧៥៧	៣៥០	៣,០៣៥	១៣៥,០៤៧	៧០,២៤៣
៧	ព្រៃវែង	៤	៣២១	២២៥	៤	៤៥៤	២៨៥
៨	កំពង់ស្ពឺ	៣១១	១៩១,៥៦៨	៨៥,៤៦៩	១	៧៥	៥០
៩	កោះកុង	៦	៣,០១០	គ្មាន	២២១	១២,៧៣១	១,៨៨២
១០	ប៉ៃលិន	៤០	១,១៦៧	៤៦០	មិនមានរបាយការណ៍		

១១	ឧត្តរមានជ័យ	៤៣	៦,៦៧៧	៣,១៧៥	មិនមានរបាយការណ៍		
១២	បន្ទាយមានជ័យ	មិនមានរបាយការណ៍			៤	៩៩៨	៧៥៩
១៣	បាត់ដំបង	៧,៦៤៩	៦១៧,៨៩០	២៩៦,០៣២	៣,០៧៨	១២១,៩៥៧	៦៣,២៥៧
១៤	ពោធិ៍សាត់	៣,១២០	៤៦៩,៣៦១	២៧៦,៧៥៣	៤២៧	៣៤,៨៥៥	១៦,៦២៩
១៥	កំពង់ឆ្នាំង	៧,៥៣២	៤៦០,៩៩១	២៥៣,០៦៣	៤,៦៣៣	៥១១,៣២៨	២២៦,១៦៤
១៦	កំពង់ធំ	៥៩	៣៤,៥៥៤	១៧,១៥៧	មិនមានរបាយការណ៍		
១៧	សៀមរាប	៣,០៨១	១៩៩,៨០១	១១៤,៣៩៨	៤៥	១៤,១៦១	៦,២៤៦
១៨	ព្រះវិហារ	២១	៤,៤១៤	២,៦៤៦	មិនមានរបាយការណ៍		
១៩	រតនគិរី	១២៩	៤,១៩០	២៧០	១០១	១១,១៤១	៤,០៦៧
២០	ស្ទឹងត្រែង	៣	៦៩៨	៥៣៩	មិនមានរបាយការណ៍		
២១	ក្រចេះ	២៨	៤,២៥៧	២,៨៣២	មិនមានរបាយការណ៍		
២២	កំពង់ចាម	១,២២៥	១១៦,២០៤	៥៩,១១២	៣១២	១២,៤៩៨	២,៦៩០
២៣	ត្បូងឃ្មុំ	៩	១០,៧៣២	៧,១៩១	១០៨	៥,២៧៧	២,៥២៦
២៤	មណ្ឌលគិរី	១៦	១៥,៣៩៩	៧,៧៧៩	មិនមានរបាយការណ៍		
២៥	រាជធានីភ្នំពេញ		មិនមានរបាយការណ៍				
សរុប		៣៥,៤០២	៣,៧៤២,៨០៤	១,៨០៧,៤៥០	១៧,៤៧៧	១,២១៧,១៣៤	៥៥៦,៣៤១
សរុបរួមការផ្សព្វផ្សាយថ្នាក់ជាតិ ក្រសួង.ស្ថាប័ន និងថ្នាក់ក្រោមជាតិ រាជធានី.ខេត្ត		*៥២,៨៧៩លើក*		*៤,៩៥៩,៩៣៨នាក់*		*២,៣៦៣,៧៩១នាក់*	

ឧបសម្ព័ន្ធ៣

លទ្ធផលបង្ក្រាបបទល្មើសអាជីវកម្មផ្លូវភេទ និងអំពើជួញដូរមនុស្ស ទូទាំងប្រទេស (ប្រចាំឆ្នាំ ២០១៧)
គិតចាប់ពីថ្ងៃទី ២៦-១២-២០១៦ ដល់ថ្ងៃទី ២៥-១២-២០១៧

ល.រ	នាយកដ្ឋាន រាជធានី-ខេត្ត	បង្ក្រាបរួម								ជួញដូរមនុស្ស								អាជីវកម្មផ្លូវភេទ								បញ្ជូនជនរងគ្រោះទៅ		
		បង្ក្រាប	ជនល្មើស			ជនរងគ្រោះ				បង្ក្រាប	ជនល្មើស			ជនរងគ្រោះ				បង្ក្រាប	ជនល្មើស			ជនរងគ្រោះ						
			រួម	ស្រី	បរទេស	រួម	-15	15-17	18+		រួម	ស្រី	បរទេស	រួម	-15	15-17	18+		រួម	ស្រី	បរទេស	រួម	-15	15-17	18+	មន្ទីរសង្គមកិច្ច	អង្គការ	គ្រួសារ
1	បន្ទាយមានជ័យ	1	1							1	1																	
2	បាត់ដំបង	23	25	2		23	23	0		2	2	2		1	1			21	23			22	22					23
3	កំពង់ចាម	3	3	2		3		1	2	3	3	2		3		1	2											3
4	កំពង់ឆ្នាំង	2	2			2	2											2	2			2	2					2
5	កំពង់ស្ពឺ		0																									
6	កំពង់ធំ	3	8	2		17		1	16	3	8	2		17		1	16									9		8
7	កំពត	1	1			1		0										1	1			1	1					1
8	កណ្ដាល	8	8			9	8	1		1	1			2	1	1		7	7			7	7					9
9	កោះកុង	2	2			2	1	1		1	1			1		1		1	1			1	1					2
10	ក្រចេះ	9	16	11	1	10	4	1	5	6	11	9		7	2		5	3	5	2	1	3	2	1				10
11	មណ្ឌលគិរី	2	2			2	2											2	2			2	2					2
12	ភ្នំពេញ	30	39	21	3	57	16	11	30	9	16	10	3	15	4	5	6	21	23	11		42	12	6	24	31	5	21
13	ព្រះវិហារ	3	3	1		2	2			1	1	1						2	2			2	2					2
14	ព្រៃវែង		0																									
15	ពោធិ៍សាត់	1	1			1	1											1	1			1	1					1
16	រតនគិរី	3	3	2		3	1	1	1	2	2	2		2		1	1	1	1			1	1					3
17	សៀមរាប	18	19		3	38	36	2		1	2		1	2	1	1		17	17		2	36	35	1				38
18	ព្រះសីហនុ	9	14	2	9	17	6		11	2	2		1	5	1		4	7	12	2	8	12	5		7			17
19	ស្ទឹងត្រែង		0																									
20	ស្វាយរៀង	1	1			1		1		1	1			1		1												1
21	តាកែវ	4	4			15	11	1	3	2	2			13	9	1	3	2	2			2	2					15
22	ឧត្ដរមានជ័យ	1	1			1	1											1	1			1	1					1
23	កែប		0																									
24	ប៉ៃលិន	2	2			19	1		18	1	1			18			18	1	1			1	1					19
25	នាយកដ្ឋាន	19	27	14	4	81	4	13	64	6	11	5	3	21			21	13	16	9	1	60	4	13	43	56		25
26	កងរាជអាវុធហត្ថ	13	20	3	0	40	18	6	16	5	6	3		20	13	6	1	8	14			20	5		15	24		16
27	ត្បូងឃ្មុំ	1	1	1	0	1			1	1	1	1		1			1											1
	សរុបរួម	159	203	61	20	345	138	40	167	48	72	37	8	129	32	19	78	111	131	24	12	216	106	21	89	120	5	220

លទ្ធផលបង្ក្រាបបទល្មើស ជួញដូរមនុស្ស ទូទាំងប្រទេស (ប្រចាំឆ្នាំ ២០១៧)
គិតចាប់ពីថ្ងៃទី ២៦-១២-២០១៦ ដល់ថ្ងៃទី ២៥-១២-២០១៧

ល.រ	នាយកដ្ឋាន រាជធានី-ខេត្ត	បង្ក្រាបសរុប							
		បង្ក្រាប	ជនរងគ្រោះ				ជនល្មើស		
			សរុប	-15	15-17	18	សរុប	ប	ស
1	បន្ទាយមានជ័យ	1					1	1	
2	បាត់ដំបង	2	1	1			2		2
3	កំពង់ចាម	3	3		1	2	3	1	2
4	កំពង់ឆ្នាំង								
5	កំពង់ស្ពឺ								
6	កំពង់ធំ	3	17		1	16	8	6	2
7	កំពត								
8	កណ្ដាល	1	2	1	1		1	1	
9	កោះកុង	1	1		1		1	1	
10	ក្រចេះ	6	7	2		5	11	2	9
11	មណ្ឌលគិរី								
12	ភ្នំពេញ	9	15	4	5	6	16	6	10
13	ព្រះវិហារ	1					1		1
14	ព្រៃវែង								
15	ពោធិ៍សាត់								
16	រតនគិរី	2	2		1	1	2		2
17	សៀមរាប	1	2	1	1		2	2	
18	ព្រះសីហនុ	2	5	1		4	2	2	
19	ស្ទឹងត្រែង								
20	ស្វាយរៀង	1	1		1		1	1	
21	តាកែវ	2	13	9	1	3	2	2	
22	ឧត្តរមានជ័យ								
23	កែប								
24	ប៉ៃលិន	1	18			18	1	1	
25	នាយកដ្ឋាន	6	21			21	11	6	5
26	កងរាជអាវុធហត្ថ	5	20	13	6	1	6	3	3
27	ត្បូងឃ្មុំ	1	1			1	1		1
	សរុបរួម	48	129	32	19	78	72	35	37

ល.រ	នាយកដ្ឋាន រាជធានី-ខេត្ត	មាត្រា៩ ការនាំយកអនីតិជន ដោយ ទីចេញដោយមិនស្របច្បាប់						មាត្រា១០ ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ						មាត្រា១១ ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន					
		បង្ក្រាប	ជនរងគ្រោះ			ជនល្មើស		បង្ក្រាប	ជនរងគ្រោះ			ជនល្មើស		បង្ក្រាប	ជនរងគ្រោះ			ជនល្មើស	
			-15	15-17	18+	ប	ស		-15	15-17	18+	ប	ស		-15	15-17	18+	ប	ស
1	បន្ទាយមានជ័យ																		
2	បាត់ដំបង							1	1				1						
3	កំពង់ចាម	1		1		1		2			2		2						
4	កំពង់ឆ្នាំង																		
5	កំពង់ស្ពឺ																		
6	កំពង់ធំ							2		1	16	5	2	1				1	
7	កំពត																		
8	កណ្ដាល																		
9	កោះកុង	1		1		1													
10	ក្រចេះ							2	1				2	1	1		1		1
11	មណ្ឌលគិរី																		
12	ភ្នំពេញ	1		1			1	1					1	4	1	2	5	3	4
13	ព្រះវិហារ							1					1						
14	ព្រៃវែង																		
15	ពោធិ៍សាត់																		
16	រតនគិរី	1		1	1		1	1					1						
17	សៀមរាប																		
18	ព្រះសីហនុ	1	1			1													
19	ស្ទឹងត្រែង																		
20	ស្វាយរៀង	1		1		1													
21	តាកែវ							1			1	1							
22	ឧត្តរមានជ័យ																		
23	កែប																		
24	ប៉ៃលិន													1			18	1	
25	នាយកដ្ឋាន							2			7	1	2	2			4	1	2
26	កងរាជអាវុធហត្ថ	1		1		1		1		1		1		1		1	1		1
27	ត្បូងឃ្មុំ							1			1		1						
	សរុបរួម	7	1	6	1	5	2	15	2	2	27	8	13	10	2	3	29	6	8

ល.រ	នាយកដ្ឋាន រាជធានី-ខេត្ត	មាត្រា១២ ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច						មាត្រា១៤ អំពើលក់ដូរមនុស្ស						មាត្រា១៥ អំពើលក់ដូរមនុស្សដោយមានគោលដៅ						មាត្រា១៦ អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន						មាត្រា១៧ ការដឹកជញ្ជូនដោយមានគោលដៅ					
		បង្ក្រាប	ជនរងគ្រោះ			ជនល្មើស		បង្ក្រាប	ជនរងគ្រោះ			ជនល្មើស		បង្ក្រាប	ជនរងគ្រោះ			ជនល្មើស		បង្ក្រាប	ជនរងគ្រោះ			ជនល្មើស		បង្ក្រាប	ជនរងគ្រោះ			ជនល្មើស	
			-15	15-17	18+	ប	ស		-15	15-17	18+	ប	ស		-15	15-17	18+	ប	ស		-15	15-17	18+	ប	ស		-15	15-17	18+	ប	ស
1	បន្ទាយមានជ័យ																														
2	បាត់ដំបង													1					1												
3	កំពង់ចាម																														
4	កំពង់ឆ្នាំង																														
5	កំពង់ស្ពឺ																														
6	កំពង់ធំ																														
7	កំពត																														
8	កណ្ដាល																														
9	កោះកុង																														
10	ក្រចេះ																			3			4	2	6						
11	មណ្ឌលគិរី																														
12	ភ្នំពេញ													2		1	1	2	3												
13	ព្រះវិហារ																														
14	ព្រៃវែង																														
15	ពោធិ៍សាត់																														
16	រតនគិរី																														
17	សៀមរាប																														
18	ព្រះសីហនុ	1			4	1																									
19	ស្ទឹងត្រែង																														
20	ស្វាយរៀង																														
21	តាកែវ																														
22	ឧត្តរមានជ័យ																														
23	កែប																														
24	ប៉ៃលិន																														
25	នាយកដ្ឋាន	2			10	4	1																								
26	កងរាជអាវុធហត្ថ	2	13	3		1	2																								
27	ត្បូងឃ្មុំ																														
	សរុបរួម	5	13	3	14	6	3							3		1	1	2	4	3			4	2	6						

លទ្ធផលបង្ក្រាបបទល្មើស ជួញដូរមនុស្ស ទូទាំងប្រទេស (ប្រចាំឆ្នាំ ២០១៧)
គិតចាប់ពីថ្ងៃទី ២៦-១២-២០១៦ ដល់ថ្ងៃទី ២៥-១២-២០១៧

ល.រ	នាយកដ្ឋាន រាជធានី-ខេត្ត	មាត្រា១៨						មាត្រា១៩						មាត្រា២០					
		អំពើនាំឆ្លងដែន						ការទទួលយកមនុស្ស ដោយមានគោលដៅ						ការទទួលយកមនុស្ស ដោយមានគោលដៅជួយ ដល់ជនល្មើស					
		បណ្តឹង	ជនរងគ្រោះ			ជនល្មើស		បណ្តឹង	ជនរងគ្រោះ			ជនល្មើស		បណ្តឹង	ជនរងគ្រោះ			ជនល្មើស	
			-15	15-17	18+	ប	ស		-15	15-17	18+	ប	ស		-15	15-17	18+	ប	ស
1	បន្ទាយមានជ័យ	1				1													
2	បាត់ដំបង																		
3	កំពង់ចាម																		
4	កំពង់ឆ្នាំង																		
5	កំពង់ស្ពឺ																		
6	កំពង់ធំ																		
7	កំពត																		
8	កណ្ដាល																		
9	កោះកុង																		
10	ក្រចេះ																		
11	មណ្ឌលគិរី																		
12	ភ្នំពេញ																		
13	ព្រះវិហារ																		
14	ព្រៃវែង																		
15	ពោធិ៍សាត់																		
16	រតនគិរី																		
17	សៀមរាប																		
18	ព្រះសីហនុ																		
19	ស្ទឹងត្រែង																		
20	ស្វាយរៀង																		
21	តាកែវ																		
22	ឧត្ដរមានជ័យ																		
23	កែប																		
24	ប៉ៃលិន																		
25	នាយកដ្ឋាន																		
26	គងរាជអាវុធហត្ថ																		
27	ត្បូងឃ្មុំ																		
	សរុបរួម	1				1													

ល.រ	នាយកដ្ឋាន រាជធានី-ខេត្ត	មាត្រា៣៤						មាត្រា៣៥						មាត្រា៣៦					
		ការទិញពេស្យាចារកុមារ						អំពើអូសទាញពេស្យាចារកុមារ						ការអោយខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងទៅនឹងអំពើពេស្យាចារកុមារ					
		បណ្តឹង	ជនរងគ្រោះ			ជនល្មើស		បណ្តឹង	ជនរងគ្រោះ			ជនល្មើស		បណ្តឹង	ជនរងគ្រោះ			ជនល្មើស	
			-15	15-17	18+	ប	ស		-15	15-17	18+	ប	ស		-15	15-17	18+	ប	ស
1	បន្ទាយមានជ័យ																		
2	បាត់ដំបង																		
3	កំពង់ចាម																		
4	កំពង់ឆ្នាំង																		
5	កំពង់ស្ពឺ																		
6	កំពង់ធំ																		
7	កំពត																		
8	កណ្ដាល	1	1	1		1													
9	កោះកុង																		
10	ក្រចេះ																		
11	មណ្ឌលគិរី																		
12	ភ្នំពេញ	1	3	1		1	1												
13	ព្រះវិហារ																		
14	ព្រៃវែង																		
15	ពោធិ៍សាត់																		
16	រតនគិរី																		
17	សៀមរាប	1	1	1		2													
18	ព្រះសីហនុ																		
19	ស្ទឹងត្រែង																		
20	ស្វាយរៀង																		
21	តាកែវ	1	9	1	2	1													
22	ឧត្ដរមានជ័យ																		
23	កែប																		
24	ប៉ៃលិន																		
25	នាយកដ្ឋាន																		
26	គងរាជអាវុធហត្ថ																		
27	ត្បូងឃ្មុំ																		
	សរុបរួម	4	14	4	2	5	1												

ល.រ	នាយកដ្ឋាន រាជធានី-ខេត្ត	មាត្រា៣៧						មាត្រា៤៥						ជនរងគ្រោះ បញ្ជូនទៅ		
		កិច្ចសន្យានៃអំពើពេស្យាចារកុមារ						កិច្ចសន្យាសំរាប់អំពើលក់-ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ								
		បណ្តឹង	ជនរងគ្រោះ			ជនល្មើស		បណ្តឹង	ជនរងគ្រោះ			ជនល្មើស		ម.សង្គមកិច្ច	អង្គការ	គ្រួសារ
			-15	15-17	18+	ប	ស		-15	15-17	18+	ប	ស			
1	បន្ទាយមានជ័យ															
2	បាត់ដំបង															1
3	កំពង់ចាម															3
4	កំពង់ឆ្នាំង															
5	កំពង់ស្ពឺ															
6	កំពង់ធំ													9		8
7	កំពត															
8	កណ្ដាល															2
9	កោះកុង															1
10	ក្រចេះ															7
11	មណ្ឌលគិរី															
12	ភ្នំពេញ													4	1	10
13	ព្រះវិហារ															
14	ព្រៃវែង															
15	ពោធិ៍សាត់															
16	រតនគិរី															2
17	សៀមរាប															2
18	ព្រះសីហនុ															5
19	ស្ទឹងត្រែង															
20	ស្វាយរៀង															1
21	តាកែវ															13
22	ឧត្ដរមានជ័យ															
23	កែប															
24	ប៉ៃលិន															18
25	នាយកដ្ឋាន															21
26	គងរាជអាវុធហត្ថ													11		9
27	ត្បូងឃ្មុំ															1
	សរុបរួម													24	1	104

លទ្ធផលបង្ក្រាបបទល្មើស អាជីវកម្មផ្លូវភេទ ទូទាំងប្រទេស (ប្រចាំឆ្នាំ ២០១៧)
គិតចាប់ពីថ្ងៃទី ២៦-១២-២០១៦ ដល់ថ្ងៃទី ២៥-១២-២០១៧

ល.រ	នាយកដ្ឋាន រាជធានី-ខេត្ត	បង្ក្រាបសរុប: បណ្តឹង	ជនរងគ្រោះ: សរុប	ជនរងគ្រោះ: -15	ជនរងគ្រោះ: 15-17	ជនរងគ្រោះ: 18	ជនល្មើស: សរុប	ជនល្មើស: ប	ជនល្មើស: ស	មាត្រា២១ ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង: បណ្តឹង	ជនរងគ្រោះ: -15	ជនរងគ្រោះ: 15-17	ជនរងគ្រោះ: 18+	ជនល្មើស: ប	ជនល្មើស: ស	មាត្រា២២ ស្ថានទម្ងន់ទោស (ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង): បណ្តឹង	ជនរងគ្រោះ: -15	ជនរងគ្រោះ: 15-17	ជនរងគ្រោះ: 18+	ជនល្មើស: ប	ជនល្មើស: ស
1	បន្ទាយមានជ័យ																				
2	បាត់ដំបង	21	22	22			23	23													
3	កំពង់ចាម																				
4	កំពង់ឆ្នាំង	2	2	2			2	2													
5	កំពង់ស្ពឺ																				
6	កំពង់ធំ																				
7	កំពត	1	1	1			1	1													
8	កណ្តាល	7	7	7			7	7													
9	កោះកុង	1	1	1			1	1													
10	ក្រចេះ	3	3	2	1		5	3	2												
11	មណ្ឌលគិរី	2	2	2			2	2													
12	ភ្នំពេញ	21	42	12	6	24	23	12	11												
13	ព្រះវិហារ	2	2	2			2	2													
14	ព្រៃវែង																				
15	ពោធិ៍សាត់	1	1	1			1	1													
16	រតនគិរី	1	1	1			1	1													
17	សៀមរាប	17	36	35	1		17	17													
18	ព្រះសីហនុ	7	12	5		7	12	10	2												
19	ស្ទឹងត្រែង																				
20	ស្វាយរៀង																				
21	តាកែវ	2	2	2			2	2													
22	ឧត្តរមានជ័យ	1	1	1			1	1													
23	កែប																				
24	ប៉ៃលិន	1	1	1			1	1													
25	នាយកដ្ឋាន	13	60	4	13	43	16	7	9												
26	កងរាជអាវុធហត្ថ	8	20	5		15	14	14		2			2	2		1			13	7	
27	ត្បូងឃ្មុំ																				
	សរុបរួម	111	216	106	21	89	131	107	24	2			2	2		1			13	7	

ល.រ	នាយកដ្ឋាន រាជធានី-ខេត្ត	មាត្រា២៤ អំពើអូសទាញសញ្ញារកម្ម: បណ្តឹង	ជនរងគ្រោះ: -15	ជនរងគ្រោះ: 15-17	ជនរងគ្រោះ: 18+	ជនល្មើស: ប	ជនល្មើស: ស	មាត្រា២៦ សញ្ញារកម្ម: បណ្តឹង	ជ.រគ្រោះ 18+	ជនល្មើស: ប	ជនល្មើស: ស	មាត្រា២៦ សញ្ញារកម្ម (មានអនីតិជន): បណ្តឹង	ជនរងគ្រោះ: -15	ជនរងគ្រោះ: 15-17	ជនរងគ្រោះ: 18+	ជនល្មើស: ប	ជនល្មើស: ស	មាត្រា២៧ ស្ថានទម្ងន់ទោសនៃសញ្ញារកម្ម: បណ្តឹង	ជនរងគ្រោះ: -15	ជនរងគ្រោះ: 15-17	ជនរងគ្រោះ: 18+	ជនល្មើស: ប	ជនល្មើស: ស	មាត្រា២៨ សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ: បណ្តឹង	ជនរងគ្រោះ: -15	ជនរងគ្រោះ: 15-17	ជនរងគ្រោះ: 18+	ជនល្មើស: ប	ជនល្មើស: ស
1	បន្ទាយមានជ័យ																												
2	បាត់ដំបង																												
3	កំពង់ចាម																												
4	កំពង់ឆ្នាំង																												
5	កំពង់ស្ពឺ																												
6	កំពង់ធំ																												
7	កំពត																												
8	កណ្តាល																												
9	កោះកុង																												
10	ក្រចេះ																							1		1		1	2
11	មណ្ឌលគិរី																												
12	ភ្នំពេញ							6	21		7							1		3			2	2		3	3		2
13	ព្រះវិហារ																												
14	ព្រៃវែង																												
15	ពោធិ៍សាត់																												
16	រតនគិរី																												
17	សៀមរាប																												
18	ព្រះសីហនុ							2	7	5	2																		
19	ស្ទឹងត្រែង																												
20	ស្វាយរៀង																												
21	តាកែវ																												
22	ឧត្តរមានជ័យ																												
23	កែប																												
24	ប៉ៃលិន																												
25	នាយកដ្ឋាន							1	4		1	3		7	13		4	2		1	11	2	2	3		5	15	1	2
26	កងរាជអាវុធហត្ថ																												
27	ត្បូងឃ្មុំ																												
	សរុបរួម							9	32	5	10	3		7	13		4	3		4	11	2	4	6		9	18	2	6

លទ្ធផលបង្ក្រាបបទល្មើស អាជីវកម្មផ្លូវភេទ ទូទាំងប្រទេស (ប្រចាំឆ្នាំ ២០១៧)
គិតចាប់ពីថ្ងៃទី ២៦-១២-២០១៦ ដល់ថ្ងៃទី ២៥-១២-២០១៧

ល.រ	នាយកដ្ឋាន រាជធានី-ខេត្ត	មាត្រា២៨ សញ្ញាកម្មដោយមានការធ្វើទារុណកម្ម						មាត្រា៣០ ការដឹកនាំពេស្យាចារ						មាត្រា៣១ ការដឹកនាំគ្រឹះស្ថានពេស្យាចារ					
		បណ្ដឹង	ជនរងគ្រោះ -15	ជនរងគ្រោះ 15-17	ជនរងគ្រោះ 18+	ជនល្មើស ប	ជនល្មើស ស	បណ្ដឹង	ជនរងគ្រោះ -15	ជនរងគ្រោះ 15-17	ជនរងគ្រោះ 18+	ជនល្មើស ប	ជនល្មើស ស	បណ្ដឹង	ជនរងគ្រោះ -15	ជនរងគ្រោះ 15-17	ជនរងគ្រោះ 18+	ជនល្មើស ប	ជនល្មើស ស
1	បន្ទាយមានជ័យ																		
2	បាត់ដំបង																		
3	កំពង់ចាម																		
4	កំពង់ឆ្នាំង																		
5	កំពង់ស្ពឺ																		
6	កំពង់ធំ																		
7	កំពត																		
8	កណ្ដាល																		
9	កោះកុង																		
10	ក្រចេះ																		
11	មណ្ឌលគិរី																		
12	ភ្នំពេញ																		
13	ព្រះវិហារ																		
14	ព្រៃវែង																		
15	ពោធិ៍សាត់																		
16	រតនគិរី																		
17	សៀមរាប																		
18	ព្រះសីហនុ																		
19	ស្ទឹងត្រែង																		
20	ស្វាយរៀង																		
21	តាកែវ																		
22	ឧត្ដរមានជ័យ																		
23	កែប																		
24	ប៉ៃលិន																		
25	នាយកដ្ឋាន																		
26	កងរាជអាវុធហត្ថ																		
27	ត្បូងឃ្មុំ																		
	សរុបរួម																		

ល.រ	នាយកដ្ឋាន រាជធានី-ខេត្ត	មាត្រា៣២ ការផ្ដល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ						មាត្រា៣៣ បទល្មើសទាក់ទងនឹងពេស្យាចារកុមារ						មាត្រា៣៨ រូបភាព និងសម្ភារៈអាសអាភាស					
		បណ្ដឹង	ជនរងគ្រោះ -15	ជនរងគ្រោះ 15-17	ជនរងគ្រោះ 18+	ជនល្មើស ប	ជនល្មើស ស	បណ្ដឹង	ជនរងគ្រោះ -15	ជនរងគ្រោះ 15-17	ជនរងគ្រោះ 18+	ជនល្មើស ប	ជនល្មើស ស	បណ្ដឹង	ជនរងគ្រោះ -15	ជនរងគ្រោះ 15-17	ជនរងគ្រោះ 18+	ជនល្មើស ប	ជនល្មើស ស
1	បន្ទាយមានជ័យ																		
2	បាត់ដំបង																		
3	កំពង់ចាម																		
4	កំពង់ឆ្នាំង																		
5	កំពង់ស្ពឺ																		
6	កំពង់ធំ																		
7	កំពត																		
8	កណ្ដាល																		
9	កោះកុង																		
10	ក្រចេះ																		
11	មណ្ឌលគិរី																		
12	ភ្នំពេញ																		
13	ព្រះវិហារ																		
14	ព្រៃវែង																		
15	ពោធិ៍សាត់																		
16	រតនគិរី																		
17	សៀមរាប																		
18	ព្រះសីហនុ																		
19	ស្ទឹងត្រែង																		
20	ស្វាយរៀង																		
21	តាកែវ																		
22	ឧត្ដរមានជ័យ																		
23	កែប																		
24	ប៉ៃលិន																		
25	នាយកដ្ឋាន																		
26	កងរាជអាវុធហត្ថ																		
27	ត្បូងឃ្មុំ																		
	សរុបរួម																		

ល.រ	នាយកដ្ឋាន រាជធានី-ខេត្ត	មាត្រា៤១ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ						មាត្រា៤២ អំពើរំលោភ ជាមួយអនីតិជន អាយុក្រោម១៥ឆ្នាំ				មាត្រា៤៣ អំពើអាសគ្រាមនឹងអនីតិជន អាយុក្រោម១៥ឆ្នាំ				ជនរងគ្រោះបញ្ជូនទៅ		
		បណ្ដឹង	ជនរងគ្រោះ -15	ជនរងគ្រោះ 15-17	ជនរងគ្រោះ 18+	ជនល្មើស ប	ជនល្មើស ស	បណ្ដឹង	ជ.គ្រោះ -15	ជនល្មើស ប	ជនល្មើស ស	បណ្ដឹង	ជ.គ្រោះ -15	ជនល្មើស ប	ជនល្មើស ស	ម.ស.អ.គ.ប្រឹ	អង្គការ	គ្រួសារ
1	បន្ទាយមានជ័យ																	
2	បាត់ដំបង							19	20	21		2	2	2				22
3	កំពង់ចាម																	
4	កំពង់ឆ្នាំង							2	2	2								2
5	កំពង់ស្ពឺ																	
6	កំពង់ធំ																	
7	កំពត							1	1	1								1
8	កណ្ដាល							4	4	4		3	3	3				7
9	កោះកុង							1	1	1								1
10	ក្រចេះ							2	2	2								3
11	មណ្ឌលគិរី											2	2	2				2
12	ភ្នំពេញ							7	7	7		5	5	5		27	4	11
13	ព្រះវិហារ							2	2	2								2
14	ព្រៃវែង																	
15	ពោធិ៍សាត់											1	1	1				1
16	រតនគិរី							1	1	1								1
17	សៀមរាប	1	18	1		1		13	14	13		3	3	3				36
18	ព្រះសីហនុ							2	2	2		3	3	3				12
19	ស្ទឹងត្រែង																	
20	ស្វាយរៀង																	
21	តាកែវ	1	1			1		1	1	1								2
22	ឧត្ដរមានជ័យ											1	1	1				1
23	កែប																	
24	ប៉ៃលិន											1	1	1				1
25	នាយកដ្ឋាន							3	3	3		1	1	1		56		4
26	កងរាជអាវុធហត្ថ							4	4	4		1	1	1		13		7
27	ត្បូងឃ្មុំ																	
	សរុបរួម	2	19	1		2		62	64	64		23	23	23		96	4	116

ឧបសម្ព័ន្ធ៤

ឧបសម្ព័ន្ធសកម្មភាពការងាររបស់អង្គការដៃគូនានា

១-ការងារផ្សព្វផ្សាយ

- **អង្គការសម្ព័ន្ធចាប់ដៃ** ៖បានផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋតាមសហគន៍ ដែលរស់នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រៃវែង សរុបចំនួន០៩លើក មានប្រជាជនចូលរួមសរុប ចំនួន៤.៩៣៨នាក់ ស្រី៣.៥២០នាក់ ,កុមារ១.០៣៩នាក់។ (រយៈពេល៣ខែ ពីខែកក្កដាដល់ខែកញ្ញាឆ្នាំ ២០១៧) និងមានសកម្មភាពដូចខាងក្រោមនេះ ៖

តារាងការងារផ្សព្វផ្សាយ

អង្គការ	សកម្មភាព
អង្គការសម្ព័ន្ធចាប់ដៃ	- បានសហការមន្ត្រីសាលាស្រុក ការិយាល័យមន្ទីរសង្គមកិច្ចស្រុក អធិការដ្ឋាននគរបាលស្រុក និង អាជ្ញាធរ មូលដ្ឋានស្រុក ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមសហគន៍ដែលរស់នៅក្នុងឃុំទាំង៨ របស់ស្រុកព្រះស្តេច និងឃុំចំនួន៤របស់ស្រុកកំចាយមារ ខេត្តព្រៃវែង បានចំនួន០៣លើក ដល់ប្រជាពលរដ្ឋចំនួន៣.៩៣៩នាក់ ស្រី២.៦៨៨នាក់ (កុមារចំនួន២៣៩នាក់) ។ - បានកំណត់អ្នកមានស្នាដៃល្អក្នុងការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅតាមសហគមន៍ក្នុងស្រុក បាភ្នំ ខេត្តព្រៃវែង សរុបចំនួន៣៦នាក់ ក្នុងនោះមាន(អភិបាលរងស្រុក០២នាក់ ,អធិការរង ស្រុក០២នាក់ ,ប្រធានការិយាល័យសង្គមកិច្ច០២នាក់ ,ប្រធានការិយាល័យកិច្ចការនារី០២នាក់ ,គ្រូគង្វាល០១នាក់ និងអាជ្ញាធរមូលដ្ឋាន២៧នាក់។ - បានសហការមន្ត្រីសាលាខណ្ឌ-សង្កាត់ ការិយាល័យមន្ទីរកិច្ចការនារីខណ្ឌ អធិការដ្ឋាននគរបាលខណ្ឌ សង្កាត់ រាជធានីភ្នំពេញ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមសហគន៍ដែលរស់នៅក្នុងសង្កាត់ច្បារ អំពៅ ខណ្ឌច្បារអំពៅ ,សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ និងខណ្ឌព្រែកព្នៅ បានចំនួន០៤លើក ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី អំពើហិង្សាក្នុងគ្រួសារ និង កុមារធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋចំនួន៦៦៣នាក់ (ស្រី៥៩៥នាក់ កុមារ៦០០នាក់) - បានសហការមន្ត្រីសាលាស្រុក ការិយាល័យមន្ទីរសង្គមកិច្ចស្រុក អធិការដ្ឋាននគរបាលស្រុក និង អាជ្ញាធរ មូលដ្ឋានស្រុក ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមសហគន៍ដែលរស់នៅក្នុងឃុំព្រែកដាច់ ស្រុកលើកដែកដែលមាន៤ភូមិ គឺភូមិ(ព្រែកតូច ព្រែកដាច់ ព្រែកតាហ៊ី និងភូមិកោះគន្ធាយ) ខេត្តកណ្តាល បានចំនួន០១លើក ដល់ប្រជាពលរដ្ឋចំនួន៣០០នាក់ ស្រី២៣៧នាក់ (កុមារ ចំនួន២០០នាក់) ។

- **អង្គការសម្ព័ន្ធចាប់ដៃ(ត្រីមាសទី៣)** បានធ្វើកម្មវិធីផ្សព្វផ្សាយតាមរយៈវិទ្យុ និងតាមឃោសនស័ព្ទ ស្តីពីការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទលើស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាក ស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ដូចមានសកម្មភាពខាងក្រោម៖

- **ផ្សព្វផ្សាយតាមរយៈវិទ្យុ**
  - បានធ្វើការចាក់ផ្សាយតាមរលកវិទ្យុ FM92,50 នៅខេត្តកោះកុង ក្នុងគម្រោងសុវត្ថិភាពសហគមន៍ បានធ្វើការជ្រើសរើសអ្នកតាមដានស្តាប់កម្មវិធីវិទ្យុ និងចែកខិតប័ណ្ណ មានចំនួន**០៧**នាក់ (កិច្ចការនារីសង្កាត់ដងទង់១នាក់ ,អនុភូមិ០១នាក់ និងសង្កាត់ដងទង់០១នាក់ ,អនុភូមិ០១នាក់ និងសង្កាត់ស្មាច់មានជ័យ០១នាក់ ,អ្នកស្ម័គ្រចិត្តកាកបាទក្រហមខេត្ត០១នាក់ និងមេភូមិទួលគគីលើ០១នាក់)។
  - បានធ្វើការចាក់ផ្សាយតាមរលកវិទ្យុ FM92,50 នៅខេត្តកំពង់ចាម ក្នុងគម្រោងសុវត្ថិភាពសហគមន៍ បានធ្វើការជ្រើសរើសអ្នកតាមដានស្តាប់កម្មវិធីវិទ្យុ និងចែកខិត្តប័ណ្ណ មានចំនួន**០៥**នាក់ (មេភូមិកំពង់ឪជ្រឹង, មេភូមិរំដេងលិច និងមេភូមិពង្រកើត ស្រុកកោះសូទិន ,មេភូមិព្រៃបាក់ និងមេភូមិព្រែកអង្គ ស្រុកស្ទឹងត្រង់) ។
- **ផ្សព្វផ្សាយតាមឃោសនស័ព្ទ** ក្នុងស្រុកចំការលើ ខេត្តកំពង់ចាម គម្រោងសុវត្ថិភាពសហគមន៍ បានធ្វើការជ្រើសរើសអ្នកតាមដានស្តាប់ឃោសនស័ព្ទ មានចំនួន០២នាក់ ក្នុងឃុំល្វាលើ មាន០២ភូមិ គឺឃុំល្វាលើមាន(ភូមិ៣ មានមេភូមិ និងមេក្រូ០១ ,ភូមិល្វាជើង មានមេភូមិ និងមេក្រូ០១) និងឃុំបុសខ្នុលមាន(ភូមិថ្លុកក្រវ៉ាន់ មានមេភូមិ និងមេក្រូ០១ , ភូមិបុសខ្នុល មានមេភូមិ និងមេក្រូ០១ ,ភូមិប្រសើរ មានមេភូមិ និងមេក្រូ០១)

❖ អង្គការសម្ព័ន្ធចាប់ដៃ(ត្រីមាសទី៤)

- បានសហការជាមួយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត ការិយាល័យអធិការកិច្ច និងវិវាទការងារ នៃមន្ទីរការងារបណ្តុះបណ្តាលវិទ្យាជីវៈខេត្ត និងស្ថានីយ៍វិទ្យុជាតិ ភ្នំប្រុស ភ្នំស្រី FM ៩២.៥០ ខេត្តកំពង់ចាម ក្នុងកម្មវិធីផ្សព្វផ្សាយការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយស្របច្បាប់ និងសិទ្ធិកុមារ និងតួនាទីឪពុកម្តាយល្អ ដែលមានប្រិយ៍មិត្តទូរស័ព្ទមកចូលរួមចំនួន**២៩**នាក់(ស្រី**២២**នាក់)។
- បានសហការជាមួយអាជ្ញធរដែនដី មានមេភូមិ សមាជិកភូមិ និងបង្គោលកិច្ចការនារីទទួលបន្ទុកស្ត្រី និងកុមារ សរុបចំនួន៤៤០នាក់ ផ្សព្វផ្សាយផ្សព្វផ្សាយការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ តាមរយៈចែកប័ណ្ណជំនួយបានចំនួន៧៥៤សន្លឹក និងសៀវភៅតម្លៃគ្រួសារចំនួន៦៦២ក្បាល ។

❖ អង្គការ Terre des homes

- បានធ្វើកម្មវិធីជជែកតាមទូរទស្សន៍ ស្តីពីសិទ្ធិកុមារ មានអ្នកចូលរួមមកពី គណៈកម្មាធិការជាតិ គ.ជ.ប.ជ ០១រូប ,ក្រសួងកិច្ចការនារី០១រូប ,ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ០១នាក់ ,អង្គការខេមបូឌាអ៊ាក០១នាក់ អង្គការកាកបាតក្រហម០១នាក់ និងបណ្តាញទំនាក់ទំនងកុមារ។
- បានពិភាក្សាជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងគោលបំណងឲ្យមានការគាំទ្រនូវអនុសាសន៍ដែលលើកឡើងដោយកុមារ និងអង្គការសង្គមស៊ីវិល មានអ្នកចូលរួមចំនួន**១០**នាក់ មកពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ,អង្គការខេមបូឌាអ៊ាក អង្គការកាកកបាតក្រហម និងបណ្តាញទំនាក់ទំនងកុមារ។

❖ អង្គការ Winrock International

- **បានផ្សព្វផ្សាយតាមរយៈវិទ្យុ ស្ទើរតែគ្រប់ខេត្ត និងបាន៖**
  - សហការជាមួយ សមាគមយុវជនមគ្គុទ្ទេសក៍កម្ពុជា- អាស៊ាន និងវិទ្យុ វាយោ បានផ្សព្វផ្សាយក្នុងកម្មវិធីវិទ្យុ

សហគមន៍ចំនួន៨ប្រធានបទ ដែលទាក់ទងនឹងចំណាកស្រុកសុវត្ថិភាព អំពើជួញដូរមនុស្ស និងផ្សាយផ្ទាល់លើបណ្ដាញ Facebook ដល់ប្រជាជនតាមបណ្ដាខេត្តនានា។

- **បានផ្សព្វផ្សាយតាមរយៈសម្ភារៈទូទាំងប្រទេស និងបាន៖**
  - សហការជាមួយអង្គការ NCCT PCCT វិទ្យាស្ថានបើកទូលាយ អង្គការសេដាក សុវណ្ណភូមិ CCPCR ADHOC LSCW ចែកចាយសម្ភារៈផ្សព្វផ្សាយចំនួន**៣៥.៤០៩** មានដូចជា៖ ប័ណ្ណលេខទូរស័ព្ទសុំជំនួយ វីដេអូ(រឿង "តម្លៃកូនក្រមុំ" "ជើងមេឃនៅឯ ណា?" "ករណីយ៉យអ៊ិន អូសិន ខេស" វីដេអូណែនាំ វិធីមុនពេល ធ្វើចំណាកស្រុក") ស្បោងដែលមានលេខទូរស័ព្ទសុំជំនួយ អាវយឺត ខិត្តប័ណ្ណស្ដីពីឱកាសការងារសម្រាប់អ្នកមានជំនាញទាប ឬគ្មានជំនាញសោះ ដល់ប្រជាជនងាយរងគ្រោះ អង្គការ ក្រុមយុវជន និងមន្ត្រីធ្វើការទាក់ទងនឹងអំពើជួញដូរមនុស្ស សរុបចំនួនមនុស្ស**៧០.៨១៨** នាក់។
  - សហការជាមួយអង្គការ NCCT PCCT វិទ្យាស្ថានបើកទូលាយ ផលិតសម្ភារៈផ្សព្វផ្សាយចំនួន**៥៥** និងផ្សព្វផ្សាយតាមបណ្ដាញសង្គម មានដូចជា៖ ព័ត៌មានស្ដីពីឱកាសការងារសម្រាប់ អ្នកមានជំនាញទាបឬគ្មានជំនាញសោះ វីដេអូ និងប៉ុស្ទ័រ អប់រំសម្រាប់ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទិវាពិភពលោកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពលកម្មអន្តរជាតិ នារីអន្តរជាតិ ប័ណ្ណទិវានៃក្ដីស្រឡាញ់ និងស្បោង និងប័ណ្ណមានលេខទូរស័ព្ទសុំជំនួយជាដើម ដល់អ្នកប្រើប្រាស់បណ្ដាញសង្គម ប្រជាជនងាយរងគ្រោះ អង្គការ ក្រុមយុវជន និងមន្ត្រីធ្វើការទាក់ទងនឹងអំពើជួញដូរមនុស្ស និងចំណាកស្រុក សរុបចំនួនមនុស្សប្រមាណជា **១.១៩២.៦៩៩នាក់**។
- **បានផ្សព្វផ្សាយតាមរយៈភាពយន្តខ្លីៗ ទូទាំងប្រទេស និងបាន៖**
  - សហការជាមួយ ក្រុមកុនខ្មែរកូនខ្មែរ សមាគមយុវជនមគ្គុទ្ទេសក៍កម្ពុជា-អាស៊ាន ទូរទស្សន៍MyTV ក្រុមហ៊ុន SONY, Studio 4, Expo Travel, Creative Plus, Chenla Media, Major Ceneplex និង Sabay បានធ្វើមហោស្រពភាពយន្តខ្លីចតុមុខ ទាញចំណាប់អារម្មណ៍សាធារណជនឲ្យយល់ដឹងពីបញ្ហាអំពើជួញដូរមនុស្ស និងចំណាកស្រុក និងកៀរគរយុវជនស្រឡាញ់វិស័យខ្សែភាពយន្ត និងជនរស់រានពីអំពើជួញដូរឲ្យ ផលិតភាពយន្តខ្លី ទាក់ទងនឹងអំពើជួញដូរមនុស្ស និងចំណាកស្រុក។ ហើយខ្សែភាពយន្តខ្លីទាំងនោះត្រូវបានបញ្ចាំងអំឡុងពេលមហោស្រពខ្សែភាពយន្តខ្លីចតុមុខ ផ្សាយលើកញ្ចក់ទូរទស្សន៍ MyTV និងបណ្ដាញសង្គម Facebook សរុបចំនួនមនុស្សចូលរួម ប្រមាណជា**៣លាន**នាក់។
- **បានផ្សព្វផ្សាយតាមបណ្ដាញ Facebook ទូទាំងប្រទេស និងបាន៖**
  - បានសហការជាមួយ កញ្ញា មាន សូនីតា អគ្គរាជទូតសុច្ឆន្ទៈនៃគម្រោង អង្គការIJM, ADHOC, LSCW, យុទ្ធនាការផ្សព្វផ្សាយតាមបណ្ដាញFacebook សម្រាប់ទិវាពិភពលោកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ផ្សាយសារតាមរយៈ វីដេអូ និង ប៉ុស្ទ័រ) មានអ្នកប្រើប្រាស់Facebook ចំនួន**៥៤.០០០** នាក់ ។
  - យុទ្ធនាការតាមរយៈបណ្ដាញសង្គមសម្រាប់ ទិវានារីអន្តរជាតិ (៨ មីនា) ជាមួយនឹងសារអប់រំ នានាទាក់ទងនឹងអំពើជួញដូរមនុស្ស មានអ្នកប្រើប្រាស់ បណ្ដាញសង្គមចំនួន**៦.៥០២**នាក់។

❖ **ស្ថានទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា ៖**បានសហការជាមួយ តារាសម្ដែង កញ្ញា មាន សូនីតា អគ្គរាជទូតសុច្ឆន្ទៈនៃគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា ក្នុងការពិភាក្សាគ្នា ស្ដីពីបញ្ហាអំពើជួញដូរមនុស្ស និងចំណាកស្រុក ក្នុងកម្មវិធី "Let's Chat" កម្មវិធីទូរទស្សន៍ របស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា មានអ្នកចូលរួមសរុបចំនួន**៩២.០០០** នាក់ ។

២-ការងារបណ្តុះបណ្តាល

តារាងកម្មវិធីបណ្តុះបណ្តាល

សកម្មភាព	ចំនួនវគ្គ	អ្នកចូលរួម	ស្រី
អង្គការ Terre des homes (ក្នុងកម្មវិធីរបស់អង្គការដៃនដីហូឡង់ដ៍ APLE) បានបើកវគ្គបណ្តុះបណ្តាលៈ - ស្តីពីការស៊ើបអង្កេតកោសល្យវិច័យលើកុមារ និងការស៊ើបអង្កេតរំលោភបំពានលើទេសចរណ៍ផ្លូវភេទលើកុមារ ដល់មន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន(នគរបាលជាតិ និងកងរាជអាវុធហត្ថ)មន្ត្រីក្រសួងទេសចរណ៍ មន្ត្រីកិច្ចការនារី និងមន្ត្រីសង្គមកិច្ច នៅក្រុងព្រះសីហនុ (០១វគ្គ សរុប២៥នាក់) - ស្តីពីការប្រមូលភស្តុតាងក្នុងករណី SECTT និងការសម្ភាសកុមាររងគ្រោះ ដោយបានសហការជាមួយស្នងការដ្ឋាននគរបាលខេត្ត ទទួលបន្ទុកផ្នែកបណ្តុះបណ្តាល មកពីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដែលមានមន្ត្រីនគរបាលចូលរួមចំនួន៣៤នាក់	០២	៥៩	
អង្គការសម្ព័ន្ធចាប់ដៃ បណ្តុះបណ្តាល ៖ - ស្តីពីការចូលរួមរបស់កុមារដល់បុគ្គលិករបស់ខ្លួន និងអាជ្ញាធរមូលដ្ឋាន (០២វគ្គ សរុប១២០នាក់ ខេត្តសៀមរាប និងខេត្តបាត់ដំបង) - គ្រូបង្គោលស្តីពី គោលការណ៍ណែនាំ សម្រាប់ការចូលរួមរបស់កុមារ ដល់អង្គការសមាជិកចំនួន០៥អង្គការ មន្ត្រី ក.ជ.ក មន្ត្រីមន្ទីរសង្គមកិច្ចខេត្តសៀមរាប ដោយសហការជាមួយមន្ត្រីក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ (០២វគ្គ សរុប២៥នាក់ ស្រី១៥នាក់)	០៤	១៤៥	១៥
អង្គការ RATANAK International ៖ បើកវគ្គបណ្តុះបណ្តាលបំណិតជីវិត និងជំនាញទន់ ការចុះទស្សកិច្ច ដល់ស្ត្រីរងគ្រោះករណីជួញដូរផ្លូវភេទចំនួន០៧នាក់ និងករណីជួញដូរពលកម្មចំនួន០២នាក់ ។	០១	០៩	០៩
សរុប	០៧	២១៣	២៤

៣-ការងារសិក្ខាសាលា

តារាងទិន្នន័យនៃកម្មវិធីសិក្ខាសាលា

អង្គការ terre des hommes	រៀបចំសិក្ខាសាលាៈ - ស្តីពីការពិគ្រោះយោបល់ជាមួយកុមារ និងយុវជន មានអ្នកចូលរួមមកពីខេត្ត/ក្រុងចំនួន ១៥ មានអង្គការ(ខេមបូឌាអ៊ាក ,ផ្លេនអន្តរជាតិ ,អង្គការក្រៅរដ្ឋាភិបាល) និងកាកបាតក្រហមកម្ពុជាសរុបចំនួន៦៩នាក់។ -ស្តីពីកុមារដែលគ្មានទិសដៅ នៃសិទ្ធិកុមារ នៅក្នុងកតិកាសញ្ញាពិភពលោក មានអ្នកចូលរួម ភ្នាក់ងាររបស់រដ្ឋាភិបាល ភ្នាក់ងារអង្គការមិនមែនរដ្ឋាលភិបាល ,អង្គការសហប្រជាជាតិ និងតំណាងកុមារ សរុបចំនួន៧៥នាក់ ។

អង្គការសម្ព័ន្ធចាប់ដៃ	រៀបចំសិក្ខាសាលា ស្ដីពីការចូលរួមរបស់កុមារ បានចំនួន០១វគ្គ មានអ្នកចូលរួមចំនួន ៣៨នាក់ នៅរាជធានីភ្នំពេញ ។

៨-កិច្ចប្រជុំការងារសម្របសម្រួល

អង្គការ RATANAK International	❖ បានចូលរួមកិច្ចប្រជុំពិភាក្សា៖ - ជាមួយអង្គការដៃគូមិនមែនរដ្ឋាភិបាល និងការពាក់ព័ន្ធប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ - ស្ដីពីការសម្រេចចុងក្រោយលើផែនការសកម្មភាពខមមីត និងផែនការក្រុមការងារសហប្រតិបត្តិការអន្តរជាតិសម្រប់អនុវត្តន៍ នៅក្រសួងកិច្ចការនារី ។ - ស្ដីពីការពង្រៀងផែនការសកម្មភាពទាក់ទងទៅនឹងកិច្ចព្រមព្រៀងទ្វេភាគីរវាងកម្ពុជា និងចិន នៅការិយាល័យ UNACT ។ - ជាអ្នកសម្របសម្រួលកម្មវិធីឈោងចាប់បុគ្គលិកសង្គមជាន់ខ្ពស់ និងជំនួយការរដ្ឋបាល និងគណនេយ្យ បានចូលរួមក្នុងការធ្វើបទបង្ហាញ ស្ដីពីភាពប្រឈមនៃការគ្រប់គ្រងករណីជនរងគ្រោះ ទៅកាន់ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃ គ.ជ.ប.ជ និងក្រុមការងារខមមីតកម្ពុជា នៅក្រសួងកិច្ចការនារី ។ - ស្ដីពីការគ្រប់គ្រងករណីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ - ជាមួយអង្គកា AGAPE ស្ដីពីកិច្ចសហការ ក្នុងការផ្ដល់សេវាចិត្តសង្គមដល់ជនរងគ្រោះ ។ - ជាមួយអង្គការដៃគូ ដូចជាអង្គកា WINROCK អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ អង្គការ Samaritan´s Purse អង្គការ IOM និងអង្គការចាប់ដៃ ដើម្បីសិក្សា អំពីបទពិសោធន៍ ក្នុងការផ្ដល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និការផ្ដល់សេវាតាមមូលដ្ឋាន។ - ជាមួយអង្គការដៃគូ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ អង្គការ IOM និងអង្គការចាប់ដៃ ស្ដីពីជនជនមាតុភូមិនិវត្តន៍ និងការផ្ដល់សេវា ។ - ក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ នៅសាលមហោស្រប និងតាំងពិព័រណ៍កោះពេជ្រ ។ - វគ្គបណ្ដុះបណ្ដាលជាមួយនាយកដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្ដីពីបទដ្ឋានអប្បរមា និងការកំណត់អត្តសញ្ញាណរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ❖ បានចូលរួមក្នុងសិក្ខាសាលា៖ - ថ្នាក់ជាតិ ស្ដីពីកុមារបម្លាស់ទីនៅក្នុងប្រទេសកម្ពុជា របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ - ស្ដីពីការផ្សព្វផ្សាយឯកសារគោល នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តឆ្នាំ២០១៧-២០១៨ ។

	-ស្តីពីការសម្របសម្រួលការយល់ដឹងអំពីអនុសញ្ញាអាស៊ាន អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP) និងផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។ -ស្តីពីកតិកាសញ្ញាជាសកល នៃទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ភាពស្របច្បាប់ និងប្រក្រតីភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។ -ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីផែនការសកម្មភាពរបស់ក្រុមការពារជនរងគ្រោះ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តឆ្នាំ២០១៧-២០១៨ ។

➢ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

១-ការងារអនុវត្តច្បាប់

១.១-អង្គការ HAGAR ការងារបង្ក្រាប(បើកករណីថ្មី) និងសង្គ្រោះជនរងគ្រោះ (ប្រចាំឆ្នាំ២០១៧)

តារាងស្ថិតិបទល្មើស និងជួយជនរងគ្រោះ

បទល្មើស	ករណី	ជនរងគ្រោះ				
		សរុប	ប្រុស	ស្រី	កុមារា	កុមារី
-ករណីប៉ុនប៉ងរំលោភ -ការរំលោភបំពានផ្លូវភេទ -ការរំលោភដោយសាច់ញាតិ -ការរំលោភបំពានដោយអំពើហិង្សា -ការជួញដូរផ្លូវភេទ -ការជួញដូរកម្លាំងពលកម្ម -ការរំលោភបំពានលើរាងកាយ -រូបអាសអាក្រាត -គេបោះបង់	១ ៣៧ ២ ៨ ៥ ៥ ៤ ៤ ១	៦៧	០១	១៥	២៧	២៤
សរុប	*៦៧ករណី*	*៦៧នាក់*	*០១នាក់*	*១៥ នាក់*	*២៧នាក់*	*២៤នាក់*

១.២-អង្គការ HAGAR ការងារបង្ក្រាប(បិទករណី) និងសង្គ្រោះជនរងគ្រោះ (ប្រចាំឆ្នាំ២០១៧)

តារាងស្ថិតិបទល្មើស និងជួយជនរងគ្រោះ

បទល្មើស	ករណី	ជនរងគ្រោះ				
		សរុប	ប្រុស	ស្រី	កុមារា	កុមារី
-ការប៉ុនប៉ងរំលោភផ្លូវភេទ -ការជួញដូរផ្លូវភេទ -ការជួញដូរកម្លាំងពលកម្ម -ការរកស៊ីផ្លូវភេទ -ការរំលោភបំពានផ្លូវភេទ -ការរំលោភបំពានលើរាងកាយ -ករណីគេបោះបង់ចោល -ការរំលោភបំពានដោយអំពើហិង្សា -ហានីភ័យ -មិនអើពើ	១ ៣ ៨ ១ ៤១ ៣ ២ ៩ ២ ៤	៧៤	១៣	៦១	០	០
សរុប	*៧៤ករណី*	*៧៤នាក់*	*១៣នាក់*	*៦១ នាក់*	*០នាក់*	*០នាក់*

២-ការគាំទ្រផ្នែកច្បាប់ និងការការពារ

២.១ សេវាកម្មដែលបានផ្តល់ជូនអតិថិជន របស់អង្គការមូលនិធិHAGA

- **(ត្រីមាសទី២)៖** សរុបចំនួន៨១លើក (ជូនអតិថិជនទៅលេងផ្ទះចំនួន០១លើក ,ស៊ើបអង្កេត០១លើក តាមដាន០១លើក ,រៀបចំឲ្យអតិថិជនឡើងតុលាការ០៦លើក ,ទៅស្តាប់ការជំនុំជម្រះករណីតុលាការ ០៦លើក ,សន្និសិទស្តីពីករណី១០លើក ,ផ្តល់ព័ត៌មានទាក់ទងនឹងករណីតុលាការ២០លើក និងការគាំទ្រ៣៦លើក)។
- **(ត្រីមាសទី៣)៖** សរុបចំនួន៩៦លើក (ស៊ើបសួរ០១លើក ,ជួបជាមួយមេធាវី០១លើក ,ករណីឧប្បត្តិហេតុ០១លើក ,ជួយអន្តរាគមន៍លើករណីឧប្បត្តិហេតុ០១លើក ,ទាក់ទងទៅអាជ្ញាធរមានសមត្ថកិច្ច ០១លើក ,ស៊ើបអង្កេត០១លើក ,តាមដាន០១លើក ,សម្របសម្រួល០២លើក ,រៀបចំឲ្យអតិថិជនឡើងតុលាការ០៣លើក ,សន្និសិទស្តីពីករណី០៣លើក ,ទៅស្តាប់ការជំនុំជម្រះករណីតុលាការ០៨លើក ការគាំទ្រ១២លើក និងផ្តល់ព័ត៌មានទាក់ទងនឹងករណីតុលាការ៦១លើក ។
- **(ត្រីមាសទី៤)៖** សរុបចំនួន៤៥លើក (តាមដាន០១លើក ,ណែនាំពីករណីតុលាការ០១លើក ,សន្និសិទស្តីពីករណី០២លើក ,ជួយអន្តរាគមន៍លើករណីឧប្បត្តិហេតុ០៣លើក ,ដំណាក់កាលមុនជំនុំជម្រះ ០៤លើក ,ការត្រៀមខ្លួនទៅតុលាការ០៤លើក ,សវនាការសាលាដំបូង០៦លើក ,ការគាំទ្រ០៧លើក និងចែករំលែកព័ត៌មានទាក់ទងនឹងករណីតុលាការ១៧លើក ។

➢ កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

១-ការជួយសង្គ្រោះជនរងគ្រោះ

❖ អង្គការសម្ព័ន្ធចាប់ដៃ(ត្រីមាសទី៣)+(ត្រីមាសទី4)បានសហការជាមួយស្ថានទូតខ្មែរប្រចាំនៅប្រទេស ៖

- ចិនបានជួយអន្តរាគមន៍សង្គ្រោះនារីខ្មែរ ដែលត្រូវមេខ្យល់ឆបោកឲ្យទៅរៀបការដោយបង្ខំ ជាមួយបុរសជនជាតិចិន មានចំនួន៣៤ករណី និងបានវិលត្រឡប់មកស្រុកកំណើតវិញ ។
- ថៃ បានជួយអន្តរាគមន៍សង្គ្រោះនារីខ្មែរ ដែលត្រូវមេខ្យល់ឆបោកឲ្យទៅធ្វើការខុសច្បាប់ មានចំនួន១៤ករណី និងបុរស០១នាក់ ដោយការជួញដូរតាមទូកនេសាទ០១ករណី និងបានវិលត្រឡប់មកស្រុកកំណើតវិញ ។
- ម៉ាឡេស៊ី បានជួយអន្តរាគមន៍សង្គ្រោះនារីខ្មែរ ដែលត្រូវមេខ្យល់ឆបោកឲ្យទៅធ្វើការខុសច្បាប់ មានចំនួន០៥ករណី និងបានវិលត្រឡប់មកស្រុកកំណើតវិញ ។
- វៀតណាម បានជួយអន្តរាគមន៍សង្គ្រោះនារីខ្មែរ ដែលត្រូវមេខ្យល់ឆបោកឲ្យទៅធ្វើការខុសច្បាប់ មានចំនួន០២ករណី និងបានវិលត្រឡប់មកស្រុកកំណើតវិញ ។
- ហុង កុង បានជួយអន្តរាគមន៍សង្គ្រោះនារីខ្មែរ ដែលត្រូវមេខ្យល់ឆបោកឲ្យទៅធ្វើការខុសច្បាប់ មានចំនួន១០ករណី និងបានវិលត្រឡប់មកស្រុកកំណើតវិញ ។
- អារ៉ាប់ បានជួយអន្តរាគមន៍សង្គ្រោះនារីខ្មែរ ដែលត្រូវមេខ្យល់ឆបោកឲ្យទៅធ្វើការខុសច្បាប់ មានចំនួន០១ករណី និងបានវិលត្រឡប់មកស្រុកកំណើតវិញ ។
- ជួយសង្គ្រោះកុមារដែលត្រូវគេរំលោភសេពសន្ថវៈ បានចំនួន១៤ករណី ។

❖ **អង្គការសម្ព័ន្ធចាប់ដៃ**(ត្រីមាសទី៤)បានសហការជាមួយស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត និងមន្ទីរសង្គមកិច្ចរាជធានី/ខេត្ត៖

- ជួយនារីរងគ្រោះដោយករណីជួញដូរមនុស្ស ចំនួន១៨នាក់ ក្នុងនោះមាន(រាជធានីភ្នំពេញ០៦នាក់ ,ខេត្តបាត់ដំបង០១នាក់ ,កំពង់ចាម០១នាក់ ,កំពង់ឆ្នាំង០១នាក់ ,កំពង់ធំ០២នាក់ ,ក្រចេះ០២នាក់ ព្រៃវែង០២នាក់ ,ត្បូងឃ្មុំ០១នាក់ ,ស្ទឹងត្រែង០១នាក់ និងខេត្តបន្ទាយមានជ័យ០១នាក់)។
- ជួយកុមារីរងគ្រោះដោយរំលោភសេពសន្ថវៈចំនួន០៩នាក់ ក្នុងនោះមាន(ខេត្តបន្ទាយមានជ័យ០១នាក់ ,រតនគិរី០២នាក់ ,ព្រះវិហារ០៣នាក់ ,ព្រៃវែង០១នាក់ ,កំពត០១នាក់ និងខេត្តកំពង់ធំ០១នាក់)។

❖ **អង្គការ RATANAK អន្តរជាតិ** (ប្រចាំឆ្នាំ)៖ បានសហការជាមួយជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការ IOM និងអង្គការចាប់ដៃ ទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាចំនួន៣០លើក សរុបចំនួនមនុស្ស៦៩នាក់(ស្ត្រី៦៧នាក់ កុមារ០១នាក់ កុមារី០១នាក់)ក្នុងនោះ៖

- មកពីប្រទេសម៉ាឡេស៊ីចំនួន៣២នាក់ ករណីជួញដូរផ្លូវភេទ ។

២-ការជួយឧបត្ថម្ភជនរងគ្រោះ

❖ **អង្គការសម្ព័ន្ធចាប់ដៃ(ត្រីមាសទី៣) +(ត្រីមាសទី4)**

➢ បានជួយឧបត្ថម្ភដល់នារីខ្មែររងគ្រោះ ដោយចាញ់បោកមេខ្យល់ ដូចជា៖

- បានទិញសំបុត្រយន្តហោះពីប្រទេស ម៉ាឡេស៊ី មកប្រទេសកម្ពុជាវិញ ចំនួន១១លើក ប្រទេសចិនចំនួន៤លើក និងប្រទេសវៀតណាមចំនួន២លើក និងបានវិលត្រឡប់មកស្រុកកំណើតវិញ ។
- បានទិញសំបុត្រយន្តហោះពីប្រទេសចិន មកប្រទេសកម្ពុជាវិញ ចំនួន០៦លើក

➢ តាមដាន និងព្រឹក្សាផ្តល់យោបល់ផ្លូវចិត្ត ដើម្បីស្តានីតិសម្បទាបានចំនួន៣១ករណី ។

- ផ្តល់សេវាកម្មផ្លូវច្បាប់ជាមេធាវី ដល់ជនរងគ្រោះបានចំនួន០៩ករណី។
- បានផ្តល់សេវាពិនិត្យសុខភាព ដល់អនីតិជនចំនួន០៧ករណី ។ និង
- **បានផ្តល់គ្រឿងឧបភោគបរិភោគមួយចំនួនដល់ជនរងគ្រោះដូចជាៈ** អង្ករចំនួន១៣០០គីឡូ, ត្រីខ៣៥៦កំប៉ុង, មី៤៩៧កញ្ចប់, ស្ករស ២៨គីឡូ, ប្រេងឆា ៥៨លីត្រ, ប្រេងខ្យង០៤ដប, អំបិល ៤៤គីឡូ, ប៊ីចេង១១គីឡូ, ទឹកត្រី ៦៥ដប ទឹកស៊ីអ៊ីវ៥៨ដប ,ទឹកម្ទេស ១៤ដប ,ទឹកដោះគោ ៩៨កំប៉ុង ,ទឹកដោះគោAD ១០យួរ ,ទឹកដោះគោខាប់០៥កំប៉ុង ,នំកញ្ចប់៣៨កញ្ចប់ នំJulie΄s oat Ten០៦ដុំ, នំ៣០៣ប្រអប់, នំOreo05ដុំ, នំស្រួយ០៥ប្រអប់, នំAFC ១០យួរ, នំSolid០៥ប្រអប់នំប្រេងដូង០៥យួរ, នំហានិមិ០៤កំប៉ុង, នំស្លឹកសយ០១ប្រអប់, នំធុង០១ធុង, ស្ករគ្រាប់០៣កញ្ចប់, ត្រីផាត់០២ចាន និងនំធុង០២ធុង, ទឹកជ្រលក់០៣ដប, ម្រេច០១កញ្ចប់, ចាហួយ០៥កែវ និងមីឡូ០៥កែវ។
- **បានជួយឧបត្ថម្ភផ្នែកសម្ភារ** ដូចជាៈ សាប៊ូកក់សក់៣៤ដប, សាប៊ូបោកខោអាវ៦៣.០៥០គីឡូ, សាប៊ូដុសខ្លួន៩៥ដប, សាប៊ូលាងចាន៤៩ដប ,ប្រអប់ដាក់សាប៊ូ២៦ប្រអប់, ថ្នាំដុសធ្មេញ៤១ដប, ច្រាស់ដុសធ្មេញ៤១ដើម, អូសាវែល០៦ដប, ទឹកក្រអូប០៦ដប, វែកឆា០៩, កាធុនលាងបន្លែ០៦, កន្ត្រៃដាក់អំបិល និងប៊ីចេង១៨, ប្រដាប់លាងចាន៣៦ដុំ, ចង្កឹះ៦០គូ, ធុងចំពោះទឹកស្អាត១៣ធុង, ចានជ័រ និងចានតូច០៣, ខ្ទះ០១, ដបទឹកធំ១០, ប្រេងកូឡា៤០ដប សៀវភៅសរសេរ១៩ក្បាល, កាតាប០២, កាបូបដាក់ប៊ិច០១, បន្ទាត់១០ដើម, ខ្មៅដៃ៣៦ដើម+០១ប្រអប់, ជ័រលុប ០៣ដើម, ប៊ិច០៧ដើម, ដែកខួង០៣, ពណ៌ផាត់០៦ប្រអប់, សៀវ ផាត់រូប០៦ក្បាល និងកាធុនបោកខោអាវ០៣ ស្បែកជើង០២សម្រាប់, កង់០១គ្រឿង, កន្លរដាក់អំបិល០៣, កន្លរដាក់ប្រហុក០២, កញ្ជ្រែង០២, ចានដែក០១ ប្រអប់ដាក់ស្លាបព្រា០១, វែកឆា០១។

❖ **អង្គការរតនៈ អន្តរជាតិ** (ប្រចាំឆ្នាំ២០១៧) បានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការ MOI អង្គការ ADHOC និងអង្គការសម្ព័ន្ធចាប់ដៃ បានទទួលជនរងគ្រោះពីប្រទេសនានា ៖

- បានចំនួន៣០លើក សរុបចំនួន៦៩នាក់ (ស្រី៦៧នាក់ កុមារា០១នាក់ កុមារី០១នាក់) ក្នុងនោះមានៈ ប្រទេសម៉ាលេស៊ី៣២នាក់ ស្រី៣១នាក់កុមារា០១នាក់(ករណី ជួញដូរកម្លាំងពលកម្ម), ប្រទេសវៀតណាមចំនួន១៦នាក់(ស្រី)(ករណីជួញដូរផ្លូវភេទ) និងប្រទេសចិនចំនួន២០នាក់(ស្រី)(ករណីជួញដូរផ្លូវភេទ) និងកុមារី០១នាក់ ប្រឈមនិងការជួញដូរ ។ ក្នុងកម្មវិធីសមិទ្ធិផលរតនៈ និងបានសហការបញ្ជូនទៅបានផ្តល់ឲ្យជនរងគ្រោះទាំង៦៩នាក់នេះ ៖

- អង្គការ MOI , អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការ ADHOC ឲ្យសេវាស្នាក់នៅរយៈពេលខ្លីឬវែងក្នុងកម្មវិធី ។
- ផ្តល់សេវាឲ្យជនរងគ្រោះដូចជា ទៅទទួលជនរងគ្រោះនៅព្រលានយន្តហោះ ឬតាមច្រកព្រំដែន និងជូនទៅសម្ភាសនៅស្នងការដ្ឋាននគរបាល ជាពិសេសបានផ្តល់អាហារ៣ពេលក្នុង១ថ្ងៃ ផ្តល់ទឹកដោះគោផៅ កញ្ចប់ជំនួយបន្ទាន់ កញ្ចប់សមាហរណកម្ម ការពិនិត្យសុខភាព ការព្យាបាលជំងឺផ្លូវចិត្ត ជួយសម្របសម្រួលសេវាផ្នែកច្បាប់ ជួយទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់អតិថិជនបានចំនួនសរុប៦៩នាក់ (ស្រី៦៧នាក់ កុមារា០១នាក់ កុមារី០១នាក់) ។

- បានសរុបចំនួន០៩នាក់ (ស្រី) ករណីជួញដូរមនុស្ស និងបានផ្តល់ឲ្យជនរងគ្រោះទាំង០៩នាក់នេះ ឲ្យស្នាក់នៅរយៈពេលវែងក្នុងកម្មវិធីសមិទ្ធិផលរតនៈ ។

៣-ការធ្វើសមាហរណកម្ម

❖ **អង្គការ HAGAR (ប្រចាំឆ្នាំ២០១៧) បាន៖**

- ធ្វើសមាហរណកម្មរងគ្រោះចំនួន**២២**នាក់ ស្ត្រី**១៧**នាក់ ដោយ(ការរំលោភបំពានផ្លូវភេទ**១០**នាក់, ជួញដូរកម្លាំងពលកម្ម**០៤**នាក់, ជួញដូរផ្លូវភេទ**០២**នាក់, ការរំលោភបំពានដោយអំពើហិង្សា**០១**នាក់, គេបោះបង់ចោល**០២**នាក់ និងហានីភ័យ**០៣**នាក់) ទៅក្នុងសហគមន៍ស្រុកកំណើតវិញ ។
- ទៅសួរសុខទុក្ខ និងតាមដានសរុបចំនួន**១០.១៨៦**ដង(ដោយផ្ទាល់ដល់ទីកន្លែងចំនួន**៧.០៣២**ដង និងតាមដានសួរសុខទុក្ខតាមរយៈទូរស័ព្ទចំនួន**៣.១៥៤**ដង) ។

❖ **អង្គការរតនៈ អន្តរជាតិ(ប្រចាំឆ្នាំ២០១៧) ៖** បានសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការ MOI អង្គការ ADHOC និងអង្គការសម្ព័ន្ធចាប់ដៃ បាន៖

➢ ធ្វើសមាហរណកម្មជនរងគ្រោះដោយ(ករណីជួញដូរផ្លូវភេទ ជួញដូរកម្លាំងពលកម្ម និងករណីប្រឈមការជួញដូរ) ពីប្រទេសនានា សរុបចំនួន**៦១**នាក់ (ស្រី**៥៩**នាក់ កុមារា០១នាក់ កុមារី០១នាក់) ទៅក្នុងសហគមន៍ នៃស្រុកកំណើតរបស់ពួកគេវិញចំនួន១៤ខេត្ត។

➢ បានធ្វើសមាហរណកម្មជនរងគ្រោះចំនួន**៣៨**លើក សរុបចំនួន**៦១**នាក់ (ស្រី៥៩នាក់ ,កុមារា០១នាក់ កុមារី០១នាក់) ទៅក្នុងសហគមន៍ស្រុកកំណើតវិញ ដែលបានសហការជាមួយ៖

- អង្គការចាប់ដៃបានទទួលជនគ្រោះចំនួន**៤៤**ករណី ចំនួន**៤៤**នាក់ (ស្រី៤២នាក់ ,កុមារា០១នាក់ កុមារី០១នាក់) មានករណីជួញដូរផ្លូវភេទចំនួន២៧នាក់,ករណីជួញដូរកម្លាំងពលកម្មចំនួន១៦នាក់(ស្រី) និងករណីប្រឈមការជួញដូរ០១នាក់។
- អង្គារ MOI ទទួលជនគ្រោះចំនួន**១៦**ករណី ករណីជួញដូរកម្លាំងចំនួន**១៦**នាក់(ស្រី)។
- អង្គការ ADHOC បានទទួលជនគ្រោះចំនួន**០១**ករណី មានករណីជួញដូរផ្លូវភេទចំនួន**០១**នាក់(ស្រី)

កម្រងរូបភាព
សកម្មភាព និងលទ្ធផលការងារ
ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
ឆ្នាំ ២០១៧

របស់

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

(គ.ជ.ប.ជ)

ការប្តេជ្ញាចិត្តរបស់ប្រមុខរដ្ឋាភិបាលនៃប្រទេសសមាជិកនៃសហគមន៍អាស៊ី-អាគ្នេយ៍ ក្នុងការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ និងប្រឆាំងការជួញដូរមនុស្ស

កិច្ចពិភាក្សាការងារ រវាងសម្តេចមហាពញ្ញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយឯកឧត្តម ផនពេជ្រ វិចិត្រឆុលឆ័យ ប្រធានសភានីតិបញ្ញត្តិថៃកាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៨ ដែលសម្តេចស្នើសុំឲ្យភាគីថៃជួយគាំពារពលករ កម្ពុជាដែលកំពុងធ្វើការក្នុងប្រទេសថៃកិច្ចពិភាក្សាការងារ





សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម ប្រាយុទ្ធ ចាន់អ៊ូចា នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃ កិច្ចសហប្រតិបត្តិការ រវាងរដ្ឋាភិបាលនៃប្រទេស ទាំងពីរ ដើម្បីដោះស្រាយរាល់ បញ្ហាពាក់ព័ន្ធនឹងសន្តិសុខជាតិ និងសុវត្ថិភាពប្រជាពលរដ្ឋ

ភាពសប្បាយរីករាយរបស់កម្មករ កម្មការិនី ពេលបានជួបសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងបានទទួលនូវគោលនយោបាយលើកកម្ពស់ស្ថានភាពជីវភាព សម្រាប់កម្មករ កម្មការិនី

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដឹកនាំការងារ គណៈកម្មាធិការជាតិដោយផ្ទាល់ និងយ៉ាងសកម្ម ជាមួយអ្នកជំនាញផ្នែកច្បាប់អន្តរក្រសួង ជាពិសេស ក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចៅក្រម ព្រះរាជអាជ្ញា នគរបាលយុត្តិធម៌ពីបណ្តាខេត្តសំខាន់ៗ បានជួបជុំគ្នា ពិភាក្សាអំពីការពង្រឹងការអនុវត្តច្បាប់ ដើម្បីយុត្តិធម៌ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស

កម្មវិធីអន្តរសាសនាអធិដ្ឋានរួមគ្នា ដើម្បីប្រឆាំងការជួញដូរមនុស្ស

កម្មវិធីប្រារព្ធធ្វើឡើង នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌល និងពិព័ណ៌ណកោះពេជ្រ

ព្រះសង្ឃ និងពុទ្ធសាសនិករាប់រយអង្គនាក់បានចូលរួមក្នុងពិធីអន្តរសាសនា បួងសួងអធិដ្ឋានដើម្បីប្រឆាំងអំពើជួញដូរមនុស្ស

មេដឹកនាំ និងសាវ:សាសនាកាតូលិកចូលរួមក្នុងកម្មវិធីអន្តរសាសនា ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌល និងពិព័ណ៌ណកោះពេជ្រ

មេដឹកនាំ និងអ្នកកាន់សាសនាឥស្លាមកម្ពុជា

កម្មវិធីយុទ្ធនាការជាតិប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ

សម្តេចក្រឡាហោម បានអញ្ជើញជាអធិបតីក្នុងកម្មវិធី យុទ្ធនាការជាតិប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ដែលមានថ្នាក់ដឹកនាំគ្រប់ក្រសួងស្ថាប័ន ផ្នែកឯកជន អង្គការដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល អាជ្ញាធរ កងកម្លាំង សិស្ស និស្សិត និងប្រជាពលរដ្ឋ ចូលរួមប្រមាណជាងបីពាន់នាក់នៅរាជធានីភ្នំពេញ

សកម្មភាពអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ត្រៀមទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ការប្រារព្ធទិវាជាតិ ១២ ធ្នូ នៅតាមបណ្តាខេត្ត

ខេត្តព្រះវិហារ

ខេត្តឧត្តរមានជ័យ

សិស្ស និស្សិត សាស្ត្រាចារ្យតាមវិទ្យាល័យ និងសាកលវិទ្យាល័យ

ការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ ដើម្បីបង្ការទប់ស្កាត់ភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាព

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី ប្រធានគ.ជ.ប.ជ បានដាក់ចេញនូវវិធានការ
គ្រប់គ្រងលំហូរមិនប្រក្រតីឆ្លងកាត់ព្រំដែនដោយបិទច្រករបៀងខុសច្បាប់តាមបណ្តោយព្រំដែន



ជំនួបរវាងរដ្ឋមន្ត្រីក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការងារថៃ
ដើម្បីដោះស្រាយភាពស្របច្បាប់ជូនពលករ

លោកជំទាវម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី ចុះសួរសុខទុក្ខកម្មករកម្មការិនី ក្នុងស្រុក នៅវត្តអង្គត្រគៀត

គណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ចុះសួរសុខទុកពលករក្នុងប្រទេសថៃ

ការលើកកម្ពស់ទេសន្តរប្រវេសន៍ដែលមានជំនាញទៅ
ប្រទេសជប៉ុនដើម្បីទទួលបានផលប្រយោជន៍ខ្ពស់

កិច្ចការពារ និងលុបបំបាត់ពលកម្មកុមារ

ឯកឧត្តម បណ្ឌិត អ៊ីត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាល
វិជ្ជាជីវៈ ចុះពិនិត្យសកម្មភាពផ្តល់ភាពស្របច្បាប់ នៅប្រទេសថៃ

ក្រុមការងារផ្តល់ភាពស្របច្បាប់
ជូនដល់បងប្អូនពលករខ្មែរយើង

ឯកឧត្តមព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដឹកនាំគណៈប្រតិភូ
ចុះសួរសុខទុក្ខពលករកម្ពុជា ដែលកំពុងធ្វើការក្នុងប្រទេសថៃ

ពលករនាំគ្នាទៅចុះឈ្មោះធ្វើលិខិតឆ្លងដែន
ប័ណ្ណស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារខាងកុះករ

ពលករខុសច្បាប់រង់ចាំការសម្របសម្រួលផ្តល់ភាព
ស្របច្បាប់ពីអាជ្ញាធរថៃក្នុងអំឡុងពេលរឹតបន្តឹងច្បាប់
ការងារ និងច្បាប់អន្តោប្រវេសន៍របស់រាជរដ្ឋាភិបាលថៃ

ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគី



ការចុះហត្ថលេខាលើកំណត់ហេតុកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ដើម្បីបង្ការ និងបង្ក្រាបអំពើជួញដូរមនុស្ស

ពិធីចុះហត្ថលេខាលើអនុស្សរណៈទ្វេភាគី កម្ពុជា ឥណ្ឌា ប្រឆាំងការជួញដូរមនុស្ស នៅទីក្រុង ញូដេលី សហភាពឥណ្ឌា

ការចុះហត្ថលេខាលើកំណត់ហេតុកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ដើម្បីបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស កិច្ចប្រជុំប្រចាំឆ្នាំលើកទី១ នៅប្រទេសចិន

កិច្ចប្រជុំអាស៊ី ប៉ាស៊ីហ្វិក ស្តីពីវេទិកាធុរកិច្ចដើម្បីប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស នៅទីក្រុង PERTH ប្រទេសអូស្ត្រាលី

កិច្ចប្រជុំពិភពលោក ស្តីពី សេចក្តីព្រាងបឋម កតិការសញ្ញ ពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ នៅទីក្រុងម៉ិចស៊ិកូ ប្រទេសមិកស៊ិក

ចូលរួមកិច្ចប្រជុំ និងទស្សនកិច្ចសិក្សា នៅសាធារណៈរដ្ឋកូរ៉េខាងត្បូង

កិច្ចប្រជុំពិគ្រោះយោបល់ អាស៊ី ប៉ាស៊ីហ្វិក ស្តីពីការត្រៀមរៀបចំកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ នៅអាគារអង្គការសហប្រជាជាតិ នាទីក្រុងបាងកក

សម្តេចក្រឡាហោម ស ខេង ប្រធានគ.ជ.ប.ជ ដឹកនាំកិច្ចប្រជុំថ្នាក់ជាតិ ដើម្បីប្រមូលធាតុចូលសម្រាប់ការស្នើដាក់បញ្ចូលក្នុងការរៀបចំកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់

សិក្ខាសាលាស្តីពី ការគ្រប់គ្រងលំហូរមិនប្រក្រតីនៃទេសន្តរប្រវេសន៍ នៅខេត្តបន្ទាយមានជ័យ

សម្តេចក្រឡាហោម ស ខេង ប្រធាន គ.ជ.ប.ជ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការជាតិ ពិភាក្សាលើវិធានការប្រឆាំងករណីជួញដូរមនុស្ស

លោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី ដឹកនាំកិច្ចប្រជុំទ្វេភាគីពិភាក្សលើ សេចក្តីព្រាងអនុស្សរណៈប្រឆាំងការជួញដូរមនុស្ស ជាមួយម៉ាលេស៊ី



ការផ្តល់ព័ត៌មានអំពីការងារប្រឆាំងការជួញដូរមនុស្ស

សិក្ខាសាលាស្ដីពី កិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមបណ្ដាខេត្តគោលដៅ

ខេត្តបន្ទាយមានជ័យ និង ឧត្តរមានជ័យ

ខេត្តកោះកុង

សិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស នៅតាមសាលារៀន

វគ្គបណ្តុះបណ្តាលគ្រូបង្គោលនគរបាលជាតិ
ស្តីពីនីតិវិធីនៃការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស

វគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស

វេទិកាផ្សព្វផ្សាយពិគ្រោះយោបល់ ស្ដីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សរបស់ គ ខ ប ជ

យុទ្ធនាការប្រឆាំងការជួញដូរមនុស្ស

យុទ្ធនាការប្រឆាំងការជួញដូរមនុស្ស

យុទ្ធនាការប្រឆាំងការជួញដូរមនុស្ស

ថ្នាក់ដឹកនាំ បានចុះជួបសំណេះសំណាល ជាមួយប្រជាពលរដ្ឋដោយផ្ទាល់

ជំនួបពិភាក្សាការងារ រវាងលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាមួយ តំណាងអង្គទូតនានា ប្រចាំព្រះរាជាណាចក្រកម្ពុជា

ជំនួបពិភាក្សាជាមួយតំណាងស្ថានទូតអាមេរិច លើលទ្ធផលនៃការវាយតម្លៃការងារប្រឆាំងការជួញដូរមនុស្ស

ការពង្រឹងការអនុវត្តច្បាប់

កិច្ចប្រជុំផ្សព្វផ្សាយ និងត្រួតពិនិត្យការអនុវត្តន៍គោលការណ៍ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ

សមត្ថកិច្ចតាមព្រំដែនព្យាយាមបង្ការទប់ស្កាត់ការឆ្លងដែនដោយខុសច្បាប់ ដោយធ្វើការអប់រំឲ្យត្រឡប់វិញ

សិក្ខាសាលាផ្សព្វផ្សាយការយល់ដឹងអំពីអនុសញ្ញាអាស៊ានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រីនិងកុមារ និងផែនការសកម្មភាពអាស៊ាន

វគ្គបណ្តុះបណ្តាលមន្ត្រីជួរមុខថ្នាក់ខេត្ត (ឧត្តរមានជ័យ) និងស្រុកសម្រាប់ការងារប្រឆាំងការជួញដូរមនុស្ស

សិក្ខាសាលារៀបចំផែនការខេត្តស្វាយរៀង

ការចុះស្រាវជ្រាវស្ថានភាពទេសន្តរប្រវេសន៍តាមបណ្តោយព្រំដែន

ការចុះត្រួតពិនិត្យច្រកដូង ផ្នែកខាងដីថៃ

ការជួបសំណេះសំណាល ណែនាំពលករ និងអាជីវករដែលកំពុងឆ្លងដែនចូលព្រំដែនថៃ

ការជួបពិភាក្សាជាមួយអាជ្ញាធរខេត្ត ប៉ៃលិន

ការចុះពិនិត្យព្រំដែន ខេត្តប៉ៃលិន

ការចុះពិនិត្យទីតាំងឆ្លងកាត់ ជាប្រចករបៀង

កិច្ចប្រជុំជាមួយអាជ្ញាធរខេត្តបន្ទាយមានជ័យ

ពិភាក្សាលើស្ថានភាពទូទៅ និងកំណត់ទីតាំងគោលដៅចុះពិនិត្យ



ការជួបពិភាក្សាជាមួយអាជ្ញាធរខេត្តបាត់ដំបង

ការជួបប្រាស្រ័យជាមួយសមត្ថកិច្ចថៃដែលប្រតិបត្តិការជាប់ព្រំដែនស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

ការជួបពិភាក្សាជាមួយមន្ត្រីនគរបាលប៉ុស្តិ៍ព្រំ ខេត្តប៉ៃលិន សិក្សាអំពីការគ្រប់គ្រងលំហូរពលករ

ការជួបជាមួយពលករដែលវិលត្រឡប់ពីប្រទេសថៃ

សិក្ខាសាលាស្តីពីការពង្រឹងកិច្ចសហការប្រឆាំងការជួញដូរកម្ម គាំទ្រដោយអង្គការ IJM

កិច្ចសហការពីអង្គការUSAID តាមរយៈអង្គការវិនរ៉ក់អន្តរជាតិ

បញ្ហាទេសន្តរប្រវេសន៍ និងភាពរងគ្រោះ

ប្រជាពលរដ្ឋនៅតែប្រថុយប្រថាន
លួចលាក់ឆ្លងដែនដោយខុសច្បាប់

ការលបលួចឆ្លងដែនខុសច្បាប់
ត្រូវបានអាជ្ញាធរថៃឃាត់ខ្លួន



សមត្ថកិច្ចថៃឃាត់ខ្លួនពលករដែលលួចឆ្លងដែនខុសច្បាប់

ពលករដែលឆ្លងដែនខុសច្បាប់ត្រូវបានឃាត់ខ្លួន
ដោយអាជ្ញាធរថៃ

អាជ្ញាធរថៃចុះស្រាវជ្រាវរកពលករខ្មែរខុសច្បាប់ដែលធ្វើ
ការលើទូកនេសាទ

អាជ្ញាធរថៃចុះត្រួតពិនិត្យដើម្បីហាមឃាត់ពលករខ្មែរ លាវ
ភូមា ដែលប្រកបអាជីវកម្ម ដែលត្រូវបានហាមឃាត់
(៣៦មុខ) រួមទាំងការលក់ដូរតាមទីសាធារណៈ

អាជ្ញាធរថៃចាប់ពលករឆ្លងដែនដោយផ្លោះរបង
តាមព្រំដែន

ការបង្ក្រាបទីតាំងធ្វើប័ណ្ណស៊ីជម្ពូក្លែងក្លាយក្នុងប្រទេសថៃ
ដែលពលករមួយចំនួនបានប្រើប្រាស់ដោយមិនបានដឹង

ពលករបង្ហាញអំពីបទដ្ឋានដែលខ្លួនប្រើប្រាស់
និងមេខ្យល់អ្នកនាំ

ការងារក្នុងវិស័យនេសាទសមុទ្រ

សាកសពពលករត្រូវបានប្រមូលពីក្នុងទឹក

ការប្រមូលសាកសពជនរងគ្រោះដែលបាត់បង់ជីវិតដោយ
គ្រោះថ្នាក់កប៉ាល់បុកទូកនេសាទ

របាយការណ៍នេះអាចទាញយកពី គេហទំព័រ

www.ncct.gov.kh

បោះពុម្ពដោយៈ

ថវិកាជាតិ

បោះពុម្ពនៅ រោងពុម្ពអន្តរជាតិ ចំនួន១៥០០ក្បាល